# មេរៀន

# កិច្ចការក្រឡាបញ្ជី

www.facebook.com/7khmer
fb : Entertainment  And Knowledge

# កិច្ចការក្រឡាបញ្ជីក្នុងរឿងរដ្ឋប្បវេណី

## ជំពូកទី ១

## កិច្ចការក្រឡាបញ្ជីក្នុងរឿងរដ្ឋប្បវេណី

### ផ្នែកទី ១ ៖ កិច្ចការក្រឡាបញ្ជីក្នុងនីតិវិធីជំនុំជម្រះក្តីលើកទី១
### កថាភាគទី១៖កិច្ចការពេលមានការដាក់ពាក្យបណ្តឹង

នីតិវិធីនៃបណ្តឹងរដ្ឋប្បវេណីនៅតុលាការ ត្រូវចាប់ផ្តើមនៅពេលដាក់ពាក្យបណ្តឹង ។ នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី នៅមាត្រា៧៥ កថាខ័ណ្ឌទី១ បណ្តឹង ត្រូវធ្វើឡើងដោយការដាក់ពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរ ទៅតុលាការ ឬអាចធ្វើដោយផ្ទាល់មាត់បាន ករណីនេះអាចធ្វើទៅបានចំពោះរឿងក្តី ដែលមានទឹកប្រាក់តិច ហើយក្រឡាបញ្ជី ត្រូវកត់ត្រានូវសេចក្តីថ្លែងការណ៍របស់ដើមចោទនោះក្នុងកំណត់ហេតុតាមមាត្រា ២២៥នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ដោយយោងតាម មាត្រា ៧៥ បានកំណត់នូវលក្ខខណ្ឌដែលត្រូវសរសេរក្នុងពាក្យបណ្តឹង៖

**១-ការប្តឹងត្រូវធ្វើពាក្យបណ្តឹងជាលាយល័ក្ខណ៍អក្សរនៅតុលាការ**

ជាទូទៅរាល់ពាក្យបណ្តឹង ត្រូវសរសេរជាលាយល័ក្ខណ៍អក្សរដាច់ខាត ហើយត្រូវយកទៅដាក់នៅតុលាការដែលមានសមត្ថកិច្ច "មាត្រា ៧៥កថាខ័ណ្ឌទី១" ។

*សារៈប្រយោជន៍នៃការសរសេរពាក្យបណ្តឹងជាលាយល័ក្ខអក្សរៈ*

- ធ្វើអោយតុលាការយល់ដឹងច្បាស់ពីខ្លឹមសារដែលដើមចោទសុំឱ្យតុលាការចេញសាលក្រម
- ធ្វើអោយតុលាការយល់ដឹងច្បាស់ពីអត្ថិភាពនៃសិទ្ធិ និង នត្ថិភាពនៃសិទ្ធិក្នុងការទាមទាររបស់ដើមចោទ
- ជាឯកសារបញ្ជាក់អំពីចំណុចទាមទារឱ្យតុលាការចេញសាលក្រម
- ជាឯកសារត្រៀមក្នុងករណីដែលពាក្យបណ្តឹងមានសរសេរពីមធ្យបាយតទល់ ឬការពារខ្លួន

www.facebook.com/7khmer
fb : Entertainment  And Knowledge

## ២-ឈ្មោះ និង អាសយដ្ឋានរបស់ភាគី និង អ្នកតំណាងដែលច្បាប់បានកំណត់

នៅក្នុងពាក្យបណ្ដឹង ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីភាគី ដែលជាប្រធាននៃបណ្ដឹងអ្នកតំណាង ដែលច្បាប់បានកំណត់ព្រមទាំងអាសយដ្ឋានឱ្យបានត្រឹមត្រូវ ។ ហេតុដូច្នេះហើយ ដើម្បីបញ្ជាក់ភាគី ដែលត្រូវចូលរួមក្នុងនីតិវិធីដោះស្រាយរបស់តុលាការក្នុងពាក្យបណ្ដឹងត្រូវសរសេរដូចខាងក្រោមៈ

### <u>-ឈ្មោះ និង អាសយដ្ឋានរបស់ដើមចោទ និង អ្នកតំណាងដែលច្បាប់បានកំណត់ ៖</u>

ជាធម្មតាការបញ្ជាក់បង្ហាញដើមចោទ ត្រូវធ្វើឡើងដោយការសរសេរឈ្មោះរបស់ដើមចោទ ហើយដើម្បីឱ្យកាន់តែច្បាស់លាស់ថែមទៀតនោះ ត្រូវសរសេរអាសយដ្ឋានផងដែរក្នុងពាក្យបណ្ដឹង ។ ក្នុងករណីដែលដើមចោទជារូបវន្តបុគ្គលឈ្មោះ ត្រូវសរសេរក្នុងពាក្យបណ្ដឹង គឺជាឈ្មោះដែលសរសេរនៅក្នុងសំបុត្រកំណើតក្នុងករណី ដែលគ្មានសំបុត្រកំណើត ត្រូវសរសេរឈ្មោះដែលមានសរសេរក្នុងអត្តសញ្ញាណប័ណ្ណ ហើយនៅតែគ្មានអត្តសញ្ញាណប័ណ្ណទៀត ត្រូវសរសេរឈ្មោះ ដែលមាននៅក្នុងសៀវភៅគ្រួសារនិយាយជារួមមក គឺដើម្បីឱ្យមានភាពងាយស្រួលក្នុងការបញ្ជូនឯកសារភាគីគប្បីសរសេឈ្មោះដែលយកជាផ្លូវការផង និង ឈ្មោះហៅក្រៅផង ។ ចំពោះដើមបណ្ដឹងជានីតិបុគ្គលត្រូវសរសេរឈ្មោះ ឬឈ្មោះករណ៍ និង អាស័យដ្ឋាននីតិបុគ្គលឱ្យបានត្រឹមត្រូវ និង ច្បាស់លាស់ក្នុងពាក្យបណ្ដឹងពោលគឺ ត្រូវសរសេរឈ្មោះ ឬនាមករណ៍ដែលបានចុះបញ្ជីតាមច្បាប់ ។ ចំណែកអ្នកតំណាងដែលច្បាប់បានកំណត់វិញត្រូវសរសេរឈ្មោះផ្លូវការឱ្យ បានច្បាស់លាស់ព្រមទាំងអាសយដ្ឋានឱ្យបានត្រឹមត្រូវ ដើម្បីបញ្ជាក់ឱ្យបានច្បាស់លាស់នូវអ្នកដែលមានសិទ្ធិបន្តនីតិវិធីក្នុងករណី ដែលដើមចោទជាបុគ្គលអសមត្ថភាពក្នុងពាក្យបណ្ដឹង ឬករណីផ្សេងទៀត ដែលដើមចោទមិនចូលរួមក្នុងនីតិវិធីរបស់តុលាការដោយខ្លួនឯងបាន ។ ប្រសិនបើដើមចោទជា នីតិបុគ្គលដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណី គឺមានអ្នកតំណាងរបស់នីតិបុគ្គលនោះ ដូច្នេះឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងនោះ គប្បីត្រូវសរសេរនៅក្នុងពាក្យបណ្ដឹង ។

*ផលប្រយោជន៍នៃការសរសេរឈ្មោះ និង អាសយដ្ឋានរបស់ដើមចោទ និង អ្នកតំណាងដែលច្បាប់បានកំណត់:*

- ងាយស្រួល ឱ្យតុលាការកោះហៅឱ្យមកកែតំរូវពាក្យបណ្ដឹង

www.facebook.com/7khmer
fb : Entertainment  And Knowledge

- ងាយស្រួល ឱ្យតុលាការធ្វើការកោះហៅឱ្យចូលរួមតាមដំណាក់កាលនៃនីតិវិធី
- ងាយស្រួល ឱ្យចុងចំលើយផ្ញើរឯកសារផ្សេងៗក្នុងដំណើការរឿងក្តី

<u>-ឈ្មោះ និង អាសយដ្ឋានរបស់ចុងចំលើយ</u>

នៅក្នុងពាក្យបណ្តឹង ពោលដើមចោទ ក៏ត្រូវសរសេរឈ្មោះ និង អាសយដ្ឋានរបស់ចុងចំលើយឱ្យបានច្បាស់លាស់ និង ត្រឹមត្រូវក្នុងពាក្យបណ្តឹងរបស់ខ្លួនដូចអ្វីដែលខ្លួនបានសរសេរអំពីឈ្មោះ និង អាសយដ្ឋានរបស់ខ្លួនដែរ ។ ការសរសេរឈ្មោះ និង អាសយដ្ឋានរបស់ចុងចំលើយបានច្បាស់លាស់ជាចំណុច ដែលដើមចោទចាំបាច់ ត្រូវសរសេរដើម្បីឱ្យតុលាការងាយស្រួលកំណត់ថាអ្នកណាជាគូវិវាទនៃរឿក្តី ។

*ផលប្រយោជន៍នៃការសរសេរឈ្មោះ និង អាសយដ្ឋានរបស់ចុងចំលើយនៅក្នុងពាក្យបណ្តឹង:*

- ងាយស្រួល ឱ្យតុលាការកំណត់អំពីសមត្ថកិច្ចក្នុងការដោះស្រាយ
- ងាយស្រួល ឱ្យតុលាការផ្ញើរពាក្យបណ្តឹងរបស់ដើមចោទទៅឱ្យចុងចំលើយ"ម-៧៩ កថាខ័ណ្ឌទី១នៃក្រមនីតិវិធីរដ្ឋប្បវេណី" ។
- ងាយស្រួលបញ្ជូនឯកសារ ដែលពាក់ព័ន្ធនឹងបណ្តឹង
- ងាយស្រួល ឱ្យតុលាការធ្វើការកោះហៅឱ្យមកចូលរួមតាមដំណាក់កាលនៃនីតិវីធីមានចែងនៅមាត្រា ៨០ និង ១១៣នៃក.ន.រ ។

**៣-ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និង អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ:**

ខ្លឹមសារនៃសាលក្រម ត្រូវបញ្ជាក់អំពីកម្មវត្ថុ ដែលត្រូវវិនិច្ឆ័យក្នុងពាក្យបណ្តឹងរដ្ឋប្បវេណីទំហំ ឬកំរិតនៃការវិនិច្ឆ័យដោយតុលាការ ។ ដើមចោទចាំបាច់ ត្រូវសរសេរក្នុងពាក្យបណ្តឹងអំពីខ្លឹមសាលក្រមដែលដើមចោទទាមទារឱ្យតុលាការ ចេញឱ្យបានច្បាស់លាស់ ។

ដូចនេះចំពោះអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារវិញ ដើមចោទត្រូវសរសេរអំពីអង្គហេតុដែលបង្កើតសិទ្ធិទាមទារ ឬអង្គហេតុរំលាយសិទ្ធិទាមទារ ។

អង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ គឺជាអង្គហេតុដែលដើមចោទទាមទារឱ្យតុលាការវិនិច្ឆ័យ និង ចេញសាលក្រមចំពោះបណ្តឹងរបស់ខ្លួន ដើម្បីកុំឱ្យការទាមទារនោះមានការភាន់ច្រឡំជាមួយការទាមទារផ្សេងទៀត ។

**៤-អង្គហេតុដែលជាមូលហេតុនៃការទាមទារ**

អង្គហេតុដែលជាមូលហេតុនៃការទាមទារ មិនចាំបាច់ត្រូវសរសេរជាដាច់ខាតក្នុងពាក្យបណ្តឹងទេ ប៉ុន្តែអង្គហេតុដែលជាមូលហេតុនៃការទាមទារ គឺជាអង្គហេតុដែលជួយបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិ ឬនត្ថិភាពនៃសិទ្ធិទាមទារឱ្យកាន់តែច្បាស់លាស់ ។ ចំណុចនេះដើមចោទត្រូវសរសេរក្នុងពាក្យបណ្តឹងរបស់ខ្លួននូវអង្គហេតុ ដែលជាមូលហេតុនៃការទាមទារនូវមូលហេតុនីមួយៗ ដែលចាំបាច់ ត្រូវធ្វើការបញ្ជាក់ដោយភស្តុតាងនូវអង្គហេតុសំខាន់ៗនៃអត្ថិភាពនៃសិទ្ធិ ឬនត្ថិភាពនៃសិទ្ធិទាមទារ ព្រមទាំងភស្តុតាងនីមួយៗផងដែរ ។ ការសរសេរដូចនេះមានគោលបំណងធ្វើការពង្រឹងខ្លឹមសារ ដែលសរសេរក្នុងពាក្យបណ្តឹង ដើម្បីបង្ហាញឱ្យបានឆាប់រហ័សនូវរឿងវិវាទចំពោះតុលាការផងចំពោះចុងចំលើយផង និង ដើម្បីងាយស្រួលដល់គូវិវាទប្រឆាំងតទល់គ្នា ព្រមទាំងធ្វើឱ្យតុលាការចាប់ផ្តើមធ្វើការវិនិច្ឆ័យបានស្រួល ។

**៥-អង្គហេតុសំខាន់ៗពាក់ព័ន្ធ នឹង អង្គហេតុដែលជាមូលហេតុនៃការទាមទារ**

ចំពោះអង្គហេតុសំខាន់ៗពាក់ព័ន្ធនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារក៏ជាអង្គហេតុដែលជួយឱ្យអត្ថិភាពនៃសិទ្ធិទាមទារផងដែរ ។ ចំណុចនេះដើមចោទ ត្រូវសរសេរនូវអង្គហេតុដែលជាមូលហេតុនាំឱ្យកើតវិវាទ ដែលត្រូវដោះស្រាយដោយចេញសាលក្រម ។

***<u>សំគាល់:</u>***ការសរសេរពាក្យបណ្តឹង ដែលមិនគោរពទៅតាមល័ក្ខខណ្ឌនៃមាត្រា ៧៥ នាំឱ្យមានផលវិបាកដូចតទៅ:

១- តុលាការ ឱ្យដើមចោទមកកែតំរូវពាក្យបណ្តឹង"មាត្រា ៧៨កថាខណ្ឌទី ១"

២- ករណីដើមចោទមិនមកកែតំរូវពាក្យបណ្តឹងទេនោះ តុលាការលើកពាក្យបណ្តឹងចោលដោយដីកាសំរេច"មាត្រា ៧៨កថាខ័ណ្ឌ ទី២" ។

៣- ធ្វើឱ្យដើមចោទខាតបង់ថវិកា និង ពេលវេលាច្រើន ។

www.facebook.com/7khmer
fb : Entertainment  And Knowledge

## កថាភាគទី២-កិច្ចការក្នុងការទទួលពាក្យបណ្ដឹង:

នៅពេលពាក្យបណ្ដឹង ត្រូវបានដាក់នៅតុលាការ ក្រឡាបញ្ជីជាអ្នកមានភារកិច្ចទទួលពាក្យបណ្ដឹង ហើយត្រូវអនុវត្តតាមជំហានដូចខាងក្រោម:

១. ពិនិត្យលើពាក្យបណ្ដឹង និង ទទួលយកពាក្យបណ្ដឹង
២. វាយត្រា លើពាក្យបណ្ដឹង ដែលបានទទួលនោះ
៣. ចុះ ថ្ងៃ ខែ ឆ្នាំ ដែលបានទទួល
៤. ចុះលេខរៀង នៅក្នុងសៀវភៅបណ្ដឹង និង លើពាក្យបណ្ដឹង
៥. យកក្របសំណុំរឿងមកគៀបសំណុំរឿងនោះ
៦. បែងចែងសំណុំរឿងនៃបណ្ដឹងនោះ ទៅឱ្យចៅក្រម ដែលត្រូវទទួលបន្ទុករឿងក្ដី
៧. ប្រគល់សំណុំរឿង ឱ្យចៅក្រមទទួលវេនតាមលំដាប់នៃការបែងចែករឿងក្ដី ដែលកំណត់ប្រចាំឆ្នាំជាមុន ដោយប្រធានតុលាការ ។
៨. ចំពោះពាក្យបណ្ដឹងដែលមានការខ្វះខាត ច្បាប់អនុញ្ញាតិឲ្យក្រឡាបញ្ជីមានយោបល់ចំពោះពាក្យបណ្ដឹងនោះបានដើម្បីពន្យល់ដល់អ្នកដាក់ពាក្យបណ្ដឹងដូចជា ពាក្យបណ្ដឹងមានការ ខ្វះខាតឈ្មោះ របស់ភាគី អាសយដ្ឋាន ដែលផ្ទុយនឹងកថាខ័ណ្ឌទី២នៃមាត្រា ៧៥ជាដើម ។
៩. ក្រឡាបញ្ជីអាចផ្ដល់យោបល់ បាននៅមុនពេលទទួលពាក្យបណ្ដឹងតែប៉ុណ្ណោះ
១០.ក្រឡាបញ្ជីគ្មានសិទ្ធិ ខាងផ្លូវច្បាប់ក្នុងការពិនិត្យពាក្យបណ្ដឹងឡើយ ។

ការពិនិត្យពាក្យបណ្ដឹងជាសិទ្ធិរបស់តុលាការដូចមានចែងនៅមាត្រា ៧៨ ។ ដូចនេះទោះបីជាពាក្យបណ្ដឹងនោះមានភាពចន្លោះជាក់ស្ដែងក៏ដោយ ក៏ក្រឡាបញ្ជីគ្មានសិទ្ធិមិនទទួលពាក្យបណ្ដឹងឡើយ ។ បើកិច្ចដែលក្រឡាបញ្ជី អនុវត្តតាមជំហានខាងលើនេះមានលក្ខណៈត្រឹមត្រូវ និង ច្បាស់លាស់ ហើយនោះវា និង មានការទាក់ទងយ៉ាងជិតស្និទ្ធិ និងតម្លាភាពទៅនឹងនីតិវិធីនៃការបែងចែកសំណុំរឿង ទៅចៅក្រម ដើម្បីចាត់ការបន្តតាមនីតិវិធីដូចមានចែងនៅមាត្រា២៦នៃក្រមនីតិវិធីរដ្ឋប្បវេណីនេះផងដែរ ។

### ១-ការបង់ពន្ធលើការដាក់ពាក្យបណ្ដឹង

#### ១-១-ការបង់ពន្ធនៃការដាក់ពាក្យបណ្ដឹង (មាត្រា ៦១)

www.facebook.com/7khmer
fb : Entertainment And Knowledge

នៅពេលដែលពាក្យបណ្តឹងត្រូវបានដាក់ ភាគីត្រូវបង់ពន្ធនៃការដាក់ពាក្យបណ្តឹងនោះ ដោយគណនាទៅតាមតំលៃកម្មវត្ថុនៃបណ្តឹងតាមបញ្ញត្តិនៃមាត្រា៦១នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ តុលាការអាចមានលទ្ធភាព ប្រមូលប្រាក់ពន្ធនៃការដាក់ពាក្យ បណ្តឹងបន្ថែមទៀតក៏បាន ក៏ចំណុចនេះអាចធ្វើបានដែរ ដូចមានចែងនៅមាត្រា៦១បានចែងថា"តំលៃនៃការបង់ពន្ធក្នុងការដាក់ពាក្យបណ្តឹង គឺជាវាយតំលៃដ៏សមរម្យមួយ ដែលគណនាទៅតាមកម្មវត្ថុនៃពាក្យបណ្តឹង ។

## ១-២-ប្រាក់ប្រដាប់ក្តីតុលាការ ក្រៅពីប្រាក់ពន្ធ (មាត្រា ៦២)

ក្រៅពីប្រាក់ដែលដើមបណ្តឹង ត្រូវបង់នៅពេលដែលដាក់ពាក្យបណ្តឹងទៅតុលាការតាមបញ្ញត្តិ នៃមាត្រា៦១ ដើមបណ្តឹងត្រូវបង់ប្រាក់ប្រដាប់ក្តីក្រៅពីពន្ធមួយចំនួនជាមុន និង ជាចាំបាច់ផងដែរសំរាប់តុលាការធ្វើការបញ្ជូនឯកសារបន្ទាប់ពីបណ្តឹងត្រូវបានដាក់ ដូចជាៈ

១. ការបញ្ជូនពាក្យបណ្តឹង និង ឯកសារភ្ជាប់នឹងពាក្យបណ្តឹងទៅ ចុងចំលើយ[1]
២. ការបញ្ជូនដីកាកោះហៅភាគី (មាត្រា ៨០ កថាខណ្ឌទី ១ )
៣. ចំនួនទឹកប្រាក់ និង ការចំណាយក្នុងការផ្ញើរសំបុត្រ តាមរយៈបុស្តិ៍ ប្រៃសណីយ៍ ឬអាជ្ញាសាលា ។
៤. ចំនួនទឹកប្រាក់ សំរាប់ការចាយវាយទៅតាមរយៈចំងាយពីតុលាការទៅតំបន់គោលដៅ ដែលត្រូវផ្ញើរសំបុត្រ ដោយមានបញ្ជីចំណាយច្បាស់លាស់ ។

ប្រសិនបើប្រាក់ប្រដាប់ក្តីដែលដើមចោទបង់ឱ្យតុលាការនោះប្រើប្រាស់មិនគ្រប់គ្រាន់ តុលាការបង្គាប់ឱ្យដើមចោទបង់ប្រាក់ប្រដាប់ក្តីបន្ថែមទៀតបាន ។ ក្រៅពីនេះ ប្រាក់ប្រដាប់ក្តីក្រៅពីពន្ធផ្សេងពីការចាំបាច់ខាងលើ តុលាការអាចបង្គាប់អោយបង់ តាមករណីជាក់ស្តែង ដែលត្រូវចំណាយ និង តាមដំណាក់កាលនៃនីតីវិធីដូចមានបញ្ញត្តិនៅក្នុងមាត្រា៦២នៃក្រមនីតីវិធីរដ្ឋប្បវេណី ។

ហេតុដូចនេះហើយនៅពេល ដែលពាក្យបណ្តឹងត្រូវបានដាក់ ដល់តុលាការភាគីត្រូវបង់ពន្ធនៃការដាក់ពាក្យបណ្តឹងតាមមាត្រា៦១ និង បង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធមាត្រា ៦២ នៃក្រមនីតីវិធីរដ្ឋប្បវេណី ។

---

[1] -មាត្រា ៧៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី

www.facebook.com/7khmer
fb : Entertainment And Knowledge

**២-ការបែងចែករឿងក្តី**

ដោយផ្អែកតាមមាត្រា២៦នៃក្រមនីតិវិធីរដ្ឋប្បវេណី មានអត្ថន័យថា នៅតាមតុលាការនីមួយៗការបែងចែករឿងក្តី និង លំដាប់ជំនួសក្នុងករណីដែលចៅក្រមណាមួយមានធុរៈ ត្រូវបានកំណត់ជាមុននៅរៀងរាល់ឆ្នាំ ដោយដីកាសំរេចរបស់ប្រធានតុលាការនោះ ហើយការបែងចែករឿងក្តីនីមួយៗទៅឱ្យចៅក្រមម្នាក់ៗគឺ ត្រូវកំណត់ ដោយលំដាប់ជាស្វ័យប្រវត្តិដោយបានកំណត់ដោយវិធានមួយ ដែលកំណត់ជារៀងរាល់ឆ្នាំក្នុងកិច្ចការរដ្ឋបាលនៃអំណាចតុលាការ ។ ក្នុងការបែងចែកភារកិច្ចនៃការដោះស្រាយ ក៏ត្រូវកំណត់ពីប្រភេទនៃរឿងក្តីណាមួយ ដែលត្រូវដោះស្រាយដោយក្រុមប្រឹក្សាជំនុំជំរៈផងដែរ ។ ប្រសិនបើតុលាការនីមួយៗមិនបានកំណត់អំពីវិធីបែងចែករឿងក្តីជាមុនទេ នោះនឹងធ្វើឱ្យមានគុណវិបត្តិ ដូចជាការដោះស្រាយរឿងក្តីមានការកកស្ទះ និង មានភាពលំអៀងជាមិនខាន ។ ដូចនេះការបែងចែករឿងក្តីឱ្យចៅក្រមទទួលបន្ទុកជាស្វ័យប្រវត្តិតាមរបៀប ដែលបានកំណត់ទុកជាមុន នាំឱ្យតុលាការអាចរក្សាបាននូវអព្យាក្រឹត្យភាព ។

**ភាពខុសគ្នារវាងចៅក្រមជំនុំជំរះតែម្នាក់ឬ ចៅក្រមជំនុំជំរះបីនាក់ មានដូចតទៅ:**

**២-១- ចំពោះចៅក្រមជំនុំជំរះ៣នាក់**

-រឿងក្តីដែលច្បាប់កំណត់ថា ត្រូវវិនិច្ឆ័យ និង ជម្រះក្តីដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម មាត្រា ២៣ កថាខណ្ឌទី ២ ចំណុច ខ ។

-គ្រប់រឿងក្តីដែលមានកម្មវត្ថុនៃបណ្តឹង មានតម្លៃមិនតិចជាង ៥.០០០.០០០(ប្រាំលាន) រៀល ហើយតុលាការ ទទួលស្គាល់ថា គួរតែត្រូវបានវិនិច្ឆ័យ និង ជម្រះដោយក្រុមប្រឹក្សាជំនុំជម្រះ ដោយគិតពិចារណាអំពីចំនួនគូភាគី និង បញ្ហាផ្សេងទៀត មាត្រា ២៣ កថាខណ្ឌទី ២ ចំណុច ក ។

**២-២-ចំពោះចៅក្រមជំនុំជំរះម្នាក់**

-គ្រប់រឿងក្តីទាំងអស់ លើកលែងតែរឿងក្តី ដែលច្បាប់បានកំណត់ថាត្រូវធ្វើការវិនិច្ឆ័យ និង កាត់សេចក្តីដោយក្រុមប្រឹក្សាជំនុះជំរះ ត្រូវធ្វើការបែងចែកទៅចៅក្រមជំនុំជំរះម្នាក់នៅសាលាដំបូង ដែលត្រូវធ្វើទៅតាមលំដាប់នៃការបែងចែករឿងក្តី សំរាប់ចៅក្រមម្នាក់ដូចមាន

ចែងនៅមាត្រា ២៣ កថាខ័ណ្ឌទី១ ។

ដោយយោងទៅលើលំដាប់នៃការបែងចែករឿងក្តីសំរាប់ក្រុមប្រឹក្សាជំនុំជំរះក្រុមប្រឹក្សាត្រូវការកំណត់ថារឿងក្តីនេះចាំបាច់ ត្រូវធ្វើការជំនុំជំរះដោយក្រុមប្រឹក្សា ដែរឬទេ? ពោលនៅពេលដែលក្រុមប្រឹក្សាសំរេចថារឿងក្តីនេះ ត្រូវធ្វើការជំនុំជំរះដោយក្រុមប្រឹក្សាជំនុំជំរះតុលាការត្រូវចេញដីការសំរេច ។ នៅក្នុងករណីនេះ ចៅក្រមម្នាក់ដែលត្រូវបានចាត់តាំងឱ្យដោះស្រាយរឿងក្តីតាំងពីពេលដំបូងមិនចាំបាច់ ត្រូវក្លាយជាសមាជិកនៃក្រុមប្រឹក្សាជំនុំជំរះដើម្បីវិនិច្ឆ័យរឿងក្តីបានឡើយ ។

ខ:តាមការបែងចែករឿងក្តី នៅតុលាការមួយគឺ បាន ទៅចៅក្រម "ក" ហើយ ចៅក្រម "ក"ក្រោយពីពិនិត្យលើពាក្យបណ្តឹង ដែលខ្លួនបានទទួលបន្ទុកហើយយល់ឃើញថាខ្លួនមិនអាចដោះស្រាយបានទេគឺ ត្រូវដោះស្រាយដោយក្រុមប្រឹក្សាជំនុំជំរះនៃចៅក្រមរួចបញ្ជូនរឿងក្តីទៅក្រុមប្រឹក្សាជំនុំជំរះនៃចៅក្រមដើម្បីសំរេចថាតើរឿងក្តីនោះ ត្រូវដោះស្រាយដោយចៅក្រមម្នាក់ ឬដោយក្រុមប្រឹក្សាជំនុំជំរះនៃចៅក្រម ។ ការសំរេចនេះត្រូវចេញជាដីកាសំរេច ។

### ៣-ការពិនិត្យពាក្យបណ្តឹង:

នៅពេលបណ្តឹង ត្រូវបានដាក់នៅតុលាការហើយបណ្តឹងនោះបានបញ្ជូនដល់ដៃតុលាការ តុលាការ ត្រូវធ្វើការពិនិត្យលើពាក្យបណ្តឹង ដោយផ្អែកតាមមាត្រា៧៨នៃក្រមនីតិវិធីរដ្ឋប្បវេណី អំពីទំរង់នៃពាក្យបណ្តឹង តើមានលក្ខណ:ត្រឹមត្រូវ និង ពេញលេញតាមមាត្រា៧៥កថាខ័ណ្ឌទី២ ហើយ ឬនៅដូចជា៖

១. អាសយដ្ឋានរបស់ភាគីនៃបណ្តឹង
២. ខ្លឹមសារនៃសាលក្រម ដែលដើមចោទទាមទារឱ្យតុលាការចេញ
៣. អង្គហេតុចាំបាច់ ដើម្បីបញ្ជាក់នូវការទាមទារ
៤. ការបង់ពន្ធបានត្រឹមត្រូវដែរ ឬទេ តាមបញ្ញត្តិនៃមាត្រា ៦១
៥. ប្រាក់ចាំ ដែលជាប្រាក់ប្រដាប់ក្តីតុលាការ សំរាប់ការបញ្ជូនហើយ ឬនៅ ។

គោលបំណងនៃការពិនិត្យពាក្យបណ្តឹងនេះ គឺជាការពិនិត្យពីភាពស្រប ឬមិនស្រប និង ល័ក្ខខ័ណ្ឌនៃទំរង់តែប៉ុណ្ណោះ ហើយមិនអនុញ្ញាតិអោយពិនិត្យមើលថាតើស្រប និង ល័ក្ខខណ្ឌ

www.facebook.com/7khmer
fb : Entertainment And Knowledge

ផលប្រយោជន៍នៃបណ្តឹង ឬល័ក្ខខ័ណ្ឌបណ្តឹងផ្សេងទៀត ឬទេ ឬក៏ការទាមទារតាមផ្លូវបណ្តឹងនោះមានមូលហេតុត្រឹមត្រូវដែរ ឬទេ ។

ប្រសិនបើខ្វះចំនុច ដែលចាំបាច់ត្រូវសរសេរក្នុងពាក្យបណ្តឹង ឬពន្ធដាក់ពាក្យសុំមិនត្រូវបានបង់ ឬមានកង្វះជាអាទិ៍ តុលាការត្រូវចេញដីកាសំរេចបង្គាប់អោយធ្វើការកែតំរូវនូវចំណុចដែលខ្វះនោះដោយកំណត់អំឡុងពេលសមរម្យដើម្បីកែតំរូវ មាត្រា ៧៨កថាខ័ណ្ឌទី១ ។ តែបើដើមចោទមិនបានធ្វើការកែតំរូវក្នុងអំឡុងពេល ដែលបានកំណត់នោះទេ តុលាការត្រូវលើកចោលពាក្យបណ្តឹង ដោយដីកាសំរេចមាត្រា៧៨ កថាខ័ណ្ឌ ទី ២ ។ បើមិនពេញចិត្តនឹងដីកាសំរេចនេះដើមចោទអាចប្តឹងជំទាស់ទៅសាលាឧទ្ធរណ៍ ។ នៅពេលដែលដើមចោទបានធ្វើការកែតំរូវតាមការបង្គាប់ឱ្យធ្វើការកែតំរូវ តុលាការត្រូវបញ្ជូនពាក្យបណ្តឹងនោះទៅឱ្យចុងចំលើយហើយចាប់ផ្តើមការជំនុំជំរះ ។

## កថាភាគទី៣-កិច្ចការក្នុងការបញ្ជូនពាក្យបណ្តឹង

ក្រោយពីពិនិត្យពាក្យបណ្តឹង ប្រសិនបើតុលាការទទួលស្គាល់ថាពាក្យបណ្តឹងនោះត្រឹមត្រូវតាមទំរង់ ហើយទទួលពាក្យបណ្តឹងនោះ ក្រឡាបញ្ជី "មាត្រា២៤៦ កថាខ័ណ្ឌទី២" ត្រូវធ្វើការបញ្ជូនពាក្យបណ្តឹងនោះ ទៅឱ្យចុងចំលើយ"មាត្រា៧៩ កថាខ័ណ្ឌ ទី ១" ដោយហេតុថាការបញ្ជូនពាក្យបណ្តឹងនោះ គឺជាការផ្តល់ឱកាសឱ្យភាគីម្ខាងទៀតបានដឹងអំពីបណ្តឹងថា តើបុគ្គលណាជាអ្នកប្តឹងកម្មវត្ថុនៃបណ្តឹងជាអ្វី និង មធ្យោបាយតទល់របស់អ្នកប្តឹងនោះជាដើមហើយក៏ជាការផ្តល់ឱកាសឱ្យភាគីម្ខាងទៀតបានឆ្លើយដោះសារ និង រៀបចំមធ្យោបាយសំរាប់ការពារខ្លួនផងដែរ ។ ក្នុងករណីដែលពាក្យបណ្តឹងមិនអាចបញ្ជូនទៅបានទេ ។ ឧទាហរណ៍ក្នុងករណីដែលអាសយដ្ឋានរបស់ចុងចំលើយ ដែលដើមចោទផ្តល់ឱ្យនោះមិនមានភាពច្បាស់លាស់ ឬក្នុងករណី ដែលចុងចំលើយជាអសមត្ថជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ ឬក្នុងករណីដែលចុងចំលើយជាជនជាតិបរទេស ដែលមានអភ័យឯកសិទ្ធិ ហើយបដិសេធការទទួលការបញ្ជូនពាក្យបណ្តឹងនោះតុលាការត្រូវលើកបណ្តឹងចោលដោយដីកាសំរេច ។

តាមរយៈការបញ្ជូនពាក្យបណ្តឹងទៅចុងចំលើយ ចុងចំលើយក៏ក្លាយទៅជាប្រធាននៃនីតីវិធីនៃបណ្តឹងនោះហើយទំនាក់ទំនងគត្តិយុត្តរវាងភាគីទាំងបី គឺតុលាការ ចុងចំលើយ និងដើមចោទនឹងកើតមានឡើងពីពេលនោះ ។ ក្នុងន័យនេះការដាក់ពាក្យបណ្តឹងត្រូវសំរេច ដោយការបញ្ជូនពាក្យបណ្តឹងនោះទៅឲ្យចុងចំលើយ ។

www.facebook.com/7khmer
fb : Entertainment  And Knowledge

## ផ្នែកទី២៖ កិច្ចការក្រោយបញ្ជីក្នុងនីតិវិធីត្រៀមសំរាប់ការទាញហេតុផល

## កថាភាគទី១៖ គោលបំណងនៃនីតិវិធីត្រៀមសំរាប់ការទាញហេតុផល

នីតិវិធីត្រៀមសំរាប់ទាញហេតុផល គឺជានីតិវិធីរៀបចំនូវការអះអាងរបស់គូភាគី និង រៀបចំនូវចំណុចវិវាទនៃរឿងក្តី ព្រមទាំងរៀបចំនូវភស្តុតាងដែលពាក់ព័ន្ធនឹងចំណុចវិវាទ ដើម្បីឲ្យតុលាការធ្វើការពិនិត្យភស្តុតាងជាសម្ងហរិធី នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ មាត្រា ១០៣ ។

នីតិវិធីត្រៀមសំរាប់ការទាញហេតុផលនេះ ធ្វើឡើងក្នុងគោលបំណងដើម្បីកាត់បន្ថយនូវចំនុចវិវាទ ឬកុំអោយមានភាពស្មុគស្មាញលើចំណុចវិវាទ ដើម្បីជួយសំរួលដល់ការវិនិច្ឆ័យរឿងក្តីនៅក្នុងនីតីវិធីទាញហេតុផលដោយផ្ទាល់មាត់ឱ្យបានល្អិតល្អន់ ពីព្រោះថានៅពេលទាញហេតុផលដោយផ្ទាល់មាត់ភាគីនីមួយៗតែងតែលើកឡើងនូវអង្គហេតុផ្សេងៗ ដែលខ្លួនយល់ថាមានប្រយោជន៍សំរាប់ខ្លួន ដោយពុំគិតថាអង្គហេតុនោះមាន ឬគ្មានសារៈសំខាន់ចំពោះរឿងក្តីនោះទេ ។ ឯភាគីម្ខាងទៀតតែងតែតវ៉ាចំពោះការលើកឡើងនូវអង្គហេតុរបស់ភាគីម្ខាងទៀត ហើយតែងតែព្យាយាមដាក់ភស្តុតាងទាំងឡាយណា ដែលខ្លួនយល់ថាមានផលប្រយោជន៍សំរាប់ខ្លួនឯងការធ្វើបែបនេះនឹងនាំឱ្យការជំរះក្តីមានការស្មុគស្មាញ និង អូសបន្លាយពេលវេលាឥតប្រយោជន៍ ដែលធ្វើឱ្យមានការលំបាកក្នុងការស្វែងរកការពិត ។ ហេតុដូច្នេះហើយបានជាមុននឹងចាប់ផ្តើមធ្វើការទាញហេតុផលដោយផ្ទាល់មាត់ តុលាការត្រូវពិគ្រោះជាមួយភាគីទាំងសងខាងដើម្បីរៀបចំសេចក្តីអះអាងរបស់គូភាគី និង បំភ្លឺអំពីចំណុចវិវាទជាមុនសិន។ នៅក្រមរដ្ឋប្បវេណី ពុំបានកំណត់ថានីតិវិធីត្រៀមសំរាប់ទាញហេតុផលនេះ អាចធ្វើឡើងប៉ុន្មានដងនោះទេ ។ តុលាការ ត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសំរាប់ការទាញហេតុផលដំបូងក្នុងអំឡុងពេល ៣០ថ្ងៃ បន្ទាប់ពីថ្ងៃដែលពាក្យបណ្តឹងត្រូវបានដាក់"មាត្រា៨០ កថាខ័ណ្ឌទី២" ។ នីតីវិធីនេះ ត្រូវធ្វើឡើងនូវកាលបរិច្ឆេទ ដែលគូភាគីអាចចូលរួមបាននេះជាគោលការណ៍ចំពោះមុខដែលតុលាការត្រូតែគោរព"មាត្រា៣"ហើយមិនចាំបាច់បើកជាសាធារណៈទេ ប៉ុន្តែ តុលាការអាចអនុញ្ញាតិឱ្យ អ្នកដែលតុលាការយល់ឃើញថាសមរម្យចូលស្តាប់ជាអ្នកសង្កេតការណ៍បាន"មាត្រា១០៥នៃក្រមរដ្ឋប្បវេណី" ។

www.facebook.com/7khmer
fb : Entertainment And Knowledge

## កថាភាគទី ២ ៖ កំណត់ហេតុនៃនីតិវិធីត្រៀមសំរាប់ការទាញហេតុផល

នៅក្នុងកាលបរិច្ឆេទនីមួយៗតុលាការ ត្រូវបង្គាប់ឲ្យក្រឡាបញ្ជីធ្វើកំណត់ហេតុ ។ កំណត់ហេតុត្រូវចុះហត្ថលេខា ដោយប្រធាន និង ក្រឡាបញ្ជីដោយហេតុថាពួកគេជាអ្នកទទួលខុសត្រូវក្នុងការធ្វើកំណត់ហេតុនេះ ។

ចំនុចដែលត្រូវសរសេរ៖

- សញ្ញាណរឿងក្តី
- ឈ្មោះចៅក្រម និង ក្រឡាបញ្ជី
- ឈ្មោះ ភាគី អ្នកតំណាង អ្នកជំនួយការ និង អ្នកបកប្រែដែលបង្ហាញខ្លួន
- ពេល វេលា និង ទីកន្លែង ។

ទន្ទឹមនឹងនេះ ក៏ត្រូវកត់ត្រា ឲ្យបានច្បាស់លាស់ផងដែរនូវចំណុច៖

- ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ
- ចំលើយតបរបស់ចុងចំលើយចំពោះការទាមទារនោះ
- ខ្លឹមសារនៃអង្គហេតុដែលបានអះអាង និង ការស្នើសុំឲ្យពិនិត្យភស្តុតាង
- ការទទួលស្គាល់ ឬ មិនទទួលស្គាល់របស់ភាគីចំពោះអង្គហេតុដែលបានអះអាងដោយភាគីម្ខាងទៀត និង ការទទួលស្គាល់ ឬមិនទទួលស្គាល់ចំពោះ ភាពត្រឹមត្រូវនៃឯកសារ ។
- ការដកពាក្យបណ្តឹង ការផ្សះផ្សា ការលះបង់ការទាមទារ និង ការទទួលស្គាល់ការទាមទារ ។
- ចំនុចដែលតុលាការបានបង្គាប់ឲ្យកត់ត្រា និង
- ចំណុច ដែលតុលាការអនុញ្ញាតិឲ្យកត់ត្រាតាមការទាមទាររបស់ភាគី ។
- ការសំរេចសេចក្តីដែលបានធ្វើ នៅកាលបរិច្ឆេទនោះដោយមិនធ្វើជាលាយល័ក្ខណ៍អក្សរ ។

ដូច្នេះកំណត់ហេតុស្តីពីនីតិវិធីត្រៀមសំរាប់ការទាញហេតុ ត្រូវគោរពតាមមាត្រា ១០៩ មាត្រា ១១០ និងមាត្រា ១១១ ។

***សំគាល់៖*** កំណត់ហេតុមានសារៈសំខាន់ណាស់ នៅពេលដែលតុលាការថ្នាក់ខ្ពស់ធ្វើការពិនិត្យការជំនុំជម្រះនៅតុលាការដើម ។ នៅក្នុងកំណត់ហេតុនៃនីតិវិធីត្រៀមសំរាប់ការទាញផល ប្រធានក្រុមប្រឹក្សាជំនុំជម្រះ និង ក្រឡាបញ្ជីត្រូវចុះហត្ថលេខា ។ ក្នុងករណីដែលការជំនុំ

ជម្រះដោយចៅក្រមទោល ចៅក្រមនោះ ជាអ្នកចុះហត្ថលេខា ។ ក្រមនីតិវិធីរដ្ឋប្បវេណីថ្មីនេះ មិនតម្រូវឲ្យគូភាគីនៃបណ្តឹង អ្នកតំណាង អ្នកជំនួយការ ឬអ្នកបកប្រែចុះហត្ថលេខាទេ ។

## កថាភាគទី៣ ៖ កាលបរិច្ឆេទត្រៀមសំរាប់ការទាញហេតុផលលើកដំបូង

**១-ការសាកល្បងផ្សះផ្សា:**

នាពេលដំបូងនៃនីតីវិធីត្រៀមសំរាប់ការទាញហេតុផលតុលាការះ

១. ត្រូវសាកល្បងផ្សះផ្សាជាមុនសិន
២. ការសាកល្បងផ្សះផ្សានេះ មិនត្រឹមតែធ្វើ នៅក្នុងនីតិវិធីត្រៀមសំរាប់ការទាញហេតុផលប៉ុណ្ណោះទេ ប៉ុន្តែតុលាការ អាចធ្វើនៅគ្រប់ដំណាក់កាលទាំងអស់ ។
៣. ប្រសិនបើបានដឹងច្បាស់លាស់តាមអាកប្បកិរិយារបស់ភាគីថា ពុំមានឆន្ទះសះជាទេ ឬឃើញថាការផ្សះផ្សាមិនសមរម្យទេនោះ មិនចាំបាច់ធ្វើការផ្សះផ្សាទេ ។
៤. ក្នុងពេលផ្សះផ្សានេះ បើគូភាគីមានការសះជានឹងគ្នា ឬមានការលះបង់ការទាមទារ ឬការទទួលស្គាល់ការទាមទារនោះ តុលាការត្រូវកត់ត្រាក្នុងកំណត់ហេតុ ហើយកំណត់ហេតុមានអានុភាពដូចគ្នានឹងសាលក្រមស្ថាពរ "មាត្រា២២២" ។
៥. ក្នុងករណីមិនអនុវត្តតាមអាចប្តឹងទៅតុលាការអនុវត្តបាន ។

**២-ការអះអាងរបស់គូភាគី:**

**<u>២-១-ដើមចោទ៖</u>**

តុលាការត្រូវឲ្យដើមចោទធ្វើសេចក្តីថ្លែងការណ៍៖

- ដោយផ្ទាល់អំពីសាលក្រម ដែលទាមទារអំពីអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ ។
- អំពីអង្គហេតុដែលមូលហេតុនៃការទាមទារអំពីអង្គហេតុសំខាន់ៗក្នុងចំណោមអង្គហេតុដែលជាមូលហេតុនៃការទាមទារដែលមាននៅក្នុងពាក្យបណ្តឹង ។

**<u>២-២-ចុងចំលើយ៖</u>**

តុលាការត្រូវឲ្យចុងចំលើយ៖

www.facebook.com/7khmer
fb : Entertainment And Knowledge

- ធ្វើសេចក្ដីថ្លែងការណ៍ដោយផ្ទាល់មាត់ តបចំពោះខ្លឹមសារនៃសាលក្រម ដែលទាមទារដោយដើមចោទ ។

នៅក្នុងដំណាក់កាលនៃនីតីវិធីត្រៀមសំរាប់ការទាញហេតុផលនេះ រាល់ឯកសារត្រៀម និង ការបញ្ជាក់របស់គូភាគីពុំចាត់ទុកជាភស្តុតាងឡើយ ។ បុន្តែភាគីអាចស្នើរសុំឱ្យតុលាការពិនិត្យភស្តុតាងបានក្នុងពេលនេះភស្តុតាង ដែលអាចទទួលយកមកពិនិត្យបានមានតែភស្តុតាងជាឯកសារប៉ុណ្ណោះ ។

### ៣-សិទ្ធិបំភ្លឺរបស់តុលាការ:

សិទ្ធិបំភ្លឺនេះតុលាការអាចប្រើបាន បើយល់ឃើញថាការអះអាងរបស់ភាគីមិនច្បាស់លាស់ ឬក៏ការអះអាងការបញ្ជាក់ភស្តុតាងមិនគ្រប់គ្រាន់ ដែលធ្វើឱ្យតុលាការមិនអាចក្ដាប់បានអំពីអត្ថន័យ ។ ការប្រើសិទ្ធិបំភ្លឺនេះ គឺដើម្បីឱ្យចំនុចនៃអង្គហេតុ និង អង្គច្បាប់ដែលទាក់ទងនឹងបណ្ដឹងមានភាពច្បាស់លាស់តុលាការអាចសាកសួរភាគី ឬឱ្យភាគីអះអាង ឬបញ្ជាក់ភស្តុតាងចំពោះចំណុចនោះនៅកាលបរិច្ឆេទនៃនីតីវិធីត្រៀមសំរាប់ការទាញហេតុផល ឬការទាញហេតុផលដោយផ្ទាល់មាត់បានតាមមាត្រា"៩០កថាខ័ណ្ឌ ទី១ នៃក្រមរដ្ឋប្បវេណី" ។

### ៤-ការពិនិត្យភស្តុតាងជាឯកសារ:

ជាគោលការណ៍ការពិនិត្យភស្តុតាង អាចធ្វើឡើងតាមការស្នើសុំឱ្យពិនិត្យរបស់គូភាគីដែលមានចែងនៅមាត្រា១២៤ កថាខ័ណ្ឌ ទី ១នៃក្រមរដ្ឋប្បវេណី ដែលករណីនេះអាចធ្វើឡើងដោយផ្ទាល់មាត់ ឬជាលាយល័ក្ខណ៍អក្សរក៏បានដែរ ។ ការស្នើសុំឱ្យពិនិត្យភស្តុតាងនេះអាចធ្វើនៅមុនកាលបរិច្ឆេទនៃនីតីវិធីត្រៀមសំរាប់ការទាញហេតុផល ឬមុនកាលបរិច្ឆេទនៃនីតីវិធីទាញហេតុផលដោយផ្ទាល់មាត់បាន ដែលមានចែង នៅមាត្រា១២៥ កថាខ័ណ្ឌទី៣ ។ តុលាការអាចចេញដីកាសំរេចទាក់ទងនឹងការស្នើសុំឱ្យពិនិត្យភស្តុតាង ។ "ពាក្យដីកាសំរេច"នេះពុំតំរូវចាំបាច់ឱ្យសរសេរជាលាយល័ក្ខណ៍អក្សរទេ"មាត្រា២១៣" គឺអាចធ្វើដោយផ្ទាល់មាត់បានព្រោះគូភាគីមានវត្តមានទាំងអស់គ្នា តែត្រូវចុះក្នុងកំណត់ហេតុ ។ ចំពោះភស្តុតាងដែលអាចទទួលយកមកពិនិត្យក្នុងនីតីវិធីនេះបានគឺមានតែភស្តុតាងជាឯកសារក្នុងកំរិតចាំបាច់ដើម្បីរៀបចំចំនុចវិវាទ និង ភស្តុតាងប៉ុណ្ណោះ"មាត្រា១០៦" ចំពោះភស្តុតាងជាសាក្សីភាគីអាចស្នើសុំដាក់

នៅនីតិវិធីត្រៀមសំរាប់ការទាញហេតុផលនេះបាន ប៉ុន្តែច្បាប់មិនអនុញ្ញាតិឱ្យមានការសាកសួរសាក្សីក្នុងដំណាក់កាលនេះបានទេ ។ ម្យ៉ាងទៀតចំពោះអង្គហេតុ ដែលត្រូវបញ្ជាក់ដោយការពិនិត្យភស្តុតាងពេលទាញហេតុផលដោយផ្ទាល់មាត់ តុលាការត្រូវឱ្យគូភាគីស្នើសុំពិនិត្យភស្តុតាងនោះនៅក្នុងនីតិវិធីត្រៀមសំរាប់ការទាញហេតុផលភាគីពុំអាចដាក់មធ្យោបានតទល់ ឬការពារខ្លួនថ្មីបានទៀតទេ លើកលែងតែមានករណីពិសេស "មាត្រា១០៨" ។ មុននឹងបញ្ចប់នីតីវិធីត្រៀមសំរាប់ការទាញហេតុផល តុលាការ ត្រូវធ្វើការបញ្ជាក់ជាមួយភាគីនូវអង្គហេតុ ដែលនឹងត្រូវបំភ្លឺ នាពេលពិនិត្យភស្តុតាងនៅពេលក្រោយ"មាត្រា១០៧" ហើយតុលាការត្រូវធ្វើការកំណត់កាលបរិច្ឆេទនៃនីតិវីធីទាញហេតុផលដោយផ្ទាល់មាត់ ដែលនឹងប្រព្រឹត្តទៅនៅពេលណាដែលគូភាគីអាចចូលរួមបាន ហើយត្រូវកោះហៅគូភាគីមកចូលរួមតាមមាត្រា១១៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## ផ្នែកទី ៣៖ កិច្ចការនាពេលទាញហេតុផលដោយផ្ទាល់មាត់

### កថាភាគទី១ ៖ ភាពចាំបាច់នៃការទាញហេតុផលដោយផ្ទាល់មាត់

មុននឹងចេញសាលក្រមស្តីពីបណ្តឹង តុលាការចាំបាច់ ត្រូវឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីស្តាប់ការអះអាងដោយផ្ទាល់មាត់ ដោយផ្អែកលើគោលការណ៍ចំពោះមុខ និង គោលការណ៍នៃការជំនុំជម្រះក្តីជាសាធារណៈ (មាត្រា ១១៤ កថាខណ្ឌទី ១ ) ។ ជាគោលការណ៍ ការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវធ្វើឡើងនៅកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចមានវត្តមានបាន (មាត្រា១១៥កថាខណ្ឌទី ១ ) និង នៅសាលសវនាការជាសាធារណៈ(មាត្រា ១១៥ កថាខណ្ឌទី ២ វាក្យខណ្ឌទី ១ ) ។ ក្នុងករណីដែលភាពសាធារណៈបណ្តាលឲ្យខូចសណ្តាប់ធ្នាប់សាធារណៈ នោះតុលាការ អាចធ្វើការទាញហេតុផលដោយផ្ទាល់មាត់ជាអសាធារណៈបាន ដោយតុលាការត្រូវកត់ត្រាអំពីហេតុការណ៍នោះ ព្រមទាំងមូលហេតុនៅក្នុងកំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់ (មាត្រា ១១៥ កថាខណ្ឌទី ២ វាក្យខណ្ឌ ២ និង មាត្រា ១១៨ កថាខណ្ឌទី ១ ចំនុច ច) ។

### កថាភាគទី ២៖ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់លើកទី ១

#### ១-សេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសំរាប់ការទាញហេតុផល

នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ជាបឋម ៖

www.facebook.com/7khmer
fb : Entertainment  And Knowledge

១. ភាគី ត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ (មាត្រា ១១៦ កថាខណ្ឌទី ១ ) ។
២. ភាគីត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់អំពីចំណុចវិវាទ
៣. ភាគីត្រូវថ្លែងការណ៍សង្ខេបៈ
   a. អំពីអង្គហេតុដែលបានអះអាង
   b. អំពីភស្តុតាងដែលបានស្នើដាក់
   c. អំពីដីកាសម្រេចស្តីពីភស្តុតាងចេញដោយតុលាការ
   d. អំពីលទ្ធផលនៃការពិនិត្យភស្តុតាងជាឯកសារ
៤. ក្នុងករណីដែលភាគីទាំងសងខាងពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការធ្វើសេចក្តីថ្លែងការណ៍ទេ តុលាការអាចពន្យល់សង្ខេបអំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ ការទាញហេតុផល *ដោយសួរបញ្ជាក់ពីភាគីថា យល់ស្រប ឬទេ ហើយប្រសិនបើយល់ស្រប អាចបកស្រាយថា ភាគីទាំងសងខាងបានធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសំរាប់ការទាញហេតុបាន ។*

**សំគាល់ៈ**

១-ស្តីពីចំនុចវិវាទ និង អង្គហេតុ ដែលត្រូវបញ្ជាក់តាមរយៈការពិនិត្យភស្តុតាងវិញ ភាគីបានធ្វើដូចគ្នា នឹងការធ្វើនៅមុនពេលបញ្ចប់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដែរ ហើយនៅក្នុងកំណត់ហេតុ មានសរសេរយោងដែរ ។

២-ស្តីពីការស្នើដាក់ភស្តុតាង និង ការសម្រេចទទួល ឬមិនទទួលយក ព្រមទាំងលទ្ធផលនៃការពិនិត្យភស្តុតាងជាឯកសារវិញ គឺដូចគ្នា នឹងបញ្ជីភស្តុតាងជាឯកសារ និង បញ្ជីសាក្សី ជាអាទិ៍ ហេតុនេះ ហើយ ក្នុងកំណត់ហេតុ គេបានសរសេរយោងដែរ ។

### ២-សកម្មភាពបណ្តឹងដែលអាចធ្វើនៅពេលទាញហេតុផលដោយផ្ទាល់មាត់

នៅពេលទាញហេតុផលដោយផ្ទាល់មាត់ ជាគោលការណ៍ គេអាចធ្វើសកម្មភាពបណ្តឹងទាំងអស់បាន ដែលសកម្មភាពទាំងនោះរួមមានៈ

១. ភាគីអះអាងស្តីពីអង្គហេតុបាន (មាត្រា ១១៦ កថាខណ្ឌទី ៣)

www.facebook.com/7khmer
fb : Entertainment And Knowledge

២. ភាគីអាចដាក់ឯកសារត្រៀម និង សេចក្តីថ្លែងការណ៍ (មាត្រា ១០១ កថាខណ្ឌទី ១)
៣. ដីកាអាចស្នើដាក់ភស្តុតាង (មាត្រា ១១៦ កថាខណ្ឌទី ៣ )
៤. ដីកាសម្រេចស្តីពីការស្នើសុំដាក់ភស្តុតាង
៥. ការពិនិត្យភស្តុតាង
៦. ភាគីធ្វើការទាញហេតុផលចុងក្រោយ (មាត្រា ១១៦ កថាខណ្ឌទី ៥ )
៧. ការដកពាក្យបណ្តឹង ការសះជា ការបោះបង់នូវការទាមទារ ការទទួលស្គាល់ការទាមទារ និង ការសារភាព ជា អាទិ៍ ។

**កថាភាគទី៣៖ កំណត់ហេតុនៃការទាញហេតុផលដោយផ្ទាល់មាត់**

តុលាការត្រូវ ឲ្យក្រឡាបញ្ជីធ្វើកំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់ នៅគ្រប់កាលបរិច្ឆេទនីមួយៗ ។ កំណត់ហេតុត្រូវចុះហត្ថលេខាដោយប្រធាន និង ក្រឡាបញ្ជីដោយហេតុថាពួកគេជាអ្នកទទួលខុសត្រូវក្នុងការធ្វើកំណត់ហេតុនេះ ។

ចំនុចដែលត្រូវសរសេរ៖

- សញ្ញាណរឿងក្តី
- ឈ្មោះ ចៅក្រម និង ក្រឡាបញ្ជី
- ឈ្មោះ តំណាងអយ្យការ ដែលបានចូលរួម ប្រសិនបើមាន
- ឈ្មោះ ភាគី អ្នកតំណាង អ្នកជំនួយការ និង អ្នកបកប្រែដែលបានបង្ហាញខ្លួន
- ពេលវេលា និង ទីកន្លែងនៃការទាញហេតុផលដោយផ្ទាល់មាត់
- ហេតុការណ៍ដែលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ ឬហេតុការណ៍ និង មូលហេតុដែលមិនបានធ្វើជាសាធារណៈ ក្នុងករណីមិនធ្វើជាសាធារណៈ ។

នៅក្នុងកំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវកត់ត្រានូវសេចក្តីសង្ខេបអំពីការទាញហេតុផលនីមួយៗ ហើយជាពិសេស ត្រូវកត់ត្រាឲ្យបានច្បាស់លាស់នូវចំនុចដូចខាងក្រោម៖

- ការដកពាក្យបណ្តឹង
- ការផ្សះផ្សា
- ការលះបង់ការទាមទារ
- ការទទួលស្គាល់ការទាមទារ និង ការសារភាព
- សេចក្តីថ្លែងការណ៍របស់៖

o សាក្សី

o ភាគីផ្ទាល់ខ្លួន

o របស់អ្នកធ្វើកោសលវិច័យ

- ការធ្វើសម្បថ ឬមិនធ្វើសម្បថរបស់៖

o សាក្សី

o របស់ភាគីផ្ទាល់ខ្លួន

o របស់អ្នកធ្វើកោសលវិច័យ

o មូលហេតុដែលមិនបានឲ្យសាក្សី និងអ្នកធ្វើកោសលវិច័យធ្វើសម្បថ

- លទ្ធផលនៃការត្រួតពិនិត្យ
- ចំនុចដែលតុលាការបានបង្គាប់ឲ្យកត់ត្រា និង ចំណុចដែលតុលាការអនុញ្ញាតិឲ្យកត់ត្រាតាមការទាមទាររបស់ភាគី
- ការសំរេចសេចក្តីដែលបានធ្វើឡើង ដោយមិនបានធ្វើជាលាយលក្ខណ៍អក្សរ
- ការប្រកាសសេចក្តីសំរេច

ក្នុងករណីដែលបណ្តឹង ត្រូវបានបញ្ចប់ដោយមិនតាមការសំរេចសេចក្តីទេសេចក្តីថ្លែងការណ៍របស់សាក្សី របស់ភាគីផ្ទាល់ និង របស់អ្នកធ្វើកោសលវិច័យ និង លទ្ធផលនៃការពិនិត្យអាចមិនសរសេរក្នុងកំណត់ហេតុបានដោយទទួលការអនុញ្ញាតិពីតុលាការ ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយចំពោះករណីដែលភាគីទាមទារឲ្យកត់ត្រានៅក្នុងកំណត់ ក្នុងរយៈពេល ១ សប្តាហ៍ គិតពីថ្ងៃដែលខ្លួនបានដឹងថាបណ្តឹងនោះត្រូវបានបញ្ចប់ ។

**<u>គួរកត់សំគាល់៖</u>** ក្រៅពីប្រធានក្រុមប្រឹក្សាជំនុំជម្រះ និង ក្រឡាបញ្ជី មិនចាំបាច់ឲ្យអ្នកចូលផ្សេងទៀត ចុះហត្ថលេខា ឬផ្តឹមមេដៃនៅលើកំណត់ហេតុទាញហេតុផលដោយផ្ទាល់មាត់ទេ ។

### ១-សារៈសំខាន់នៃកំណត់ហេតុទាញហេតុផលដោយផ្ទាល់មាត់

សារៈសំខាន់នៃកំណត់ហេតុទាញហេតុផលដោយផ្ទាល់មាត់ មានលក្ខណៈប្រហាក់ប្រហែលគ្នានឹងសារៈសំខាន់នៃកំណត់ហេតុជំនុំជម្រះរឿងព្រហ្មទណ្ឌផងដែរ លើសពីនេះមានចំណុចសារធាតុ ជាច្រើននៃកំណត់ហេតុទាញហេតុផលដោយផ្ទាល់មាត់ ដែលតម្រូវឲ្យតុលាការយកមកធ្វើជាមូលដ្ឋានក្នុងការសម្រេចសេចក្តី និង មានចំណុចសារធាតុខ្លះទាក់ទង និងការបញ្ចប់បណ្តឹងតាមរយៈកំណត់ហេតុដែលទាំងនោះរួមមាន៖

**១-១-ចំណុចសារធាតុ ដែលជាមូលដ្ឋានក្នុងការសម្រេចសេចក្តី**

-ការលះបង់ការទាមទារ ការទទួលស្គាល់ការទាមទារ និង ការសារភាព តុលាការមិនចាំបាច់ពិនិត្យភស្តុតាងបន្ថែមទេ (មាត្រា១២៣ ចំណុច ខ)

-សាក្សី និង អ្នកជំនាញដែលមិនព្រមស្បថ តុលាការមិនអាចយកចំលើយ អ្នកទាំងអស់នោះ យកមកធ្វើជាភស្តុតាងបានទេ (មាត្រា ១៣៧)

-បើភាគីម្ខាងបានប្តឹងសុំ ហើយភាគីដែលត្រូវបានភាគីម្ខាងប្តឹងសុំនោះ មិនហ៊ានធ្វើសម្បថ តុលាការអាចទទួលស្គាល់ថាសេចក្តីអះអាងអំពីចំណុចសាកសួរភាគីម្ខាងទៀតជាការពិតបាន (មាត្រា ១៤០ ចំណុច ២) ។

**១-២-ចំណុចដែលទាក់ទងទៅការបញ្ចប់បណ្តឹងដោយកំណត់ហេតុ**

-ការដកពាក្យបណ្តឹង (មាត្រា ២២១ និង ២២២ )

-ការសះជា (មាត្រា ២២១ ២២២)

-ការលះបង់ ឬការទទួលស្គាល់ការទាមទារ (មាត្រា ២២១ ២២២)

**២-សុពលភាពនៃកំណត់ហេតុទាញហេតុផលដោយផ្ទាល់មាត់**

សុពលភាពនៃកំណត់ហេតុទាញហេតុផលដោយផ្ទាល់មាត់ មានលក្ខណៈដូចគ្នានឹងសុពលភាពនៃកំណត់ហេតុជំនុំជម្រះរឿងព្រហ្មទណ្ឌផងដែរ ។

ដូច្នេះ កំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវគោរពតាមមាត្រា ១១៧ មាត្រា ១១៨ និងមាត្រា ១១៩ ។

## កថាភាគទី ៤៖ ការពិនិត្យភស្តុតាងដោយសម្ងហវិធី

នៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់លើកដំបូង ដែលធ្វើឡើងបន្ទាប់ពីបានបញ្ចប់ការរៀបចំចំណុចវិវាទ និង ភស្តុតាងរួចហើយ តុលាការ ត្រូវធ្វើឲ្យការពិនិត្យភស្តុតាង អាចប្រព្រឹត្តទៅជាបន្ទាន់បាន (មាត្រា ១២៧ កថាខណ្ឌទី ១ ) ។ ការសាកសួរសាក្សីឬសាមីភាគី បើអាចធ្វើបាន ត្រូវធ្វើដោយសម្ងហវិធី (មាត្រា ១២៧ កថាខណ្ឌទី ២ ) ។ តាមរយៈការពិនិត្យភស្តុតាង ដោយសម្ងហវិធី តុលាការ នឹងអាចធ្វើការវិនិច្ឆ័យបានត្រឹមត្រូវ ហើយ បានលឿន ដោយផ្អែកលើជំនឿទុកចិត្តថ្មីៗ ។

www.facebook.com/7khmer
fb : Entertainment And Knowledge

**១-ការសាកសួរសាក្សីៈ**

តួនាទីសំខាន់របស់តុលាការ ក្នុងការសាកសួរសាក្សីនៃគោលការណ៍ភាគី គឺមិនទទួលទាំងបង្ខំចិត្តនូវចំលើយរបស់សាក្សី ថាជាការពិត ។ តុលាការ ត្រូវធ្វើការវិនិច្ឆ័យដោយពិចារណាថា តើចំលើយរបស់សាក្សី នោះ ពិត ឬមិនពិត លើចំលើយដែលមានលាយឡំគ្នាទាំង ចំលើយពិត និង មិនពិត ។ ចំណុចពិសេសនៃការសាកសួរសាក្សី គឺឲ្យសាក្សីធ្វើសេចក្តីថ្លែងការណ៍ នូវអង្គហេតុដែលខ្លួនបានដឹង តាមការពិសោធន៍របស់ខ្លួនចំពោះមុខតុលាការ ហើយចំលើយរបស់សាក្សី គឺជាភស្តុតាង ។ ការធ្វើឲ្យសាក្សីបញ្ចេញពាក្យសំដីដើម្បីប្រាប់ដល់ចៅក្រម គឺជាតួនាទីមួយសំខាន់ណាស់របស់ចៅក្រមក្នុងការរកឃើញនូវការពិតពីសាក្សី ។

**នីតិវិធីសួរសាក្សីមានដូចតទៅៈ**

១. **សួរអំពីអត្តសញ្ញាណរបស់សាក្សីៈ** ត្រូវសួរនូវៈ
   a. សួរ ឈ្មោះ ថ្ងៃ ខែ ឆ្នាំ កំណើត
   b. អាសយដ្ឋាន
   c. មុខរបរជាដើម ។

២. **សម្បថ** ( មាត្រា ១៣៧ )
   a. សាក្សី ត្រូវតែធ្វើសម្បថមុនពេលសាកសួរ លើកលែងមាត្រា ១៣៧ -២[២]
   b. សម្បថ ត្រូវដឹកនាំដោយក្រឡាបញ្ជី[៣]
   c. ត្រូវធ្វើនៅចំពោះមុនវត្តុសក្តិសិទ្ធិនៃតុលាការនីមួយៗ
   d. ក្រោយពីធ្វើសម្បថ ក្រឡាបញ្ជី ត្រូវធ្វើកំណត់សម្បថ

៣. **ការកម្រិតការសាកសួរ**
   a. ត្រូវធ្វើជាច់ដោយឡែក និង ច្បាស់លាស់ (មាត្រា ១៣៩ កថាខណ្ឌទី ១)
   b. មិនត្រូវសួរសំណួរនាំមុខឡើយ
   c. សំណួរ ច្រំដែល

---

[២] - លើកលែង ជនដែលមានអាយុក្រោម ១៦ ឆ្នាំ ឬ ជនដែលមិនយល់អំពីអត្ថន័យនៃសម្បថ តុលាការមិនឲ្យធ្វើសម្បថទេ ។

[៣] -ត្រូវអុជទៀន ធូប ក្រឡាបញ្ជីត្រូវអានប្រារព្វវាទខ្លាំងៗ និង អាចពាក្យសច្ចាប្រណិធាន ឲ្យអ្នកស្បថថាតាម ។

www.facebook.com/7khmer
fb : Entertainment And Knowledge

d. សំណួរដែលគ្មានទំនាក់ទំនងនឹងចំណុចវិវាទ

e. សំណួរដែលប្រមាថមើលងាយ ឬធ្វើឲ្យច្របូកច្របល់ដល់សាក្សី ។ ល ។

**២-ការសាកសួរសាមីភាគី**

ជាគោលការណ៍ នីតិវិធីនៃការសាកសួរសាមីភាគី ក៏ដូចនឹងនីតិវិធីនៃការសាកសួរសាក្សីដែរ គឺត្រូវអនុវត្ត តាមបញ្ញត្តិស្តីពីការសាកសួរសាក្សី (មាត្រា ១៩១ កថាខណ្ឌទី ១ )។

១. សួរ អត្តសញ្ញាណរបស់ភាគី
២. តុលាការអាចឲ្យសាមីភាគីធ្វើសម្បថ ឬមិនធ្វើសម្បថ
៣. បើ តុលាការឲ្យធ្វើសម្បថ ត្រូវពន្យល់ពីគោលបំណងនៃការធ្វើសម្បថ និងការផ្តន្ទាទោសអំពីការផ្តល់នូវការក្លែងបន្លំសេចក្តីថ្លែងការណ៍ ព្រមទាំងធ្វើកំណត់ហេតុសម្បថ ។
៤. មិនត្រូវឲ្យសាមីភាគីចេញពីសាលសវនាការទេ
៥. ភាគី ត្រូវធ្វើសេចក្តីថ្លែងការណ៍នៃនីតិវិធីត្រៀមសំរាប់ការទាញហេតុផល

**៣-កោសលវិច័យ**

កោសលវិច័យគឺជាភស្តុតាង ដែលបង្គាប់ឲ្យតតិយជន ដែលមានឯកទេស បច្ចេកទេស និង ចំណេះដឹងផ្សេងៗ ឲ្យធ្វើការវិនិច្ឆ័យនូវចំណុចណាមួយ ដោយផ្អែកលើឯកទេស បច្ចេកទេស និង ចំណេះដឹងនោះ ។ កោសលវិច័យ គឺជាការពិនិត្យភស្តុតាងមួយប្រភេទ ហើយជាគោលការណ៍ត្រូវធ្វើឡើង ដោយការស្នើសុំពីភាគី ដូចភស្តុតាងដទៃទៀត ដែរ ប៉ុន្តែក្នុងករណីដែលទទួលស្គាល់ថាមានការចាំបាច់ តុលាការអាចបង្គាប់ឲ្យធ្វើកោសល្យវិច័យ បាន ។

មុននឹងកំណត់នូវចំណុច ដែលត្រូវធ្វើកោសលវិច័យ ដោយផ្អែកលើការទាមទាររបស់ភាគីម្ខាង តុលាការ ត្រូវផ្តល់ឱកាសម្ខាងទៀតបញ្ចេញមតិរបស់ខ្លួន ។ អ្នកធ្វើកោសលវិច័យ គឺជាសាក្សីផង ព្រមជាមួយគ្នានេះ គឺជាអ្នកជំនួយការរបស់តុលាការផង ។ តុលាការជាអ្នកជ្រើសតាំងអ្នកធ្វើកោសលវិច័យហើយការជ្រើសតាំងនេះ ត្រូវធ្វើដោយសមភាព ដោយផ្អែកលើមាត្រា ១៩៤ កថាខណ្ឌទី ៣ និង មាត្រា ១៩៥ ។

www.facebook.com/7khmer
fb : Entertainment And Knowledge

### ៤-ការត្រួតពិនិត្យ

ការត្រួតពិនិត្យ គឺជាការពិនិត្យភស្តុតាង ដើម្បីទទួលបាននូវធនធានភស្តុតាង ដោយការត្រួតពិនិត្យនូវភិនភាគ ឬលក្ខណៈនៃវត្ថុដោយផ្ទាល់ ដោយចៅក្រម ដោយប្រើវិញ្ញាណប្រាំរបស់ខ្លួន (មាត្រា ១៦១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ) ។

## កថាភាគទី ៥៖ ការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់

ក្នុងករណី យល់ឃើញថា ត្រូវបញ្ចប់ការវិនិច្ឆ័យ ដោយផ្អែកលើលទ្ធផលនៃការទាញហេតុ និង ការពិនិត្យភស្តុតាង តុលាការត្រូវបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ហើយចេញសាលក្រមចុងក្រោយ(មាត្រា ១៨០ កថាខណ្ឌទី ១) ។ តុលាការត្រូវធ្វើការវិនិច្ឆ័យនូវភាពត្រឹមត្រូវនៃការទាមទារ ដោយផ្អែកលើស្ថានភាពនៃការអះអាង និង បញ្ជាក់ភស្តុតាងនៅពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ។ ហេតុនេះ ហើយអាជ្ញាអស់ជំនុំនៃការវិនិច្ឆ័យ ត្រូវកំណត់ជាស្ថាពរនូវសិទ្ធិ ឬទំនាក់ទំនងគត្តិយុត្តិនៅពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ (មាត្រា ១៩៤ កថាខណ្ឌទី ២) ។ ដូច្នេះ នៅក្នុងលិខិតសាលក្រម ត្រូវសរសេរ ថ្ងៃ ខែ ឆ្នាំ ដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ (មាត្រា ១៨៩ កថាខណ្ឌទី ១ ចំណុច ខ) ។

## ផ្នែកទី ៤៖ សាលក្រមក្នុងរឿងរដ្ឋប្បវេណី

## កថាភាគទី១៖ និយមន័យ៖

សាលក្រម គឺជាការសំរេចសេចក្តី ដែលតុលាការធ្វើលិខិតសាលក្រមដែលមានលក្ខណៈគ្រប់គ្រាន់ទៅតាមទំរង់ ដែលច្បាប់បានកំណត់ដោយផ្អែកលើការទាញហេតុផលដោយផ្ទាល់មាត់ លើកលែងក្នុងករណី ដែលមានកំណត់ពិសេសនៅក្នុងសាលក្រមនេះ ឬនៅក្នុងច្បាប់ផ្សេងទៀតហើយកើតមានអានុភាព ដោយការប្រកាស ដោយផ្អែកលើលិខិតសាលក្រមនោះ ។ ចំណុចនេះមានន័យថាចំពោះបណ្តឹងធម្មតាជាគោលការការវិនិច្ឆ័យទៅលើពាក្យបណ្តឹងថាមានលក្ខណៈគ្រប់គ្រាន់ ហើយត្រឹមត្រូវទៅតាមច្បាប់កំណត់ ឬមិនត្រឹមត្រូវតាមច្បាប់កំណត់ ឬក៏ការវិនិច្ឆ័យទៅលើការទាមទារក្នុងពាក្យបណ្តឹងថាមានលក្ខណៈត្រឹមត្រូវទៅតាមច្បាប់ ឬ មិនត្រឹមត្រូវគឺត្រូវធ្វើដោយសាលក្រម ។

**កថាភាគទី២៖ ប្រភេទសាលក្រមក្នុងរដ្ឋប្បវេណី៖** មានបីប្រភេទ៖

### ១-សាលក្រមចុងក្រោយ

សាលក្រមចុងក្រោយ គឺជាបញ្ចប់ការវិនិច្ឆ័យ ដោយផ្អែកទៅលើលទ្ធផល ដែលបានមកពីការទាញហេតុផលដោយផ្ទាល់មាត់ និង ការពិនិត្យភស្តុតាង ។ សាលក្រមចុងក្រោយនេះ

www.facebook.com/7khmer
fb : Entertainment And Knowledge

តុលាការបើកសិទ្ធិឲ្យគូភាគីនៃរឿងក្ដីប្ដឹងឧទ្ធរណ៍ ទៅតុលាការជាន់ខ្ពស់បាន កាលណាមិនពេញចិត្តនឹងសេចក្ដីសំរេចរបស់ខ្លួន(មាត្រា២៦០) ។ ប្រភេទនៃសាលក្រមចុងក្រោយនេះមាន៖

១. សាលក្រមលើកពាក្យបណ្ដឹងចោល

២. សាលក្រមច្រានចោលការទាមទារ

៣. សាលក្រមទទួលស្គាល់ការទាមទារ

៤. សាលក្រមទទួលស្គាល់ការទាមទារមួយផ្នែក

៥. សាលក្រមច្រានចោលការទាមទារមួយផ្នែកជាដើម ។

**២-សាលក្រមរបៀប៖**

សាលក្រមរបៀប គឺជាសាលក្រម ដែលគ្មានអានុភាពបញ្ចប់បណ្ដឹងទេហើយដែលសំរេចសេចក្ដីចំពោះចំណុចដែលជាបុរេលក្ខខ័ណ្ឌសំរាប់ការចេញសាលក្រមចុងក្រោយ។

**២-១-ចំពោះបណ្ដឹងដែលតុលាការបញ្ចប់វិនិច្ឆ័យដោយចេញសាលក្រមរបៀបមានដូចតទៅ៖**

- *អត្ថិភាពនៃការទាមទារក្នុងករណីដែលមានវិវាទលើអត្ថិភាព និង ចំនួនទឹកប្រាក់ទាមទារ*

បានន័យថាប្រសិនបើតុលាការវិនិច្ឆ័យទាំងមូលហេតុនៃការទាមទារ និង ចំនួនទឹកប្រាក់ហើយការវិនិច្ឆ័យនោះ ត្រូវបានសន្និដ្ឋានថាការទាមទារគ្មានមូលហេតុត្រឹមត្រូវវិញ នោះវាបណ្ដាលឲ្យការវិនិច្ឆ័យអំពីចំនួនទឹកប្រាក់នោះត្រូវអាសាបង់ ។

- *មធ្យោបាយតទល់ ឬការពារខ្លួនដែលអាចវិនិច្ឆ័យដោយឯករាជ្យ៖*

បានន័យថាអាចបង្កើត ផ្លាស់ប្ដូរ ឬរំលត់នូវទំនាក់ទំនង ដោយស្វ័យប្រវត្តិជាមុនសិន ។

- *អត្ថិភាព ឬនត្ថិភាពនៃល័ក្ខខ័ណ្ឌបណ្ដឹង៖*

បានសេចក្ដីថាបើមានវិវាទទៅលើល័ក្ខខ័ណ្ឌនៃបណ្ដឹង ដូចជា អត្ថិភាព ឬនត្ថិភាពនៃសិទ្ធិជំរះក្ដីរបស់តុលាការកម្ពុជា ឬសមត្ថកិច្ចរបស់ភាគីថាមាន ឬគ្មាន ឬការបញ្ជូនពាក្យបណ្ដឹង នោះមានសុពលភាព ឬគ្មានសុពលភាព តុលាការអាចចេញសាលក្រមរបៀបចំពោះអត្ថិភាពនៃល័ក្ខខ័ណ្ឌបណ្ដឹងនោះបាន ។ ផ្ទុយទៅវិញ បើតុលាការវិនិច្ឆ័យទៅលើល័ក្ខខ័ណ្ឌនៃបណ្ដឹងថា គ្មានអត្ថិភាពទេ តុលាការនឹងចេញសាលក្រមចុងក្រោយលើកចោលនូវពាក្យបណ្ដឹងនោះ ។

- *ហេតុដែលទាក់ទងនឹងការបញ្ចប់បណ្ដឹង៖*

បានន័យថា បើមានវិវាទទៅលើសុពលភាពនៃពាក្យបណ្ដឹង ឬមោឃភាពនៃការដកពាក្យបណ្ដឹងការផ្សះផ្សាលើបណ្ដឹងការទទួលស្គាល់ការទាមទារ ឬការលះបង់ការទាមទារជាដើម តុលាការអាចបន្តបណ្ដឹងនោះបាន ដោយចេញសាលក្រមរបៀបថា វាមោឃភាព ។ ផ្ទុយ

www.facebook.com/7khmer
fb : Entertainment  And Knowledge

ទៅវិញ ប្រសិនបើតុលាការវិនិច្ឆ័យថាមានសុពលភាពតុលាការ នឹងប្រកាសបញ្ចប់បណ្ដឹងនោះ ដោយចេញសាលក្រមចុងក្រោយ ។

**៣-សាលក្រមកំបាំងមុខ៖**

សាលក្រមកំបាំងមុខដើមចោទ ។ សាលក្រមកំបាំងមុខដើមចោទ គឺជាសាលក្រម ដែលវិនិច្ឆ័យចំពោះការអវត្តមានរបស់ដើមចោទ ដែលមិនបានចូលរួមក្នុងកាលបរិច្ឆេទនីតិវិធី របស់តុលាការ ។ ការអវត្តមាននេះតុលាការសន្មត់ថាដើមចោទគ្មានឆន្ទះក្នុងការធ្វើ ទៅតាម នីតិវិធីនៃបណ្ដឹង ។ នៅក្នុងសាលក្រមកំបាំងមុខនេះរួមមាន ២ ប្រភេទ៖

**<u>៣-១-សាលក្រមកំបាំងមុខចំពោះដើមចោទ</u>**

តុលាការអាចចេញសាលក្រមកំបាំងមុខដើមចោទក្នុងករណីដូចខាងក្រោម៖

- ដើមចោទមិនបង្ហាញខ្លួន នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសំរាប់ការទាញហេតុផល លើកទី១៖
    - ត្រូវប្រានចោល នូវការទាមទាររបស់ដើមចោទ ដោយសាលក្រមកំបាំងមុខ
- ដើមចោទមិនបង្ហាញខ្លួន នៅកាលបរិច្ឆេទ នៃការទាញហេតុផលដោយផ្ទាល់មាត់
    - ត្រូវប្រានចោល នូវការទាមទាររបស់ដើមចោទ ដោយសាលក្រមកំបាំងមុខ
- ករណីដែលមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញ ហេតុផលបន្ត៖
    - អាចបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ហើយកំណត់កាល បរិច្ឆេទនៃការទាញហេតុផលលើកទី ១ បាន
    - អាចបន្តនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបាន

**<u>៣-២-សាលក្រមកំបាំងមុខចំពោះចុងចំលើយ៖</u>**

សាលក្រមកំបាំងមុខចំពោះចុងចំលើយ គឺជាសាលក្រមដែលចេញដោយតុលាការក្នុង ករណីដែលចុងចំលើយមិនបានចូលរួមក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ។

- ក្នុងករណី ដែលមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការ ទាញហេតុផលលើកទី ១ (មាត្រា ២០១ កថាខណ្ឌទី ១ )៖
    - ត្រូវ បញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ហើយកំណត់កាលបរិច្ឆេទ នៃការទាញហេតុផលដោយផ្ទាល់មាត់ លើកទី ១ ។
- ក្នុងករណី ដែលមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយ ផ្ទាល់មាត់ (មាត្រា ២០១ កថាខណ្ឌទី២)៖

- o ត្រូវចាត់ទុកថា ចុងចំលើយបានសារភាព តាមសេចក្តីថ្លែងការណ៍របស់ដើមចោទ
- o បើសិនជាការទាមទាររបស់ដើមចោទ មានហេតុផលត្រឹមត្រូវតាមសេចក្តីថ្លែងការណ៍នេះ ត្រូវទទួលស្គាល់ការទាមទាររបស់ដើមចោទតាមរយៈសាលក្រមកំបាំងមុខ ។
- o បើសិន ជាការទាមទាររបស់ដើមចោទ ពុំមានហេតុផលត្រឹមត្រូវតាមសេចក្តីថ្លែងការណ៍នេះទេ ត្រូវចេញសាលក្រមច្រានចោលនូវការទាមទាររបស់ដើមចោទ ។

- ក្នុងករណី ដែលមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទត្រៀមសម្រាប់ការទាញហេតុផលបន្ត ៖
  - o បើមិនអាចរៀបចំចំណុចវិវាទតទៅទៀតបានទេ ត្រូវបញ្ចប់កាលបរិច្ឆេទត្រៀមសំរាប់ការទាញហេតុផល ហើយកំណត់កាលបរិច្ឆេទនៃការទាញហេតុដោយផ្ទាល់មាត់លើកទី ១ តាមធម្មតា ដូចដែលមានចែងក្នុងមាត្រា ២០១ -១ដែរ ។

**<u>៣-៣-ករណីដែលភាគីទាំងសងខាងអវត្តមាន៖</u>**

ត្រូវអនុវត្តតាមមាត្រា ២១៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលមាន៖

- ក្នុងករណី ដែលភាគីទាំងសងខាងមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ។
- មិនបានដាក់ពាក្យសុំ ឲ្យតុលាការកំណត់កាលបរិច្ឆេទជាថ្មីទៀត ក្នុងអំឡុងពេល ១ ខែទេ នោះត្រូវចាត់ទុកថា បានដកពាក្យបណ្តឹង ។
- ក្នុងករណីដែលភាគីទាំងសងខាងមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ពីរដងជាប់គ្នា ក៏ត្រូវចាត់ទុក ថាបានដកពាក្យបណ្តឹងដែរ ។

**ករណីដែលតុលាការមិនអាចចេញសាលក្រមកំបាំងមុខបានមាន៖**

- *ភាគីដែលមិនបង្ហាញខ្លួនដោយមិនបានទទួលការកោះហៅស្របច្បាប់៖*

ចំណុចនេះមានចែងដោយផ្អែកលើមាត្រា៣ស្តីពីសិទ្ធិទាមទារឲ្យសាកសួរគោលការណ៍ចំពោះមុខ ។ នៅក្នុងរឿងក្តីរដ្ឋប្បវេណី ភាគីនៃបណ្តឹងអាចទទួលឥទ្ធិពលដល់សិទ្ធិរបស់ខ្លួនដោយអានុភាពនៃសេចក្តីសំរេចរបស់តុលាការ ដែលខ្លួនដាក់ពាក្យបណ្តឹង ។ ហេតុដូច្នេះជាគោលការណ៍ភាគីនៃរឿងក្តី ត្រូវទទួលបាននូវឱកាសបញ្ចេញមតិអំពីចំណុច ដែលត្រូវវិនិច្ឆ័យ

ដោយតុលាការក្នុងបណ្ដឹងនោះ ហើយស្ដាប់មតិដែលថ្លែងដោយភាគីម្ខាងទៀតមុនពេលតុលាការចេញសេចក្ដីសំរេច ។

- *ភាគីដែលមិនបង្ហាញខ្លួនមានមូលហេតុ ដែលអាចទទួលស្គាល់ថាពិតជាមិនអាចបង្ហាញខ្លួនបានមែនដោយគ្រោះមហន្តរាយធម្មជាតិ ឬកាលៈទេសៈសផ្សេងទៀតដែលមិនអាចជៀសវាងបាន ។*
- *បណ្ដឹងមិនស្របច្បាប់ ។*
- *ខ្លឹមសារនៃសេចក្ដីថ្លែងការណ៍ ដែលដើមចោទ ធ្វើនៅកាលបរិច្ឆេទទាញហេតុផលដោយផ្ទាល់មាត់ ដែលចុងចំលើយមិនបានបង្ហាញខ្លួន ហើយខ្លឹមសារនៃសេចក្ដីថ្លែងការណ៍នោះ មិនបានជូនដំណឹងដល់ចុងចំលើយ មុនកាលបរិច្ឆេទ ។*

**កថាភាគទី៣៖ ចំណុចសំខាន់ៗ ដែលត្រូវសរសេរក្នុងលិខិតសាលក្រម៖**

ភាគីធ្វើបណ្ដឹងរដ្ឋប្បវេណី គឺមានគោលបំណងឲ្យតុលាការដោះស្រាយបណ្ដឹងរបស់ខ្លួនតាមរយៈការកំណត់ជាស្ថាពរដោយតុលាការនូវអត្ថិភាព ឬនត្ថិភាពនៃការទាមទារ ដែលលើកឡើងជាកម្មវត្ថុ ដើម្បីឲ្យវិនិច្ឆ័យក្នុងពាក្យបណ្ដឹងនោះ ។ សាលក្រមរដ្ឋប្បវេណី គឺជាលិខិតតួបករណ៍មួយ ដែលតុលាការប្រើប្រាស់សំរាប់ធ្វើការបង្ហាញចំលើយស្ដីពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិទាមទារ ។

**១-និទ្ទេស ដែលត្រូវសរសេរក្នុងលិខិតសាលក្រមរដ្ឋប្បវេណី ៖**

១. ឈ្មោះតុលាការ ដែលចេញសាលក្រម

២. ថ្ងៃ ដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់

៣. ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិងឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់

៤. អង្គហេតុ និង ចំនុចវិវាទ ចំនុចនេះ ចៅក្រម ត្រូវសរសេរពីខ្លឹមសរនៃសាលក្រម ដែលទាមទារដោយដើមចោទ និង ចុងចំលើយតបចំពោះការទាមទាររបស់ដើមចោទបន្ទាប់មក ចៅក្រម ត្រូវសរសេរពីសិទ្ធិគត្តិយុត្តិ ដែលជាមូលហេតុនៃសាលក្រម ដែលទាមទារដោយ ដើមចោទ ព្រមទាំងអង្គហេតុ ដែលជាមូលហេតុនៃការកើតឡើងនៃសិទ្ធិ ។

លើសពីនេះក្នុងករណីដែលចុង ចំលើយបានអះអាងអំពីមូលហេតុរារាំងនូវកំណើត ឬរលាយសិទ្ធិដែលអះអាងដោយដើមចោទ ចៅក្រម ត្រូវសរសេរអង្គហេតុនោះ ហើយក៏ត្រូវសរសេរអំពីការទទួលស្គាល់ ឬមិនទទួលស្គាល់នូវអង្គហេតុទាំងនោះដោយដើមចោទផង ។

៥. សំអាងហេតុ (មូលហេតុ ឬការយល់ឃើញ) ចំនុចនេះ ចៅក្រមត្រូវសរសេរ

អំពីការវិនិច្ឆ័យទៅលើភស្តុតាងស្តីពីអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុចាំបាច់សំរាប់ធ្វើការវិនិច្ឆ័យ អំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិទាមទារ ដោយផ្អែកលើអង្គហេតុ ដែលបានទទួលស្គាល់ដើម្បីទាញនូវលទ្ធផលក្នុងសេចក្តីសំរេចបញ្ចប់ ។

៦. សេចក្តីសំរេចបញ្ចប់ចំណុចនេះ មានន័យថា ចៅក្រម ត្រូវធ្វើសេចក្តីសំរេចជាចុងក្រោយស្តីពីការទទួលស្គាល់ ឬមិនទទួលស្គាល់ការទាមទាររបស់ដើមចោទ ។

ចៅក្រម ដែលចេញសាលក្រម ត្រូវចុះហត្ថលេខាលើលិខិតសាលក្រមនោះ ។ ក្នុងករណី ដែលចៅក្រមណាម្នាក់ក្នុងចំណោមក្រុមប្រឹក្សាជំនុំជំរះមានធុរៈមិនបានចុះហត្ថលេខាលើលិខិតសាលក្រម ចៅក្រមផ្សេងទៀត ត្រូវចុះហត្ថលេខាដោយចុះនិទ្ទេសអំពីហេតុដែលចៅក្រមនោះមិនអាចចុះហត្ថលេខាបាន ។ ចំណុចដែលបានរៀបរាប់ខាងលើ គឺជាចំណុចចាំបាច់សរសេរក្នុងលិខិតសាលក្រម ហើយក្រៅពីចំណុចទាំងអស់នេះ តុលាការអាចសរសេរចំណុចផ្សេងទៀតដូចជា លេខសំណុំរឿងលេខសាលក្រម ប្រភេទនៃសាលក្រម ជាដើម ។

**២-ចំណុចសំខាន់ៗ ដែលត្រូវវិនិច្ឆ័យដោយសាលក្រម**

ចំណុច ដែលត្រូវវិនិច្ឆ័យដោយចេញសាលក្រម មានដូចខាងក្រោម៖

- *តុលាការត្រូវចេញសាលក្រម ចំពោះការទាមទារទាំងអស់ ដែលភាគីបានសុំ* បានសេចក្តីថា រាល់ការទាមទាររបស់ភាគីតុលាការ ត្រូវសំរេចទាំងអស់មិនឲ្យលើសនិងមិនឲ្យខ្វះការទាមទារឡើយ ។
- *តុលាការ មិនអាចចេញសាលក្រមចំពោះចំណុចណា ដែលភាគីមិនបានសុំឡើយ* ចំណុចនេះ បានន័យថា ជាគោលការណ៍ចំណុច ដែលភាគីសុំ និង ចំណុចនៃសាលក្រមរបស់តុលាការ ត្រូវតែមានភាពដូចគ្នា ហើយម្យ៉ាងទៀតមានអត្ថន័យបញ្ជាក់ច្បាស់លាស់អំពីគោលការណ៍នៃសិទ្ធិចាត់ចែងថា" គ្មានពាក្យបណ្តឹងគ្មានការសំរេចសេចក្តី" ។ ក្នុងករណីដែលតុលាការខកខានមិនបានធ្វើការវិនិច្ឆ័យលើការទាមទារផ្នែកណាមួយ ដែលយើងហៅថា" ការខកខានវិនិច្ឆ័យ" ដែលខកខាននោះ ត្រូវបានចាត់ការបន្តនៅតុលាការនោះតទៅទៀត ។ ហេតុដូច្នេះ កាលណាតុលាការធ្វើការវិនិច្ឆ័យ ដោយចេញសាលក្រមទៅលើផ្នែក ដែលត្រូវបានខកខាននោះ ទើបការចាត់ការបណ្តឹងត្រូវបានបញ្ចប់ ។ សាលក្រមដែលវិនិច្ឆ័យជាក្រោយលើផ្នែក ដែលត្រូវខកខាននោះ គេឲ្យឈ្មោះថា "សាលក្រមបន្ថែម" ។
- *តុលាការ ត្រូវសំរេចសេចក្តីអំពីករណីទទួលបន្ទុកប្រាក់ប្រដាប់ក្តី* ទោះបីជាគ្មាន

www.facebook.com/7khmer
fb : Entertainment And Knowledge

ពាក្យសុំរបស់ភាគីក៏ដោយ បានន័យថាតុលាការ ត្រូវសំរេចសេចក្តីអំពីករណីយកិច្ចទទួលបន្ទុកប្រាក់ប្រដាប់ក្តី ដោយមិនចាំបាច់មានពាក្យសុំរបស់ភាគី ដោយផ្អែកតាមជំពូកស្តីពីប្រាក់ប្រដាប់ក្តីដែលច្បាប់តំរូវឲ្យភាគីចាញ់ក្តីជាអ្នកទទួលបន្ទុក ។

- *ក្នុងការចេញសាលក្រម តុលាការ ត្រូវវិនិច្ឆ័យទទួលស្គាល់ ឬមិនទទួលស្គាល់*

ថាការអះអាងអំពីអង្គហេតុមាន ឬគ្មានភាពពិតដោយគិតពិចារណាយ៉ាងហ្មត់ចត់នូវលទ្ធផលនៃការពិនិត្យភស្តុតាង និង ដំណើការ និង ខ្លឹមសារនៃការទាញហេតុផលដោយផ្ទាល់មាត់តាមជំនឿទុកចិត្តដោយសេរីរបស់ខ្លួន ។ គោលការណ៍ជំនឿទុកចិត្តដោយសេរី គឺជាគោលការណ៍ដែលចៅក្រមវិនិច្ឆ័យ ទៅលើពាក្យបណ្តឹង ដែលភាគីបានដាក់ដោយសេរី ហើយចៅក្រមអាចទទួលស្គាល់អង្គហេតុ ដែលជាមូលដ្ឋាននៃសាលក្រម ដោយផ្អែកលើជំនឿទុកចិត្តរបស់ខ្លួន ។ គោលការណ៍មួយទៀតដែលផ្ទុយ នឹងគោលការណ៍ជំនឿទុកចិត្តិដោយសេរី គឺគោលការណ៍បញ្ជាក់ដោយភស្តុតាង ដែលច្បាប់បានកំណត់ដោយកំរិតប្រភេទនៃភស្តុតាង ឬអនុភាពក្នុងការបញ្ជាក់ដោយភស្តុតាង ។

**៣-ការបញ្ជូនលិខិតសាលក្រម៖**

ក្រោយពីតុលាការចេញលិខិតសាលក្រមរួចហើយ តុលាការ ត្រូវបញ្ជូនលិខិតសាលក្រមទៅឲ្យភាគីក្នុងអំឡុងពេល ២សប្តាហ៍ ដោយគិតពីថ្ងៃប្រកាសសាលក្រម ។ សាលក្រមដែលត្រូវបញ្ជូននោះគឺ អនុសារសាលក្រម ។ ទោះបីជាមាន ឬគ្មានវត្តមានគូភាគី នៅពេលប្រកាសសាលក្រមក៏ដោយ ក៏ការបញ្ជូនលិខិតសាលក្រម ទៅឲ្យគូភាគីនៃរឿងក្តី គឺក្នុងគោលបំណងឲ្យគូភាគីដឹងច្បាស់លាស់អំពីអត្ថន័យរបស់សាលក្រម ។ ម្យ៉ាងទៀតឆ្លងកាត់ការបញ្ជូននេះអំឡុងពេលអាចប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ចាប់ពីដំណើការហើយភាគីដែលឈ្នះក្តីអាចដាក់ពាក្យសុំទៅតុលាការអនុវត្តជាបណ្តោះអាសន្នបាន ។

## កថាភាគទី ៤ ៖ ទំរង់នៃសាលក្រម

**-១-ទំរង់នៃសាលក្រមចុងក្រោយ**

ចំណុច ដែលត្រូវវិនិច្ឆ័យដោយសាលក្រម (មាត្រា ១៨២)

-តុលាការ ត្រូវចេញសាលក្រមចំពោះការទាមទារទាំងអស់ ដែលភាគីបានសុំ

-តុលាការមិនចេញសាលក្រមចំពោះចំណុចណា ដែលភាគីមិនបានសុំឡើយ ។

-តុលាការត្រូវ សម្រេចអំពីករណីយកិច្ចទទួលបន្ទុកប្រាក់ប្រដាប់ក្តី ទោះបីគ្មានពាក្យសុំរបស់ភាគីក៏ដោយ ។

នៅក្នុងលិខិតសាលក្រម ត្រូវសរសេរចំណុចដូចខាងក្រោមនេះ ៖

១. ឈ្មោះ តុលាការ

www.facebook.com/7khmer
fb : Entertainment And Knowledge

២. ថ្ងៃ ខែ ឆ្នាំ ដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់
៣. ឈ្មោះ ឬនាមករណ៍ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់
៤. អង្គហេតុ និង ចំណុចវិវាទ
៥. សំអាងហេតុ
៦. សេចក្តីសម្រេចបញ្ចប់

ចំពោះអង្គហេតុ និង ចំណុចវិវាទ ត្រូវសរសេរខ្លឹមសារសំខាន់ៗ ដោយផ្អែកលើសេចក្តីថ្លែងការណ៍របស់ភាគី ។ ចៅក្រម ដែលចេញសាលក្រម ត្រូវចុះហត្ថលេខា លើសាលក្រមនោះ ។ ក្នុងករណីណាចៅក្រមណាម្នាក់ ក្នុងចំណោមក្រុមប្រឹក្សាជំនុំជម្រះ មានធុរៈក្នុងការចុះហត្ថលេខា លើលិខិតសាលក្រម ចៅក្រមផ្សេងទៀត ត្រូវចុះ ហត្ថលេខា ដោយចុះនិទ្ទេសអំពីហេតុដែលចៅក្រមនោះ មិនអាចចុះហត្ថលេខាបាន ។

តាមទំរង់ដូចបានបញ្ជាក់រៀបរាប់ខាងលើ ហើយអាចបែងចែកទំរង់នៃសាលក្រមជា ៤ផ្នែក ៖

- **ផ្នែកក្បាលនៃសាលក្រម**
  - តុលាការ
  - ថ្ងៃដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់
  - ឈ្មោះ ឬនាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយ និងឈ្មោះ និង អាស័យដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។
- **ផ្នែកអង្គហេតុ និង ចំណុចវិវាទ**
  - ត្រូវសរសេរខ្លឹមសារសំខាន់ៗ ដោយផ្អែកលើសេចក្តីថ្លែងការណ៍របស់ភាគី
- **ផ្នែកសំអាងហេតុ**
  - គឺជាទឡ្ហីករណ៍នៃអង្គហេតុ និង អង្គច្បាប់ ដែលនាំឲ្យតុលាការចេញសេចក្តីសម្រេច ។ មុននឹងសរសេរផ្នែកសំអាងហេតុ ត្រូវគិតឲ្យហើយជាស្រេច ថាតើនឹងសម្រេចសេចក្តីទៅលើអ្វីខ្លះ គ្មានចំណុចនៃសេចក្តីសម្រេចណាមួយ ដែលគ្មានសំអាងហេតុទេ ។
- **ផ្នែកនៃសេចក្តីសម្រេច**
  - នៅក្នុងរឿងរដ្ឋប្បវេណីរួមមានបណ្តឹងបីយ៉ាង គឺ ៖
    - បណ្តឹងទាមទារឲ្យផ្តល់តាវកាលិក
    - បណ្តឹងទាមទារឲ្យបញ្ជាក់
    - បណ្តឹងទាមទារឲ្យបង្កើត ប្តូរ ឬរំលត់ទំនាក់ទំនងគតិយុត្តិ
  - សាលក្រមដែលសម្រេចដល់សេចក្តីលើបណ្តឹង ទាំងបីយ៉ាងខាងលើនេះហៅថា

- សាលក្រមបង្គាប់ឲ្យផ្តល់តាវកាលិក
- សាលក្រមបញ្ជាក់
- និង សាលក្រម បង្កើត ប្តូរ ឬរំលត់ទំនាក់ទំនងគតិយុត្តិ

o សេចក្តីសម្រេចនៃសាលក្រមចុងក្រោយរួមមាន៖

- សេចក្តីសម្រេចលើកនូវពាក្យបណ្តឹង (ក្នុងករណីដែលពាក្យបណ្តឹងរបស់ដើមចោទ ផ្ទុយនឹងច្បាប់ ឬខ្វះលក្ខខណ្ឌនៃបណ្តឹង )
- សេចក្តីសម្រេចច្រានចោលនូវការទាមទារ (ក្នុងករណីដែលភាគីគ្មានភស្តុតាង ឬមានមិនគ្រប់គ្រាន់ដើម្បីយកមកបញ្ជាក់អង្គហេតុដែលខ្លួនបានអះអាង )
- សេចក្តីសម្រេចទទួលស្គាល់ (ក្នុងករណីដែលភាគីមានភស្តុតាងគ្រប់គ្រាន់យកមកបញ្ជាក់អង្គហេតុ ដែលខ្លួនបានអះអាង ) ។
- និង លើសពីនេះ តុលាការត្រូវសម្រេចផលដែរ អំពីបន្ទុកនៃប្រាក់ប្រដាប់ក្តី ។

**-២-ទំរង់នៃសាលក្រមរបៀប៖**

សាលក្រមរបៀប មានទំរង់ប្រហាក់ប្រហែលគ្នានឹងទំរង់នៃសាលក្រមចុងក្រោយផងដែរ ប៉ុន្តែមានលក្ខណៈខុសប្លែកគ្នាខ្លះៗ ត្រង់ផ្នែកសំអាងហេតុ និង ផ្នែកនៃសេចក្តីសម្រេច ដែលរួមមានដូចតទៅ ៖

❖ **ផ្នែកសំអាងហេតុ៖**

o លើកឡើងនូវហេតុផលទាំងឡាយ ដែលតុលាការមិនអាចសម្រេចដល់អង្គសេចបាន ហើយនាំឲ្យមានការចាត់របៀប ដែលហេតុផលទាំងនោះរួមមាន៖

- ភស្តុតាងមិនគ្រប់គ្រាន់ ឬមិនច្បាស់លាស់ តម្រូវឲ្យមានការស៊ើបសួរបន្ថែម
- តម្រូវឲ្យមានការបំបែកសំណុំរឿង ឬបញ្ចូលសំណុំរឿង
- តម្រូវឲ្យមានការបង្អង់សំណុំរឿង ដោយមានករណីបន្ទាន់បង្ខំ
- តម្រូវឲ្យមានការផ្ទេរសមត្ថកិច្ច

❖ **ផ្នែកនៃសេចក្តីសម្រេច៖**

o ចាត់ឲ្យស៊ើបសួរបន្ថែម
o ចាត់ឲ្យធ្វើកោសល្យវិច័យ ឬប្រតិកោសល្យវិច័យ
o ចាត់របៀបដើម្បីបំបែកសំណុំរឿង ឬបញ្ចូលសំណុំរឿង
o ចាត់របៀប ដើម្បីបង្អង់សំណុំរឿង
o ចាត់របៀប ដើម្បីផ្ទេរសមត្ថកិច្ច

www.facebook.com/7khmer
fb : Entertainment And Knowledge

**កថាភាគទី៥៖ ការប្រកាសសាលក្រម៖**

ជាគោលការណ៍ កំណើតនៃអានុភាពនៃសាលក្រម នឹងមានអានុភាពដោយការប្រកាស ដែលជាទំរង់នៃការជូនដំណឹងពិសេស ។ ទំរង់ណាក្រៅពីការប្រកាសនេះមិនបណ្តាល ឲ្យមាន អានុភាពឡើយ ។ ទំរង់នៃការប្រកាសសាលក្រមអាចធ្វើបានទោះបីជាភាគីម្ខាង ឬទាំងសង ខាងអវត្តមានក៏ដោយ ។ ការប្រកាសត្រូវធ្វើជាសាធារណៈ ។

**១-ការប្រកាសសាលក្រម៖**

១. ត្រូវធ្វើឡើងដោយការកោះហៅតាមកាលបរិច្ឆេទ
២. ត្រូវធ្វើឡើងក្នុងរយៈពេល ១ (មួយ) ខែគឺចាប់ពីថ្ងៃដែលបានបញ្ចប់នូវការ ទាញហេតុផលដោយផ្ទាល់មាត់
៣. ត្រូវធ្វើឡើងដោយផ្អែកលើច្បាប់ដើមនៃមូលសាលក្រម
៤. ត្រូវធ្វើនៅក្នុងសវនាការដែលបើកជាសាធារណៈ (ចៅក្រមទទួលបន្ទុកម្នាក់ ឬ ប្រធានក្រុមប្រឹក្សាជំនុំជំរះជាអ្នកអាននូវសេចក្តីសំរេចបញ្ចប់

**២-អត្តពន្ធភាពនៃសាលក្រម៖**

ជាគោលការណ៍សាលក្រម ដែលប្រកាសរួចហើយ តុលាការដែលចេញសាលក្រម នោះមិនអាចកែប្រែ ឬលុបសាលក្រមនោះបានឡើយ ។

**លើកលែងតែករណីពិសេសមួយ ចំនួនដូចខាងក្រោម៖**

- *ក្នុងករណីដែលសាលក្រមមានការគណនាលេខខុស ឬកត់ខុស ឬកំហុសជាក់ស្តែងផ្សេងទៀត* ដែលមានប្រភេទប្រហាក់ប្រហែលគ្នាតុលាការអាចចេញដីកាសំរេចកែតំរូវ សាលក្រមតាមពាក្យសុំ ឬដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន ។
- *ចំពោះដីកាសំរេចកែតំរូវសរសេរបន្ថែមនៅលើច្បាប់ដើមនៃមូលសាលក្រម និង អនុសារសាលក្រម* ។ ប៉ុន្តែប្រសិនបើយល់ឃើញថាសមរម្យតុលាការអាចធ្វើដីកាសំរេចនេះ ជាលិខិតជំនួសការសរសេរបន្ថែមនៅលើច្បាប់ដើមនៃមូលសាលក្រម និង អនុសារសាលក្រម ហើយ បញ្ជូនឯកសារចំលងយថាភូតនៃការសំរេចនេះទៅឲ្យភាគីបាន ។

ការកែតំរូវសាលក្រមនេះ តុលាការសាមី ត្រូវធ្វើជាដីកាសំរេចកែតំរូវចំណុច ដែលខុសឆ្គង ។ យើងដឹងថាសាលក្រមមានអានុភាពចងតុលាការ ដែលចេញសេចក្តីសំរេចនោះមែនតែ ការកែតំរូវកំហុសជាក់ស្តែងក្នុងការសរសេរពុំមែនជាការផ្លាស់ប្តូរខ្លឹមសាររបស់សាលក្រមឡើយ ។ ក្នុងករណីនេះ បើតំរូវឲ្យឆ្លងកាត់ការវិនិច្ឆ័យនូវកំហុសរបស់តុលាការ ដែលចេញសាលក្រមដោយ

តុលាការជាន់ខ្ពស់នោះកិច្ចការនេះអាចទាមទារឲ្យមានការចំណាយពេលវេលា និង ពលកម្ម ដែលគ្មានប្រយោជន៍យ៉ាងច្រើន ។

ដូច្នេះហើយបញ្ញត្តិនេះ ទទួលស្គាល់ការតំរូវសាលក្រមរបស់តុលាការ ដែលបានចេញសាលក្រមនោះដោយខ្លួនឯង ។ ដោយអ្នកស្វែងរកឃើញនូវការសរសេរខុសលើសាលក្រមភាគច្រើននៃរឿងក្តី ហើយភាគីជាអ្នកទទួលរងនូវការខូចខាតប្រយោជន៍ ដោយសារការសរសេរខុសនោះ ដូច្នេះយើង ត្រូវទទួលស្គាល់នូវសិទ្ធិដាក់ពាក្យសុំ របស់ភាគីក្នុងការសុំកែតំរូវសាលក្រម ដែលសរសេរខុស ។ ចំពោះភាគី ដែលទទួលការខូចខាតប្រយោជន៍ដោយដីកាសំរេចកែប្រែសាលក្រមអាចប្តឹងជំទាស់បានចំពោះដីកាសំរេចនោះបាន ។ ក៏ប៉ុន្តែបើមានការប្តឹងឧទ្ធរណ៍ ក្នុងអំឡុងពេលសិទ្ធិប្តឹងឧទ្ធរណ៍ ចំពោះសាលក្រមនោះភាពត្រឹមត្រូវនៃដីកាសំរេចកែតំរូវសាលក្រមនោះក៏នឹងត្រូវវិនិច្ឆ័យនៅពេល ដែលសាលាឧទ្ធរណ៍ជំនុំជំរះបណ្តឹងឧទ្ធរណ៍ក្នុងការសំរេចសេចក្តីអំពីបណ្តឹងឧទ្ធរណ៍នោះដែរ ។ ហេតុដូច្នេះបញ្ញត្តិមិនអនុញ្ញាតឲ្យភាគីធ្វើ បណ្តឹងជំទាស់ចំពោះដីកាសំរេចកែតំរូវ ដោយឯកឯងឡើយ នៅពេលការប្តឹងឧទ្ធរណ៍ ។ ដីកាសំរេចកែតំរូវសាលក្រម ក្លាយជាសេចក្តីវិនិច្ឆ័យតែមួយ ដោយសរសេរបន្ថែមលើលិខិតសាលក្រម ហើយបង្កើតអានុភាពដូចបានចេញ ដែលមានអត្ថន័យដែលបានកែតំរូវហើយតាំងពីពេលដំបូង ។ ក្នុងករណី ដែលបានធ្វើដីកាសំរេចកែតំរូវពុំចាំបាច់ភ្ជាប់ជាមួយលិខិតសាលក្រមឡើយទៅឲ្យគូភាគី ។

**៣- ពេលសាលក្រមចូលស្ថាពរ**

នៅក្នុងពេល ដែលច្បាប់បានផ្តល់សិទ្ធិឲ្យទៅភាគីប្តឹងឧបាស្រស័យ ទៅតុលាការជាន់ខ្ពស់ ឬប្តឹងទាស់ ដោយស្របច្បាប់នោះសាលក្រមមិនចូលជាស្ថាពរឡើយ ។ ដូចនេះសាលក្រមស្ថាពរ មានអានុភាពបង្អាក់ការដាក់ពាក្យបណ្តឹងឧបាស្រ័យ ទៅតុលាការជាន់ខ្ពស់ ឬពាក្យបណ្តឹងទាស់ ដែលត្រូវបានធ្វើឡើងក្នុងអំឡុងពេល ដែលច្បាប់បានកំណត់ ។ ពេលសាលក្រមចូលជាស្ថាពរ បង្កើតអានុភាពអាជ្ញាអស់ជំនុំ ។ ពេលមានអាជ្ញាអស់ជំនុំ ត្រូវកំណត់ជាស្ថាពរនូវទំនាក់ទំនងសិទ្ធិ ឬ ទំនាក់ទំនងគត្តិយុត្ត នាពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ។ ទំហំនៃអាជ្ញាអស់ជំនុំមានត្រឹមតែទំហំ ដែលបានវិនិច្ឆ័យនៅក្នុងសេចក្តីសំរេចបញ្ចប់ការទាមទារ ដែលបានដាក់ពាក្យបណ្តឹង ឬពាក្យបណ្តឹងតបតែប៉ុណ្ណោះ ហើយអាជ្ញាអស់ជំនុំមិនអាចមានទៅលើសេចក្តីវិនិច្ឆ័យក្នុងសំអាងហេតុនៃសាលក្រមបានទេ ហើយម្យ៉ាងវិញទៀត បើចុងចំលើយទាមទារការទូទាត់ ដោយសិទ្ធិលើបំណុលតបសេចក្តីវិនិច្ឆ័យក្នុងវិនិច្ឆ័យ ក្នុងសាលក្រមស្ថាពរ ដែលសំរេចថាគ្មានសិទ្ធិលើបំណុលតបទេ ត្រូវបង្កើតអានុភាពនៃអាជ្ញាអស់ជំនុំលើទឹក

www.facebook.com/7khmer
fb : Entertainment  And Knowledge

ប្រាក់ ដែលបានតវ៉ាដោយការទូទាត់នោះ ។ ពេលសាលក្រមចូលស្ថាពរ បង្កើតអានុភាព អនុវត្តចាប់តាំងពីពេលដែលអាជ្ញាអស់ជំនុំបានកើតឡើង ។

## ផ្នែកទី ៥៖ ការសះជាតាមផ្លូវបណ្តឹង

### កថាភាគទី១៖ អត្ថន័យនៃការសះជាតាមផ្លូវបណ្តឹង

ការសះជាតាមផ្លូវបណ្តឹង គឺជាសកម្មភាព ដែលដើមចោទ និង ចុងចំលើយធ្វើសម្បទានគ្នាទៅវិញទៅមក (លះបង់រៀងៗខ្លួន ) នូវការអះអាងអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តិដែលជាកម្មវត្ថុនៃបណ្តឹង និង ព្រមព្រៀងបញ្ចប់វិវាទនៅក្នុងនីតិវិធីបណ្តឹង ហើយធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនោះ ដោយឯកភាពគ្នាចំពោះមុខតុលាការ ។ ហេតុនេះហើយ ការសះជា គឺជាមូលហេតុដ៏សំខាន់មួយនៃការបញ្ចប់បណ្តឹង ដូចសាលក្រមដែរ ។

-*<u>ការសាកល្បងធ្វើការផ្សះផ្សា មាត្រា ៩៧ ៖</u>*

តុលាការ អាចសាកល្បងធ្វើការផ្សះផ្សាបាន ទោះបីជាបណ្តឹងស្ថិតនៅក្នុងដំណាក់កាលណាក៏ដោយ ។

-*<u>ការសាកល្បងផ្សះផ្សានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មាត្រា ១០៥៖</u>*

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការ ត្រូវសាកល្បងផ្សះផ្សាជាដំបូងសិន លើកលែងតែយល់ឃើញថាមិនសមរម្យ ។

*<u>ការផ្សះផ្សាលើបណ្តឹង មាត្រា ២២០៖</u>*

ភាគីអាចធ្វើការផ្សះផ្សា នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬកាលបរិច្ឆេទនៃការផ្សះផ្សាបាន ។

ការផ្សះផ្សាដែលបានកំណត់ក្នុងកថាខណ្ឌទី១ ខាងលើនេះ អាចធ្វើនៅក្រៅទីតាំងតុលាការក៏បានដែរ ប្រសិនបើ តុលាការយល់ឃើញថាសមរម្យ ។

*<u>អានុភាពនៃកំណត់ស្តីពីការសះជា ជាអាទិ៍</u>*៖

ក្នុងករណីដែលមានការសះជា ការលះបង់នូវការទាមទារ ឬការទទួលស្គាល់នូវការទាមទារ ត្រូវបានកត់ត្រានៅក្នុងកំណត់ហេតុ កំណត់ហេតុនេះ មានអានុភាពដូចគ្នានឹងសាលក្រមស្ថាពរ ។

*<u>-កំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មាត្រា ១១១ ចំណុច ឃ</u>*

ឃ-ការ ដកពាក្យបណ្តឹង ការផ្សះផ្សា ការលះបង់ការទាមទារ និង ការទទួលស្គាល់ការទាមទារ ។ នេះក៏ចាត់ទុកជាការសះជាតាមផ្លូវបណ្តឹងដែរ ។

www.facebook.com/7khmer
fb : Entertainment And Knowledge

*-កំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់ មាត្រា ១១៩ កថាខណ្ឌទី ១ ចំណុច ក*

ក-ការដកពាក្យបណ្តឹង ការផ្សះផ្សា ការលះបង់ការទាមទារ ការទទួលស្គាល់ការទាមទារ និង ការសារភាព ។ នេះ ក៏ចាត់ទុកជាការសះជាតាមផ្លូវបណ្តឹងដែរ ។

**១- ផលប្រយោជន៍នៃការសះជាតាមផ្លូវបណ្តឹង**

១. អាចបញ្ចប់ជម្លោះបានឆាប់រហ័ស

២. អាចដោះស្រាយជាស្ថាពរ និង ដាច់ស្រេច

៣. ដោះស្រាយសមរម្យតាមធម្មជាតិ ដោយមិនបើហិង្សា

៤. អាចទទួលនូវខ្លឹមសារនៃការសះជាសមរម្យ ដែលស្របទៅនឹងលក្ខណៈ និង ស្ថានភាពនៃរឿងក្តី ។

៥. ភាគី នឹងអនុវត្តដោយស្ម័គ្រចិត្តនូវកាតព្វកិច្ចដែលបានសន្យាក្នុងការសះជា ។

៦. អាចរក្សានូវភាពប្រក្រតីនូវទំនាក់ទំនងរវាងភាគី នាពេលអនាគតបាន។

**២-ការផ្សះផ្សានៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ និង កាលបរិច្ឆេទនៃការផ្សះផ្សា**

១. ការផ្សះផ្សា អាចធ្វើទៅបានជាអសាធារណៈ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬកាលបរិច្ឆេទនៃការផ្សះផ្សា

២. នៅក្នុងនីតិវិធីនៃការផ្សះផ្សា ភាគីអាចនិយាយអ្វីៗដោយស្មោះបាន ចំពោះតុលាការ ដោយសារតែតុលាការមិនអាចយកទៅធ្វើជាមូលដ្ឋាននៃសាលក្រមបាន ។

**៣-ការផ្សះផ្សានៅក្រៅតុលាការ**

ក្នុងករណីដែលតុលាការ យល់ឃើញថា សមរម្យ តុលាការក៏អាចធ្វើការផ្សះផ្សាតាមផ្លូវបណ្តឹង នៅក្រៅតុលាការបាន (មាត្រា២២០ កថាខណ្ឌទី ២) ។

ឧទាហរណ៍ដូចជា៖

- ❖ ការពាក់ព័ន្ធ នឹងជម្លោះស្តីពីព្រំដី ឬស្តីពីការសាងសង់ អាចមានករណីដែលគួរតែផ្សះផ្សាដោយមើលស្ថានភាពផ្ទាល់ទីកន្លែង ។
- ❖ ក្នុងករណីដែលភាគីណាម្ខាងមានជម្ងឺធ្ងន់ មិនអាចចូលខ្លួនមកតុលាការបាន តុលាការអាចផ្សះផ្សានៅកន្លែងណាមួយសមស្រប ក្រៅពីតុលាការបាន ។

## កថាភាគទី ២៖ អានុភាព និង កំណត់ហេតុសះជា

**១-អានុភាពនៃកំណត់ហេតុសះជា**

កំណត់ហេតុសះជា មានអានុភាពដូចនឹងសាលក្រមស្ថាពរដែរ រាប់បញ្ចូលទាំងអនុភាពនៃការបញ្ចប់បណ្តឹង ហើយក្រៅពីនេះ អានុភាពអនុវត្តក្នុងករណីដែលការសះជានោះ មានខ្លឹមសារ

www.facebook.com/7khmer
fb : Entertainment And Knowledge

ផ្តល់តាវកាលិកកំណត់មួយ ។ មានន័យថា ភាគីអាចយកកំណត់ហេតុដែលមានចុះអំពីការសះជានោះ មកធ្វើជាលិខិតអនុវត្ត ដើម្បីដាក់ពាក្យសុំឲ្យអនុវត្តដោយបង្ខំបាន (មាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច ឈ) ។ ដូច្នេះហើយ ក្នុងករណីដែលភាគីម្ខាងទៀត មិនបំពេញកាតព្វកិច្ច ដែលបានកំណត់នៅក្នុងកំណត់ហេតុនៃការសះជានោះទេ អាចអនុវត្តដោយបង្ខំបានហើយនេះ គឺជាចំណុចមួយដ៏សំខាន់ដើម្បីពន្យល់ណែនាំឲ្យភាគីសះជា ។

**២-កំណត់ហេតុសះជា**

ដោយយោងតាមមាត្រា២២២ នៃក្រមនីតិវិធីរដ្ឋប្បវេណី បានចែងថា ក្នុងករណីដែលមានការសះជា ការលះបង់ការទាមទារ ឬការទទួលស្គាល់ការទាមទារ ត្រូវបានកត់ត្រាក្នុងកំណត់ហេតុ កំណត់នេះ មានអានុភាពដូចគ្នានឹងសាលក្រមស្ថាពរ ។

**ក-ទំរង់នៃកំណត់ហេតុសះជា៖**

- **ផ្នែកក្បាលនៃកំណត់ហេតុ៖**
  - បារ វចនា( ព្រះរាជាណាចក្រកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ)
  - បានឃើញ សំណុំរឿងរដ្ឋប្បវេណី លេខ ថ្ងៃ ខែ ឆ្នាំ
  - សាលាដំបូង...............
  - ដើមចោទ ឈ្មោះ ................
  - ចុង ចំលើយឈ្មោះ ............
  - បានឃើញ កំណត់ហេតុត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃ ទី ខែ ឆ្នាំ
  - បានឃើញ កំណត់ទាញហេតុផល ដោយផ្ទាល់មាត់ ចុះ ថ្ងៃ ទី ខែ ឆ្នាំ
- **ផ្នែកខ្លឹមសារនៃកំណត់ហេតុ៖**
  - ត្រូវកត់ត្រាឲ្យបានច្បាស់នូវការទទួលស្គាល់ ឬ លះបង់ការទាមទារ និងធ្វើយ៉ាងណាឲ្យ ងាយស្តាប់ ងាយយល់ តែមានន័យគ្រប់គ្រាន់
- **ផ្នែកសេចក្តីបញ្ចប់នៃកំណត់ហេតុ**
  - ម៉ោង ថ្ងៃ ខែ ឆ្នាំ នៃការបញ្ចប់កំណត់ហេតុ
  - ហត្ថលេខា របស់ចៅក្រម
  - ហត្ថលេខា របស់ក្រឡាបញ្ជី
  - ស្នាមផ្តិមមេដៃរបស់ ដើមចោទ និង ចុងចំលើយ ។

**ខ-ទំរង់គំរូនៃកំណត់ហេតុសះជា៖**

www.facebook.com/7khmer
fb : Entertainment And Knowledge

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

កំណត់ហេតុសះជា

(មាត្រា ២២២ នៃ ក.ន.រ)

បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ ៖........ចុះថ្ងៃទី..........ខែ.......ឆ្នាំ......របស់សាលាដំបូង ...............................។

ដើមចោទ ឈ្មោះ ...............................និង ចុងចំលើយឈ្មោះ ............................... ។

បានឃើញកំណត់ហេតុត្រៀមសម្រាប់ការទាញហេតុផលចុះថ្ងៃទី......ខែ.....ឆ្នាំ ...........របស់ដំបូង..........................................។

នៅថ្ងៃទី................. ខែ.......... ឆ្នាំ............... វេលាម៉ោង.......នាទីព្រឹក នៅសាលាដំបូង....... រវាងដើមចោទឈ្មោះ....... ភេទ....... អាយុ.......ឆ្នាំ មានទីលំនៅភូមិ....... ឃុំ....... ស្រុក....... ខេត្ត....... និងចុងចម្លើយឈ្មោះ....... ភេទ....... អាយុ ....... ឆ្នាំ ប្រពន្ធឈ្មោះ ....... អាយុ ....... ឆ្នាំ មានទីលំនៅភូមិ ............... ឃុំ.................. ស្រុក..................... ខេត្ត.................... បានព្រមព្រៀងសះជានឹងគ្នាដែលចុងចម្លើយសុខចិត្ត......................... ទៅដើមចោទ។

កំណត់ហេតុនេះ គូភាគីបានអាន និង ពិនិត្យ ហើយបានឯកភាពយល់ព្រម ដោយគ្មានភាគីណាមួយជំទាស់ឡើយ។ កំណត់ហេតុនេះ បានបញ្ចប់នៅថ្ងៃទី ....... ខែ....... ឆ្នាំ ....... វេលាម៉ោង .............. នាទី........។

**ដើមចោទ** **ចុងចម្លើយ** **ក្រឡាបញ្ជី**

**បានឃើញ**

**ចៅក្រម**

www.facebook.com/7khmer
fb : Entertainment And Knowledge

# ជំពូកទី ៤

# កិច្ចការក្រឡាបញ្ជីក្នុងនីតិវិធីអនុវត្តដោយបង្ខំ

## ផ្នែកទី១ ៖ សញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំ

ការអនុវត្តដោយបង្ខំ មិនមែនអនុវត្តត្រឹមតែសាលក្រមទេ គឺអនុវត្តរាល់សេចក្តីសម្រេចរបស់តុលាការដែលមានប្រសិទ្ធិភាពអនុវត្ត ។ នីតិវិធីអនុវត្តដោយបង្ខំ ជានីតិវិធីអនុវត្តសិទ្ធិដែលត្រូវបានកំណត់រួចហើយតាមរយៈសាលក្រម ឬលិខិតអនុវត្ត ។ ដូច្នេះ ការអះអាងផ្សេងៗរបស់អ្នកចាញ់ក្នុងរឿងក្តីនេះ មិនបានត្រូវយកមកពិចារណា ក្នុងនីតិវិធីអនុវត្តដោយបង្ខំឡើយ ។ ទន្ទឹមនឹងនេះ ការអនុវត្តត្រូវបានបែងចែកជា ២ប្រភេទធំៗ ដូចជា៖

១. **ការអនុវត្តជាប្រាក់៖**

   a. ការអនុវត្តចំពោះចលនវត្ថុ

   b. ការអនុវត្តចំពោះអចលនវត្ថុ

   c. ការអនុវត្តចំពោះសិទ្ធិលើបំណុល

២. **ការអនុវត្តមិនមែនជាប្រាក់**

   a. ការអនុវត្តស្តីពីសិទ្ធិទាមទារឲ្យប្រគល់វត្ថុ

   b. ការអនុវត្តស្តីពីសិទ្ធិទាមទារឲ្យធ្វើសកម្មភាព ឬមិនឲ្យធ្វើសកម្មភាព

## ផ្នែកទី២៖ កិច្ចការក្រឡាបញ្ជី មុនពេលអនុវត្តដោយបង្ខំចាប់ផ្តើម

នីតិវិធីអនុវត្តដោយបង្ខំ អាចចាប់ផ្តើមបានលុះត្រាតែមានពាក្យសុំពីម្ចាស់បំណុល ។

### កថាភាគទី១៖ ការដាក់ពាក្យសុំឲ្យអនុវត្តដោយបង្ខំ

ពេលដែលមានពាក្យសុំពីម្ចាស់បំណុល ពេលនោះ ក្រឡាបញ្ជីត្រូវពិនិត្យពាក្យសុំនោះ តើបានគោរពតាមលក្ខខណ្ឌដែលមានចែងនៅមាត្រា ៣៤៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីដែរ ឬទេ

ពាក្យសុំឲ្យអនុវត្តដោយបង្ខំ ត្រូវ៖

១. ពាក្យសុំ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ

www.facebook.com/7khmer
fb : Entertainment  And Knowledge

២. ត្រូវមានឈ្មោះ និង អាសយដ្ឋាន របស់ម្ចាស់បំណុល នៃការអនុវត្ត ឬអ្នកតំណាង
៣. ត្រូវ មានឈ្មោះ និង អាសយដ្ឋាន របស់កូនបំណុលនៃការអនុវត្ត ឬអ្នកតំណាង
៤. សញ្ញាណនៃលិខិតអនុវត្ត (ភ្ជាប់ជាមួយនឹងពាក្យសុំ )
៥. លក្ខណៈនៃការសុំឲ្យអនុវត្តដោយបង្ខំ ៖

a. ដោយផ្ទាល់

b. ដោយជំនួស

c. ឬ ដោយប្រយោល

៦. ខ្លឹមសារនៃសេចក្តីសម្រេច ក្នុងលិខិតអនុវត្ត

ក្រោយពេល ដែលក្រឡាបញ្ជីបានធ្វើការពិនិត្យលើពាក្យសុំឲ្យអនុវត្តដោយបង្ខំបានគោរព តាមលក្ខខណ្ឌនៃមាត្រា ៣៥៩ រួចហើយ នោះក្រឡាបញ្ជីត្រូវ៖

១. ចុះក្នុងសៀវភៅទទួលបណ្តឹង សុំឲ្យអនុវត្តដោយបង្ខំ
២. បង្គាប់ឲ្យបង់ពន្ធដាក់ពាក្យសុំ ចំនួន ១ ម៉ឺន រៀល (មាត្រា ៣៧២)
៣. បង្គាប់ឲ្យដាក់ពាក្យសុំឲ្យផ្តល់រូបមន្តអនុវត្ត (មាត្រា ៣៥៥)

**កថាភាគទី ២៖ ការផ្តល់រូបមន្តអនុវត្ត៖**

**១-ការផ្តល់រូបមន្តអនុវត្តត្រូវធ្វើឡើងដោយក្រឡាបញ្ជី**

ជាទូទៅ ក្រឡាបញ្ជី មានភារកិច្ចក្នុងការផ្តល់រូបមន្តអនុវត្ត ពោលគឺក្រឡាបញ្ជីនៃសាលាដំបូងដែលមានសមត្ថកិច្ច បានសេចក្តីថា ក្រឡាបញ្ជីត្រូវយកលិខិតអនុវត្តដើម មកថតចម្លងដោយបញ្ជាក់ថា" *បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម" រួចចុះហត្ថលេខា និង បោះត្រា ទើបក្លាយទៅជាឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលក្រឡាបញ្ជី ត្រូវយកមកប្រើប្រាស់សំរាប់ការផ្តល់រូបមន្តអនុវត្ត ។* រូបមន្តអនុវត្តមាន ២ ប្រភេទ ៖ (១)-រូបមន្តអនុវត្តសាមញ្ញ(មាត្រា ៣៥៤ នៃ ក.ន.រ ) និង (២)- រូបមន្តអនុវត្តពិសេស (មាត្រា ៣៥៦ នៃក.ន.រ) ។

www.facebook.com/7khmer
fb : Entertainment And Knowledge

**១-១-រូបមន្តអនុវត្តសាមញ្ញ**

-លិខិតអនុវត្តគ្មានភាពស្មុគស្មាញ

-មានទំនាក់ទំនងផ្ទាល់ចំពោះតែដើមចោទ និង ចុងចំលើយក្នុងរឿងក្តី

-គ្មានគោលដៅច្រើន

-កំណត់ពេលវេលាច្បាស់លាស់

**១-២-រូបមន្តអនុវត្តពិសេស**

-មានលក្ខខណ្ឌបង្អង់

-ពេលវេលាកំណត់មិនពិតប្រាកដ

-អនុវត្តទៅលើអ្នកផ្សេងក្រៅពីកូនបំណុល និង ម្ចាស់បំណុលដែលលិខិតអនុវត្តបាន កំណត់ ។

-ការផ្តល់រូបមន្តអនុវត្តច្រើនច្បាប់

មុននឹងក្រឡាបញ្ជី ធ្វើការផ្តល់រូបមន្តអនុវត្តពិសេសយកទៅអនុវត្តបានលុះតែះ

ក-*ម្ចាស់បំណុលធានាបាន នូវលក្ខខណ្ឌនៃមាត្រា ៣៥៦កថាខណ្ឌទី១ះ*

នៅក្នុងករណីដែលសិទ្ធិទាមទារដែលត្រូវបានកំណត់នៅក្នុងលិខិតអនុវត្ត ភ្ជាប់ជាមួយនឹងលក្ខខណ្ឌបង្អង់ ឬពេលកំណត់មិនពិតប្រាកដ ក្រឡាបញ្ជី ឬសារការីអាចប្រគល់រូបមន្តអនុវត្តបាន លុះត្រាតែម្ចាស់បំណុលនៃការអនុវត្តបានបញ្ជាក់អំពីការបំពេញលក្ខខណ្ឌ ឬការមកដល់នូវពេលកំណត់មិនពិតប្រាកដនោះ ។

*ខ-មានការអនុញ្ញាតពីប្រធានតុលាការ ឬ ចៅក្រមចាត់តាំង(មាត្រា ៣៥៦ កថាខណ្ឌទី ៤*

នៅពេលក្រឡាបញ្ជីផ្តល់រូបមន្តអនុវត្តដោយយោងាតាមបញ្ញត្តិ នៃកថាខណ្ឌទី ១ ឬ កថាខណ្ឌទី ៣ នៃ មាត្រា ៣៥៦ (*ក្នុងករណីដែលមានភាពច្បាស់លាស់ថា អាចនឹងធ្វើការអនុវត្តដោយបង្ខំ ដោយយកបុគ្គលផ្សេងក្រៅពីភាគីដែលត្រូវបានកំណត់នៅក្នុងលិខិតអនុវត្តធ្វើជាម្ចាស់បំណុលនៃការអនុវត្ត ឬកូនបំណុលនៃការអនុវត្ត ឬករណីដែលម្ចាស់បំណុលនៃការអនុវត្តបានបញ្ជាក់ដោយលិខិតអនុវត្តអំពីហេតុការណ៍នោះ ក្រឡាបញ្ជី ឬ សារការីអាចផ្តល់*

www.facebook.com/7khmer
fb : Entertainment  And Knowledge

*រូបមន្តអនុវត្ត )* ខាងលើនេះ ក្រឡាបញ្ជីនោះ ត្រូវទទួលសេចក្តីអនុញ្ញាតពីតុលាការដែលខ្លួនស្ថិតនៅ ។

**ក-អ្នកដែលអាចអនុវត្តដោយបង្ខំបាន**(មាត្រា ៣៥១)

- ❖ ម្ចាស់បំណុលអនុវត្ត ឬ កូនបំណុលនៃការអនុវត្ត
- ❖ ភាគីដែលបានបញ្ជាក់ក្នុងលិខិតអនុវត្ត
- ❖ តតីយជនដែលបានបញ្ជាក់ក្នុងលិខិតអនុវត្ត
- ❖ អ្នកដែលទទួលបន្តសិទ្ធិ
- ❖ កូនបំណុលទី ៣

**ខ-ចំណុចដែលត្រូវសរសេរក្នុងរូបមន្តអនុវត្ត** (មាត្រា ៥៥៧)

- ❖ រូបមន្តអនុវត្តត្រូវសរសេរ បន្ថែមនៅផ្នែកក្រោមនៃឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត រួមមាន៖
  - ▪ បុគ្គលដែលអាចទាមទារឲ្យធ្វើការអនុវត្តដោយបង្ខំ ដោយលិខិតអនុវត្តនោះ និង ភាគីម្ខាងទៀត
  - ▪ មូលហេតុដែលត្រូវផ្តល់រូបមន្តអនុវត្តពិសេស
  - ▪ មូលហេតុដែលផ្តល់រូបមន្តអនុវត្តតែមួយផ្នែកនៃសិទ្ធិទាមទារ
  - ▪ មូលហេតុដែលផ្តល់រូបមន្តច្រើនច្បាប់
- ❖ ក្រឡាបញ្ជី ឬសារការី ត្រូវចុះហត្ថលេខាលើរូបមន្តអនុវត្ត ហើយសរសេរ ថ្ងៃ ខែ ឆ្នាំ នៃការផ្តល់រូបមន្តអនុវត្ត ។

ឧទាហរណ៍: ការផ្តល់រូបមន្តអនុវត្តសាមញ្ញ៖ **រូបមន្តអនុវត្ត**

ម្ចាស់បំណុលនៃការអនុវត្តឈ្មោះ ....................អាចអនុវត្តដោយបង្ខំចំពោះកូនបំណុលនៃការអនុវត្តឈ្មោះ ................................ដោយផ្អែកលើលិខិតអនុវត្ត "សាលក្រមលេខ.........ចុះថ្ងៃទី........ខែ ..............ឆ្នាំ............របស់សាលាដំបូង............................................. ។

ធ្វើនៅថ្ងៃទី............ខែ..............ឆ្នាំ......................

ក្រឡាបញ្ជី

ហត្ថលេខា ឈ្មោះ និង ត្រា

**គ-ការសរសេរចូលនៅក្នុងច្បាប់ដើមនៃលិខិតអនុវត្ត** ( មាត្រា ៣៥៩ )

នៅពេលផ្តល់រូបមន្តអនុវត្ត ក្រឡាបញ្ជី ឬសារការី ត្រូវសរសេរក្នុងច្បាប់ដើម នៃលិខិតអនុវត្តនូវចំណុចដូចខាងក្រោម៖

- មូលហេតុ ថ្ងៃ ខែ ឆ្នាំ និង ចំនួនឯកសារចម្លងយថាភូត ដែលបានផ្តល់រូបមន្តអនុវត្ត
- ករណី ដែលផ្តល់រូបមន្តមួយផ្នែក នៃសិទ្ធិទាមទារ
- មូលហេតុ ឈ្មោះ ម្ចាស់បំណុល និង កូនបំណុលនៃការអនុវត្ត ក្នុងករណីផ្តល់រូបមន្តអនុវត្តពិសេស
- មូលហេតុ ដែលផ្តល់រូបមន្តច្រើនច្បាប់

## ២- ការអនុវត្តដោយបង្ខំ ត្រូវផ្អែកលើខ្លឹមសារនៃលិខិតអនុវត្ត

**ក-លិខិតអនុវត្ត** (មាត្រា ៣៥០ )

លិខិតដែលកំណត់ថា ជាលិខិតអនុវត្ត មានដូចខាងក្រោម៖

១. សាលក្រម ឬសាលដីកា បង្គាប់ឲ្យផ្តល់តាវកាលិកដែលបានចូលជាស្ថាពរ ។
២. សាលក្រម ឬសាលដីកា បង្គាប់ឲ្យផ្តល់តាវកាលិក ដែលភ្ជាប់ជាមួយនឹងការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន ។
៣. ដីកាសម្រេចបង្គាប់ឲ្យផ្តល់តាវកាលិក បានចូលជាស្ថាពរ ។
៤. ដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន ។
៥. ការចាត់ចែងរបស់ក្រឡាបញ្ជី
៦. លិខិតយថាភូតដែលធ្វើដោយសារការី ចំពោះការទាមទារដែលមានគោលបំណងសងជាប្រាក់ ហើយបានចំពោះ តែកូនបំណុល បញ្ជាក់ថា ខ្លួនអាចទទួលយកការអនុវត្តដោយបង្ខំបានភ្លាមៗ ។
៧. សាលក្រម ឬសាលដីកា របស់តុលាការបរទេស (មាត្រា ៣៥២)
៨. សេចក្តីសម្រេចមជ្ឈត្តករ(មាត្រា ៣៥៣)
៩. កំណត់ហេតុស្តីពីការសះជា (មាត្រា ២២២)

**ខ-ការអនុវត្តផ្អែកលើលិខិតអនុវត្ត**

នៅពេលដែលមានពាក្យសុំឲ្យអនុវត្ត ភ្ជាប់ជាមួយនឹងឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត បានដាក់ចូលមកដល់ការិយាល័យក្រឡាបញ្ជីនៃសាលាដំបូងដែលមានសមត្ថកិច្ច ។

ក្រឡាបញ្ជីមានភារកិច្ចដូចតទៅ៖

www.facebook.com/7khmer
fb : Entertainment And Knowledge

**ខ-១-ករណីដែលក្រឡាបញ្ជីមិនចាំបាច់ផ្តល់រូបមន្តអនុវត្តៈ**

លិខិតអនុវត្តដែលមិនចាំបាច់មានរូបមន្តអនុវត្ត ដូចជា៖

១. សាលក្រមស្ថាពរ ដែលរឿងក្តីមានចំនួនទឹកប្រាក់តិចជាង ១លានរៀលចុះ

២. សាលក្រម ដែលរឿងក្តីមានចំនួនទឹកប្រាក់តិច ភ្ជាប់ជាមួយការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន

៣. ដីកាសម្រេចដាស់តឿនដែលភ្ជាប់ ការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន

៤. ដីកាសម្រេចដាស់តឿន (ចំពោះជនដែលបានកំណត់ក្នុងដីកាតែប៉ុណ្ណោះ )

**ខ-២-ករណីដែលក្រឡាបញ្ជី បដិសេធមិនផ្តល់រូបមន្តអនុវត្ត (មាត្រា ៣៦១)**

ក្នុងករណីដែលម្ចាស់បំណុលមិនបាន កាតព្វកិច្ចផ្តល់ឯកសារទាំងឡាយ ដែលអាចបញ្ជាក់ច្បាស់លាស់អំពីការសុំរបស់ខ្លួន ដូចជា៖

១. លិខិតអនុវត្តនោះ មានអនុភាពអនុវត្ត អាចយកទៅអនុវត្តបាន

២. លិខិតបញ្ជាក់ពីភាពចាំបាច់ តម្រូវឲ្យអនុវត្តទៅអ្នកក្រៅពីអ្នកដែលបានកំណត់នៅក្នុងលិខិតអនុវត្ត

៣. លិខិតដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិរបស់ម្ចាស់បំណុល នៅពេលការតវ៉ា

៤. លិខិតដែលមានបញ្ជាក់បន្ថែមលើភាពមិនច្បាស់លាស់នៃលិខិតអនុវត្ត ដូចជាកំណត់ហេតុសៈជា ពុំបានបញ្ជាក់អំពីកាតព្វកិច្ច ច្បាស់លាស់ ឬមិនបានកំណត់ពេលវេលា ដែលត្រូវមកដល់ ។

ករណីនេះ ក្រឡាបញ្ជីមិនចាំបាច់ផ្តល់រូបមន្តអនុវត្តឡើយ ។

**ខ-៣-ករណីដែលមានការផ្តល់រូបមន្តអនុវត្ត**

ក្រៅពី ចំណុច (ខ-១ និង ខ-២ )ខាងលើនេះ ក្រឡាបញ្ជីអាចផ្តល់រូបមន្តអនុវត្តទៅ អ្នកដាក់ពាក្យឲ្យអនុវត្តបាន ក្រោមការពិនិត្យរបស់ក្រឡាបញ្ជី និង បង្គាប់ឲ្យអ្នកដាក់ពាក្យសុំអនុវត្តដាក់*ពាក្យសុំឲ្យផ្តល់រូបមន្តអនុវត្ត* ។ ការផ្តល់រូបមន្តអនុវត្តនេះ ក្រឡាបញ្ជីអាចផ្តល់រូបមន្តអនុវត្តជា *រូបមន្តអនុវត្តសាមញ្ញ និង រូបមន្តអនុវត្តពិសេសបាន* ។

**កថាភាគទី ៣៖ ការបង់សោហ៊ុយសម្រាប់ការអនុវត្ត** (មាត្រា ៣៧១)

**១-ពន្ធដាក់ពាក្យសុំ** (មាត្រា ៣៧២ )

ក្នុងករណីដែលដាក់ពាក្យសុំឲ្យអនុវត្តដោយបង្ខំ ***ទៅតុលាការអនុវត្ត*** ម្ចាស់បំណុលនៃការអនុវត្ត ត្រូវបង់ពន្ធចំនួន ១០.០០០(មួយម៉ឺន) រៀល ទៅតុលាការ ហើយ ករណីដែលដាក់

www.facebook.com/7khmer
fb : Entertainment And Knowledge

ពាក្យសុំឲ្យអនុវត្តដោយបង្ខំ *ទៅអាជ្ញាសាលា* ម្ចាស់បំណុល ត្រូវបង់ពន្ធ តាមបញ្ញត្តិ ដែលកំណត់ផ្សេង (ដោយផ្អែកតាមសេចក្តីប្រកាសរបស់ក្រសួងយុត្តិធម៌ គឺ ត្រូវបង់ចំនួន ៥.០០០ រៀល ។

**២-សោហ៊ុយក្រៅពី ពន្ធដាក់ពាក្យសុំ** (មាត្រា ៣៧៣)

-ត្រូវបង់ ចំនួនទឹកប្រាក់សំរាប់បញ្ជូនឯកសារ

-ប្រាក់សម្រាប់ធ្វើសកម្មភាពផ្សេងៗ ដើម្បីនីតិវិធី ដែលកំណត់ដោយតុលាការ

**៣-សោហ៊ុយនានា**(មាត្រា ៣៧៤)

គឺជាសោហ៊ុយផ្សេងៗ ដែលតុលាការទទួលស្គាល់ថា ចាំបាច់ត្រូវឲ្យម្ចាស់បំណុលនៃការអនុវត្ត ឬកូនបំណុលអនុវត្តចំណាយឲ្យអ្នកក្រៅពីតុលាការអនុវត្ត និង អាជ្ញាសាលា ដូចជាៈ

-សោហ៊ុយសម្រាប់ធ្វើឯកសារ

-សោហ៊ុយសម្រាប់ធ្វើដំណើរសម្រាប់ម្ចាស់បំណុលនៃការអនុវត្ត ឬកូនបំណុលនៃការអនុវត្ត ដើម្បីចូលបង្ហាញខ្លួនតាមកាលបរិច្ឆេទ ដែលតុលាការ កំណត់ពេលវេលា ឬទីកន្លែង ។

-សោហ៊ុយសម្រាប់ធ្វើលិខិតចម្លងការចុះបញ្ជីអចលនវត្ថុ ពីស្ថាប័នមានសមត្ថកិច្ច

-សោហ៊ុយសម្រាប់ចុះបញ្ជីផ្សេងៗ

**៤-សោហ៊ុយសម្រាប់នីតិវិធី ៖**

-សោហ៊ុយដែលមានអាទិភាពក្នុងការសង នៅក្នុងនីតិវិធីអនុវត្ត ៖

-សោហ៊ុយសម្រាប់ផលប្រយោជន៍រួម ( ជាសហ៊ុយចាំបាច់ ដើម្បីជម្រុញដំណើរការនៃនីតិវិធីអនុវត្ត ហើយដែលជាផលប្រយោជន៍រួមនៃម្ចាស់បំណុលទាំងអស់ " ដីកាសម្រេចបង្គាប់ឲ្យប្រគល់លិខិតបញ្ជាក់នាវា នៅមុនពេលដាក់ពាក្យសុំ មាត្រា ៥៥៩ ) ។

**<u>សំគាល់ៈ</u>** រាល់សោហ៊ុយទាំងអស់ ម្ចាស់បំណុលត្រូវបង់ជាមុន បើមិនបង់ទេ តុលាការអាចលើកចោល ពាក្យសុំឲ្យអនុវត្តដោយបង្ខំ ឬលុបចោលនីតិវិធីអនុវត្តដោយបង្ខំ(មាត្រា ៣៧៥ ) ។ បើមានការខ្វះខាតក្នុងការចំណាយ តុលាការបង្គាប់ឲ្យម្ចាស់បំណុលបង់បន្ថែម ។ សោហ៊ុយសម្រាប់ការអនុវត្ត ជាបន្ទុករបស់កូនបំណុលនៃការអនុវត្ត (មាត្រា ៣៧៦ )ដែល ត្រូវកាត់កងទៅឲ្យម្ចាស់បំណុលនៃការអនុវត្តវិញ ក្រោយពីការលក់ ចលនវត្ថុ - អចលនវត្ថុរបស់កូនបំណុលរួចហើយ ។

ជនដែលពាក់ព័ន្ធ នឹងរឿងក្តីនិង មានផលប្រយោជន៍ ចំពោះការអនុវត្តដោយបង្ខំធ្វើឡើងដោយតុលាការ អាចទាមទារមើលសំណុំរឿង ថតចម្លងសំណុំរឿង ប្រគល់ឯកសារចម្លងយថាភូត ប្រគល់លិខិតបញ្ជាក់ផ្សេងៗ ដែលពាក់ព័ន្ធនឹងផលប្រយោជន៍របស់ខ្លួន ពីតុលាការបាន ។

www.facebook.com/7khmer
fb : Entertainment And Knowledge

**កថាភាគទី ៤៖ ការបញ្ជូនលិខិតអនុវត្ត** (មាត្រា ៣៦០ )

ការអនុវត្តដោយបង្ខំ អាចចាប់ផ្ដើមបាន តែក្នុងករណីដែលឯកសារចម្លងយថាភូត ឬឯកសារដែលមានសេចក្ដីបញ្ជាក់នៃលិខិតអនុវត្ត ឬសេចក្ដីសម្រេចដែលនឹងក្លាយជាលិខិតអនុវត្តនៅពេលចូលជាស្ថាពរ ត្រូវបានបញ្ជូនទៅ កូនបំណុលនៃការអនុវត្តជាមុន ។ នៅក្នុងករណីដែលដែលរូបមន្តអនុវត្តត្រូវបានប្រគល់ តាមបញ្ញត្តិនៃមាត្រា ២៥៦ (រូបមន្តអនុវត្តពិសេស )នៃក្រមនេះ ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃរូបមន្តអនុវត្ត និងឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃឯកសារដែលម្ចាស់បំណុលនៃការអនុវត្តបានដាក់ តាមបញ្ញត្តិនៃមាត្រា ៣៥៦ នោះក៏ត្រូវបញ្ជូនទៅជាមុនផងដែរ ។

**កថាភាគទី៥៖ ពាក្យសុំតវ៉ា** (អាចមានម្ចាស់បំណុល ឬកូនបំណុល ឬតតីយជន )

**១-ចំពោះការចាត់ចែងផ្ដល់រូបមន្តអនុវត្ត** (មាត្រា ៣៦២)

ចំពោះការចាត់ចែងពាក្យសុំឲ្យផ្ដល់រូបមន្តអនុវត្ត បើជា*ការចាត់ចែងរបស់ក្រឡាបញ្ជី* អាច*ដាក់ពាក្យសុំតវ៉ាទៅតុលាការដែលក្រឡាបញ្ជីនោះស្ថិតនៅ* តែបើជា*ការចាត់ចែងរបស់សារការី អាចដាក់ពាក្យសុំតវ៉ា ទៅសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងនៃការិយាល័យរបស់សារការីនោះ* ។

ការសម្រេចសេចក្ដីអំពីពាក្យសុំតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើដោយដីកាសម្រេច ។

បញ្ញត្តិនៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលមានពាក្យសុំឲ្យប្រគល់បន្ថែមនូវឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី២ នៃកថាខណ្ឌទី ១ មាត្រា ៣៥៤(ភាពចាំបាច់នៃរូបមន្តអនុវត្ត និង ស្ថាប័នផ្ដល់រូបមន្តអនុវត្ត )នៃក្រមនេះ ។

**២-ចំពោះការទាមទារ កុំឲ្យតុលាការអនុញ្ញាតការអនុវត្តដោយបង្ខំ** (មាត្រា ៣៦៣)

កូនបំណុលនៃការអនុវត្តដែលមានការតវ៉ាចំពោះអត្ថិភាព ឬអត្ថន័យនៃសិទ្ធិទាមទារដែលត្រូវបានកំណត់នៅក្នុងលិខិតអនុវត្ត *អាចដាក់បណ្ដឹងតវ៉ាចំពោះការទាមទារ ដើម្បីកុំឲ្យតុលាការ* អនុញ្ញាតការអនុវត្តដោយបង្ខំ ដោយផ្អែកលើលិខិតអនុវត្តនោះបាន ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះលិខិតអនុវត្តដែលបានកំណត់នៅក្នុង ចំណុច **ខ** ឬចំណុច **ឃ** នៃកថាខណ្ឌទី ២មាត្រា ៣៥០ (លិខិតអនុវត្ត) នៃក្រមនេះ ហើយមិនទាន់ចូលជាស្ថាពរ ។

កូនបំណុលនៃការតវ៉ាចំពោះសាលក្រម ឬសាសដីកាស្ថាពរ ត្រូវបានកម្រិតត្រឹមតែហេតុដែលកើតឡើងនៅក្រោយការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់តែប៉ុណ្ណោះ ។

www.facebook.com/7khmer
fb : Entertainment And Knowledge

បណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះ ស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការ តាមការកំណត់នីមួយៗ យោងទៅតាមផ្នែកនៃលិខិតអនុវត្តដែលបានកំណត់ក្នុងចំណុចនីមួយៗខាងក្រោមនេះ ៖

**ក**- លិខិតអនុវត្តដែលបានកំណត់ចាប់ពីចំណុច **ក** រហូតដល់ចំណុច **ឃ** ឬចាប់ពីចំណុច **ឆ** រហូតទៅដល់ចំណុច **ឈ** កថាខណ្ឌទី ២ មាត្រា ៣៥០ (លិខិតអនុវត្ត )នៃក្រមនេះ ៖**សាលាដំបូងនៃនីតិវិធីសម្រេចសេចក្តីនោះ ។**

**ខ**- លិខិតអនុវត្តដែលបានកំណត់នៅចំណុច **ខ** កថាខណ្ឌទី ២ មាត្រា ៣៥០(លិខិតអនុវត្ត) នៃក្រមនេះ ៖ **តុលាការដែលក្រឡាបញ្ជីចាត់ចែងដូចចំណុចនោះ ស្ថិតនៅ ។**

**គ**- លិខិតអនុវត្តដែលបានកំណត់នៅចំណុច **ច** កថាខណ្ឌទី ២មាត្រា ៣៥០ (លិខិតអនុវត្ត) នៃក្រមនេះ ៖ **តុលាការដែលមានសមត្ថកិច្ច លើទីកន្លែងរបស់ចុងចំលើយដែលត្រូវបានកំណត់ដោយមាត្រា ៨ (សមត្ថកិច្ចសាលាជម្រះក្តី ដែលបានកំណត់ទៅតាមលំនៅដ្ឋាន ជាអាទិ៍ )នៃក្រមនេះ** ។ បើពុំមានតុលាការដែលមានសមត្ថកិច្ច តាមមាត្រានេះ ទេ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលកម្មវត្ថុនៃការទាមទារ ឬទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្តដែលអាចរឹបអូសបាន ស្ថិតនៅ ។

**៣-ចំពោះការទាមទារ របស់តតិយជន** (មាត្រា ៣៦៥ )

តតីយជនដែលមានកម្មសិទ្ធិ ឬសិទ្ធិផ្សេងទៀតដែលរាំងស្ទះការធ្វើអនុប្បទាន ឬប្រគល់ចំពោះវត្ថុដែលជាកម្មវត្ថុនៃ ការអនុវត្តដោយបង្ខំ អាចដាក់ពាក្យបណ្តឹងតវ៉ា ដើម្បីទាមទារកុំឲ្យអនុញ្ញាតការអនុវត្តដោយបង្ខំ ចំពោះម្ចាស់បំណុលនៃការអនុវត្តដោយបង្ខំ ។

បណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ខាងលើនេះ ចំពោះការអនុវត្តដោយបង្ខំដោយតុលាការអនុវត្តដែលក្លាយជាស្ថាប័នអនុវត្ត ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការនោះ រីឯចំពោះការអនុវត្តដោយបង្ខំ ដោយអាជ្ញាសាលាដែលក្លាយជាស្ថាប័នអនុវត្ត ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាដំបូងដែលអាជ្ញាសាលានោះស្ថិតនៅ ។

## ផ្នែកទី ៣៖ កិច្ចការក្រឡាបញ្ជី នៅពេលការអនុវត្តដោយបង្ខំចាប់ផ្តើម

## កថាភាគទី១៖ ការអនុវត្តចំពោះចលនវត្ថុ ជាសមត្ថកិច្ចរបស់អាជ្ញាសាលា

១. ពាក្យសុំអនុវត្តចំពោះចលនវត្ថុ ត្រូវធ្វើទៅអាជ្ញាសាលា នៃសាលាដំបូងមានសមត្ថកិច្ច

២. ចាំបាច់ ត្រូវបញ្ជាក់ទីកន្លែងដែលចលនវត្ថុ ត្រូវបានរឹបអូសស្ថិតនៅ ។

៣. មិនចាំបាច់កំណត់ច្បាស់លាស់ចលនវត្ថុ ត្រូវរឹបអូសនៅពេលដាក់ពាក្យសុំឡើយ មានន័យថាគ្រាន់តែថា សុំរឹបអូសចលនវត្ថុរបស់កូនបំណុល នៅទីកន្លែង នេះ

www.facebook.com/7khmer
fb : Entertainment And Knowledge

ឬនៅកន្លែងនោះបានហើយ ។ អាជ្ញាសាលាជាអ្នកពិចារណាសម្រេចថា ត្រូវរឹបអូសវត្ថុអ្វី ដោយផ្អែកទៅលើមាត្រា ៣៨៥ ។ ចៅក្រមមិនចាំបាច់ចេញដីកាសម្រេចរឹបអូសទេ ក្នុងករណីនេះទេ ព្រោះអាជ្ញាសាលាជាស្ថាប័នអនុវត្តហើយ។

៤. ចំពោះការរឹបអូស រថយន្ត ឬទោចក្រយានយន្ត ដែលបានចុះបញ្ជី អជ្ញាសាលាត្រូវផ្ទុកផ្ដាក់ឲ្យស្ថាប័ន ដែលមានសមត្ថកិច្ចសរសេរ ចូលទៅក្នុងសៀវភៅចុះបញ្ជីថា យានយន្តនោះ ត្រូវបានរឹបអូសហើយ មាត្រា ៣៨៧ ។

៥. ប្រសិនបើប៉ាន់ប្រមាណឃើញថា ចំនួនទឹកប្រាក់ដែលបានមកពីការលក់ចលនវត្ថុដែលត្រូវបានរឹបអូសនោះ គ្មានចំនួនសេសសល់ ក្រោយពីបានសងសោហ៊ុយសម្រាប់នីតិវិធីហើយ អាជ្ញាសាលាមិនត្រូវរឹបអូសឡើយ មាត្រា ៣៩២ ។

៦. ចលនវត្ថុដែលត្រូវបានរឹបអូស អាជ្ញាសាលា ត្រូវលក់តាមវិធីលក់ឡាយឡុងដោយផ្ទាល់មាត់ ឬដោយដាក់ស្រោមសំបុត្រ មាត្រា ៣៩៥ ។

## កថាភាគីទី២៖ ការអនុវត្តចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ជាសមត្ថកិច្ចរបស់តុលាការអនុវត្ត

### ក-អត្ថន័យនៃការអនុវត្តចំពោះសិទ្ធិលើបំណុល និង តុលាការអនុវត្ត

ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ដែលមានគោលបំណងឲ្យសងជាប្រាក់ ឬប្រគល់ចលនវត្ថុ ត្រូវ*ហៅថាការអនុវត្តចំពោះសិទ្ធិលើបំណុល ។*

កូនបំណុលនៃសិទ្ធិលើបំណុលដែលនឹងត្រូវរឹបអូស ត្រូវហៅថា *កូនបំណុលទី ៣ ។*

ក្នុងការអនុវត្តចំពោះសិទ្ធិលើបំណុល សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងរបស់កូនបំណុលនៃការអនុវត្តដែលបានកំណត់នៅក្នុងមាត្រា ៨ (សមត្ថកិច្ចសាលាជម្រះក្ដីដែលបានកំណត់ទៅតាមលំនៅដ្ឋាន ជាអាទិ៍ )នៃក្រមនេះ គឺជាតុលាការអនុវត្តដែលមានសមត្ថកិច្ចហើយ ក្នុងករណីដែលគ្មានកន្លែងខាងលើនេះ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងរបស់កូនបំណុលទី ៣ ដែលបានកំណត់នៅមាត្រា ៨ គឺជាតុលាការអនុវត្តដែលមានសមត្ថកិច្ច វិញ ។

ក្នុងករណីដែលដីកាសម្រេចរឹបអូសបានចេញម្ដងទៀត ចំពោះសិទ្ធិលើបំណុលដែលត្រូវបានរឹបអូស បើតុលាការអនុវត្តដែលបានចេញដីកាសម្រេចរឹបអូសនោះខុសគ្នា តុលាការអនុវត្តអាចផ្ទេររឿងក្ដីនោះ ទៅតុលាការអនុវត្តផ្សេងបាន ។

**ខ-ពាក្យសុំឲ្យអនុវត្តចំពោះសិទ្ធិលើបំណុល** (មាត្រា ៤០៣ )

១. ពាក្យសុំឲ្យអនុវត្តចំពោះសិទ្ធិលើបំណុល ត្រូវដាក់ទៅតុលាការអនុវត្ត

www.facebook.com/7khmer
fb : Entertainment And Knowledge

២. នៅក្នុងពាក្យសុំឲ្យអនុវត្តចំពោះសិទ្ធិលើបំណុល ក្រៅពីចំណុចដែលបានកំណត់នៅក្នុងចំណុចនីមួយៗ នៃកថាខណ្ឌទី ២ មាត្រា ៣៩៩ (របៀបដាក់ពាក្យសុំឲ្យអនុវត្តដោយបង្ខំ ) នៃក្រមនេះ ត្រូវបញ្ជាក់អំពីកូនបំណុលទី៣ ផងដែរ ។

៣. ក្នុងករណីដែលសុំឲ្យអនុវត្តចំពោះផ្នែកណាមួយនៃសិទ្ធិលើបំណុល ម្ចាស់បំណុលនៃការអនុវត្ត ត្រូវសរសេរបញ្ជាក់ឲ្យបានច្បាស់លាស់នូវទំហំនៃការអនុវត្តនោះ ក្នុងពាក្យសុំឲ្យអនុវត្តចំពោះសិទ្ធិលើបំណុល ។

៤. ការអនុវត្តចំពោះសិទ្ធិលើបំណុល ត្រូវចាប់ផ្តើមដោយដីកាសម្រេចរឹបអូសរបស់តុលាការអនុវត្ត ។

៥. ក្នុងដីកាសម្រេចរឹបអូស តុលាការអនុវត្តត្រូវហាមមិនឲ្យកូនបំណុលនៃការអនុវត្តធ្វើការប្រមូលសិទ្ធិលើបំណុល ឬការចាត់ចែងផ្សេងទៀត ហើយហាមមិនឲ្យកូនបំណុលទី ៣ សងបំណុលឲ្យកូនបំណុលនៃការអនុវត្តនោះ ។

៦. ដីកាសម្រេចរឹបអូស ត្រូវធ្វើឡើង ដោយមិនត្រូវសួរកូនបំណុលលនៃការអនុវត្ត និងកូនបំណុលទី៣ ទេ ។

៧. ដីកាសម្រេចរឹបអូស ត្រូវបញ្ជូនទៅឲ្យកូនបំណុលនៃការអនុវត្ត និង កូនបំណុលទី៣

៨. អានុភាពនៃការរឹបអូស ត្រូវកើតឡើងនៅពេលដែលដីកាសម្រេចរឹបអូស ត្រូវបញ្ជូនទៅដល់ដៃកូនបំណុលទី៣។

៩. នៅពេលដែលដីកាសម្រេចរឹបអូស ត្រូវបានបញ្ជូនទៅកូនបំណុលនៃការអនុវត្ត និងកូនបំណុលទី ៣ *ក្រឡាបញ្ជី ត្រូវជូនដំណឹងអំពីការណ៍នោះ និង ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជូននោះ ទៅម្ចាស់បំណុលនៃការអនុវត្ត ។*

១០. បើដីកាសម្រេចរឹបអូសចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀតដែលបានចុះបញ្ជី បានបង្កើតអានុភាព តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត *ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ឲ្យស្ថាប័នដែលមានសមត្ថកិច្ច ចុះបញ្ជីបញ្ជាក់ថា សិទ្ធិលើបំណុលនោះ ត្រូវបានរឹបអូសហើយ ។*

១១. ចំពោះសេចក្តីសម្រេចអំពីពាក្យសុំឲ្យចេញដីកាសម្រេចរឹបអូស អាចប្តឹងជំទាស់បាន ។

ដូច្នេះ នៅពេលដែលមានពាក្យសុំឲ្យអនុវត្តចំពោះសិទ្ធិលើបំណុល និងក្រោយពីបានធ្វើការពិនិត្យរួចហើយនោះ តុលាការនឹងចេញដីកាសម្រេចរឹបអូសទៅតាមពាក្យសុំរបស់អ្នកសុំ ។

ពេលនេះ ក្រឡាបញ្ជីមានភារកិច្ចដូចតទៅ៖

១. ផ្ទុកផ្តាក់ឲ្យស្ថាប័នមានសមត្ថកិច្ចចុះបញ្ជី

www.facebook.com/7khmer
fb : Entertainment And Knowledge

២. បញ្ជូន ដីកាសម្រេចរឹបអូសទៅៈ

a. កូនបំណុលនៃការអនុវត្ត

b. កូនបំណុលទី ៣

c. ម្ចាស់បំណុលនៃការអនុវត្ត

d. ដាស់តឿនឲ្យកូនបំណុលទី៣ ធ្វើសេចក្តីថ្លែងការណ៍ អត្ថិភាព ឬ នត្ថិភាព នៃសិទ្ធិលើបំណុលដែលត្រូវបានរឹបអូសនោះ ហើយប្រភេទនៃចំនួនទឹកប្រាក់ និង ខ្លឹមសារនៃសិទ្ធិលើបំណុល ក្នុងអំឡុងពេល ២ សប្តាហ៍ ចាប់ពី ***ថ្ងៃបញ្ជូនដីកាសម្រេចរឹបអូស ។***

**គ-ដីកាសម្រេចបង្គាប់ឲ្យលក់ សិទ្ធិលើបំណុល** (មាត្រា ៥១៣)

បើការរឹបអូសសិទ្ធិលើបំណុលមានការលំបាកដូចជា មានភ្ជាប់លក្ខខណ្ឌ ឬមានការលំបាកផ្សេងៗ ម្ចាស់បំណុលនៃការអនុវត្ត អាចសុំឲ្យតុលាការ ចេញដីកាសម្រេចឲ្យលក់សិទ្ធិលើបំណុលដែលបានរឹបអូសនោះ ។ ពោលនៅពេលដែលមានពាក្យសុំពីម្ចាស់បំណុលសុំដីកាសម្រេចបង្គាប់ឲ្យលក់ លុះតុលាការត្រូវៈ

**<u>គ-១-ករណីដែលតុលាការមិនអាចចេញដីកាសម្រេចឲ្យលក់</u>**

តុលាការអនុវត្ត អាចចេញដីកាសម្រេចរឹបអូសសិទ្ធិលើបំណុលទាំងអស់ដែលត្រូវរឹបអូសនោះបាន តែប្រសិនបើតំលៃនៃសិទ្ធិលើបំណុលដែលបានរឹបអូស លើសតំលៃនៃសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្ត និង សោហ៊ុយសម្រាប់ការអនុវត្ត នោះតុលាការអនុវត្តមិនត្រឹមរឹបអូសសិទ្ធិលើបំណុលផ្សេងទៀតឡើយ (មាត្រា ៥០៤ កថាខណ្ឌទី ១ និង ទី ២ )

**<u>គ-២-ករណីដែលតុលាការចេញដីកាសម្រេចឲ្យអាជ្ញាសាលាលក់</u>**

បើសិទ្ធិលើបំណុលដែលត្រូវបានរឹបអូស មានលក្ខខណ្ឌ ឬមានកំណត់ពេល ឬមានការលំបាកក្នុងការប្រមូលដោយសារភ្ជាប់នឹងតាវកាលិកតប ឬមានហេតុផ្សេងទៀត តុលាការអាចចេញដីកាសម្រេចបង្គាប់ឲ្យអាជ្ញាសាលាលក់សិទ្ធិលើបំណុលនោះ ដោយវិធីដែលកំណត់ដោយតុលាការអនុវត្ត ហើយឲ្យយកប្រាក់ដែលបានមកពីការលក់នោះ ទៅឲ្យតុលាការអនុវត្ត តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត ។ ក្នុងករណីដែលតុលាការចេញដីកាសម្រេច នោះតុលាការអនុវត្តត្រូវសួរកូនបំណុលនៃការអនុវត្ត ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយចំពោះករណីដែលកូនបំណុលនៃការអនុវត្តនៅបរទេស ឬមិនដឹងលំនៅដ្ឋានកូនបំណុលនោះដែលមានចែងនៅមាត្រា ៥១៣ កថាខណ្ឌទី ១ និង ទី២ ) ។

ហេតុដូច្នេះ ត្រូវបង្គាប់ឲ្យអ្នកជំនាញ ធ្វើការវាយតំលៃ និង ក្រោយពីធ្វើវាយតំលៃរួចហើយ នឹងធ្វើការលក់តាមវិធីដែលតុលាការកំណត់អាចក្រៅពី តាមស្រោមសំបុត្រ ឬផ្ទាល់មាត់ ។

**កថាភាគទី ៣៖ ការអនុវត្តចំពោះ អចលនវត្ថុ ជាសមត្ថកិច្ចរបស់តុលាការអនុវត្ត**( មាត្រា ៩១៧ )

អចលនវត្ថុសំដៅទៅលើដី អាគារដែលត្រូវបានចុះបញ្ជី ចំណែកកម្មអវភាគលើដី ឬ អាគារនោះ សិទ្ធិជួលអចិន្ត្រៃយ៍ និង ផលុបភោគដែលត្រូវបានចុះបញ្ជី និង ចំណែកនៃសិទ្ធិទាំងនេះដែលជាសិទ្ធិរួម ។

ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ត្រូវធ្វើតាមវិធីលក់ដោយបង្ខំ ។

ពាក្យសុំឲ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ត្រូវភ្ជាប់ជាមួយឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត និង ឯកសារខាងក្រោម៖

**ក**- ចំពោះអចលនវត្ថុដែលត្រូវបានចុះបញ្ជី ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជី និង ក្នុងករណីដែលជនដទៃក្រៅពីកូនបំណុលនៃការអនុវត្ត ត្រូវបានចុះបញ្ជីនៅក្នុងសៀវភៅចុះបញ្ជី ថាជាកម្មសិទ្ធិករឯកសារដែលមានបញ្ជាក់ថា អចលនវត្ថុនោះជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត ។

**ខ**- ចំពោះដីដែលមិនបានចុះបញ្ជី ឯកសារដែលបញ្ជាក់ថា ដីនោះជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត ។

នៅពេលដែលមានពាក្យសុំឲ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ភ្ជាប់ជាមួយឯកសារចម្លងនៃការចុះបញ្ជី(បើមាន) និង លិខិតអនុវត្ត ដាក់ចូលមកដល់សាលាដំបូងដែលមានសមត្ថកិច្ច (មាត្រា ៩១៨ ) ។ នៅពេលសាលាដំបូងដែលមានសមត្ថកិច្ច ពិនិត្យ ថា បានគោរពតាមលក្ខខណ្ឌដែលបញ្ញត្តិដោយច្បាប់នោះ តុលាការ នឹងទទួលពាក្យសុំឲ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ដោយចេញដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ ។

ហេតុដូច្នេះហើយ ក្រឡាបញ្ជីមានភារកិច្ចត្រូវធ្វើដូចតទៅ៖

១. ចុះសៀវភៅបណ្ដឹងសុំឲ្យអនុវត្តដោយបង្ខំ
២. បង្គាប់ឲ្យបង់ពន្ធ និង សោហ៊ុយសម្រាប់ការអនុវត្ត
៣. ត្រូវផ្ទុកផ្ដាក់ឲ្យស្ថាប័នមានសមត្ថកិច្ចចុះបញ្ជី អំពីការរឹបអូស
៤. ត្រូវជូនដំណឹងពីដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្ខំទៅកូនបំណុលនៃការអនុវត្ត

www.facebook.com/7khmer
fb : Entertainment And Knowledge

៥. ជូនដំណឹង និង កំណត់ពេលចុងក្រោយពីការលក់ដោយបង្ខំ ទៅម្ចាស់បំណុលផ្សេងៗទៀតដែលចង់ទាមទារចំណែក (មាត្រា ៤២២ )

**១-ជនដែលអាចទាមទារឲ្យចែកចំណែក៖**

ការទាមទារឲ្យចែកចំណែក ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដោយសរសេរនូវមូលហេតុ និង ចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល ដោយរួមបញ្ចូលទាំងការប្រាក់ និង សិទ្ធិលើបំណុលបន្ទាប់បន្សំឯទៀត ។ ប៉ុន្តែបើមានការទាមទារឲ្យចែកចំណែកនោះ តុលាការ ត្រូវជូនដំណឹងអំពីហេតុការណ៍នោះ ទៅម្ចាស់បំណុលនៃការអនុវត្ត និង កូនបំណុលនៃការអនុវត្ត ។

ជនដែលអាចទាមទារឲ្យចែកចំណែករួមមាន៖

១. ម្ចាស់បំណុលដែលមានឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលអាចអនុវត្តដោយបង្ខំបាន

២. ម្ចាស់បំណុលដែលបានចុះបញ្ជីអំពីការរឹបអូស បណ្ដោះអាសន្ន នៅក្រោយពេលចុះបញ្ជីអំពីការរឹបអូសដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ ។

៣. ម្ចាស់បំណុលដែលបានបញ្ជាក់ដោយឯកសារថា មានឯកសិទ្ធិទូទៅ ។

**២-តុលាការអាចលុបចោលនីតិវិធីនៃការលក់ដោយបង្ខំបាន** (មាត្រា ៤២៧ )

- បើមានភាពច្បាស់លាស់អំពីស្ថានភាព ដែលបានបាត់បង់អចលនវត្ថុ
- ករណីដែលអចលនវត្ថុនោះ ស្ថិតនៅក្រោមកម្មសិទ្ធិរបស់តតីយជន
- ម្ចាស់បំណុលនៃការអនុវត្ត បានដកពាក្យសុំ

បើពាក្យសុំឲ្យលក់ដោយបង្ខំ ត្រូវបានដកចេញ ឬ បើអានុភាពនៃដីកាសម្រេចលុបចោលនីតិវិធីលក់ដោយបង្ខំ បានកើតឡើង ***ក្រឡាបញ្ជី ត្រូវផ្ទុកផ្ដាក់ឲ្យស្ថាប័នមានសមត្ថកិច្ចលុបចោលការចុះបញ្ជីអំពីរឹបអូស ដែលពាក់ព័ន្ធនឹងដីកាសម្រេចចាប់ផ្ដើមនោះ ។***

ចំពោះសោហ៊ុយចាំបាច់សម្រាប់ការផ្ទុកផ្ដាក់ ដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ជាបន្ទុករបស់ម្ចាស់បំណុលនៃការអនុវត្តដែលបានដកពាក្យសុំចេញ ឬម្ចាស់បំណុលនៃការអនុវត្តដែលបានទទួលដីកាសម្រេចលុបចោលនោះ (មាត្រា ៤២៨ ) ។

## ផ្នែកទី ៤៖ កិច្ចការក្រឡាបញ្ជី នៅពេលអនុវត្តការលក់

### កថាភាគទី១៖ សញ្ញាណនៃការលក់ និង នីតិវិធីលក់

មុននឹងលក់ តុលាការអនុវត្ត ត្រូវជ្រើសតាំងអ្នកវាយតំលៃ និង បង្គាប់ឲ្យវាយតំលៃអចលនវត្ថុ ដោយផ្អែកលើការស្រាវជ្រាវ ទំនាក់ទំនងនៃការកាន់កាប់ និង ស្ថានភាពបច្ចុប្បន្នឯទៀត (មាត្រា ៤៣០) ។

www.facebook.com/7khmer
fb : Entertainment  And Knowledge

**១-ការចាត់ចែងការលក់៖** តុលាការអនុវត្ត ត្រូវ៖

- បង្គាប់ឲ្យស្រាវជ្រាវអំពីស្ថានភាពនៃអចលនវត្ថុ ដើម្បីធ្វើការវាយតំលៃ
- ចាត់តាំងអ្នកវាយតំលៃ និង បង្គាប់ឲ្យធ្វើការវាយតំលៃអចលនវត្ថុ
- ត្រូវរាយការណ៍អំពីការលំបាក បើមានទៅ តុលាការអនុវត្ត ឬអាចសុំជំនួយពីអាជ្ញាសាលា ។

**២-វិធីលក់**(មាត្រា ៤៣៦)

ការលក់អចលនវត្ថុ ត្រូវអនុវត្តតាមវិធីលក់ឡាយឡុង ដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់ ។

តុលាការអនុវត្តអាចកំណត់វិធីលក់ ផ្សេងពីវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់ តែក្នុងករណីដែលពុំអាចលក់តាមវិធីលក់ឡាយឡុង ដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់ ។

ប្រសិនបើការលក់តាមវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់ តុលាការអនុវត្ត ត្រូវកំណត់កាលបរិច្ឆេទ និង ទីកន្លែងលក់ ហើយត្រូវឲ្យ*អាជ្ញាសាលាអនុវត្តការលក់នោះ*

ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ***ក្រឡាបញ្ជី ត្រូវផ្សព្វផ្សាយជាសាធារណៈនូវសញ្ញាណនៃអចលនវត្ថុ ដែលត្រូវលក់ តំលៃលក់អប្បបរមា ព្រមទាំងកាលបរិច្ឆេទ និង ទីកន្លែងលក់ ។***

**<u>២-១-ការធានាលើសំណើទិញ</u>**(មាត្រា ៤៣៧ )

អ្នកចូលមកដេញថ្លៃក្នុងការលក់ឡាយឡុង គេហៅថា **អ្នកធ្វើសំណើទិញអចលនវត្ថុ** ត្រូវដាក់ប្រាក់ធានា ដែលមានចំនួន ស្មើរនឹងចំនួន *១ ភាគ ១០* (មួយភាគដប់) នៃតំលៃលក់អប្បបរិមា ។ ប៉ុន្តែ បើយល់ឃើញថា សមរម្យ តុលាការអនុវត្តអាចកំណត់ចំនួននៃប្រាក់ធានាលើសពីចំនួននេះ បាន ។

ប្រសិនបើមានសំណើទិញពីបុគ្គលក្រៅពី**អ្នកស្នើសុំទិញក្នុងតំលៃអតិបរិមា** តុលាការអនុវត្ត ត្រូវសងភ្លាមនូវប្រាក់ធានា ដែលបានដាក់តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ក្រោយពេលបញ្ចប់ការលក់ ដែលធ្វើឡើង ដោយផ្អែកលើបញ្ញត្តិនៃ មាត្រា ៤៣៦ (វិធីលក់) នៃក្រមនេះ ។

**<u>២-២-ការកំណត់អ្នកស្នើសុំទិញក្នុងតំលៃអតិបរិមា ៖</u>**(មាត្រា ៤៣៨ )

បើការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់បានបញ្ចប់ អាជ្ញាសាលាត្រូវប្រកាសការបញ្ចប់កាលបរិច្ឆេទនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬដោយផ្ទាល់

www.facebook.com/7khmer
fb : Entertainment And Knowledge

មាត់ ក្រោយពីពេលបានកំណត់អ្នកស្នើសុំទិញក្នុងតំលៃអតិបរិមា និង បានប្រកាសនូវនាម ឬនាមករណ៍របស់អ្នកទិញ និង ថ្លៃលក់ឡាយឡុងនោះ ។

បើអ្នកដេញថ្លៃ ដោយស្រោមសំបុត្រ ដែលបានធ្វើសំណើរទិញក្នុងតំលៃអតិបរិមា មានច្រើននាក់ អាជ្ញាសាលា ត្រូវកំណត់អ្នកស្នើទិញក្នុងតំលៃអតិបរិមា ដោយឲ្យអ្នកទាំងនោះដេញថ្លៃដោយស្រោមសំបុត្រម្តងទៀត ។ ក្នុងករណីនេះ អ្នកដេញថ្លៃមិនអាចដេញថ្លៃដោយតំលៃតិចជាងតំលៃដែលខ្លួនដេញមុនបានឡើយ ។

បើអ្នកដេញថ្លៃ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី២ ខាងលើនេះ មិនដេញថ្លៃម្តងទៀតទេ អ្នកស្នើសុំទិញក្នុងតំលៃអតិបរិមា ត្រូវបានកំណត់ដោយការចាប់ឆ្នោត ។ បញ្ញត្តិនេះត្រូវយកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអ្នកដេញថ្លៃដោយស្រោមសំបុត្រ ដែលបានធ្វើសំណើរទិញក្នុងតំលៃអតិបរិមា មានច្រើននាក់ នៅក្នុងការលក់ឡាយឡុង ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នោះ ។

បើបានអនុវត្តការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់ហើយ អាជ្ញាសាលា ត្រូវធ្វើកំណត់ហេតុនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់ដែលសរសេរនូវចំណុចដូចខាងក្រោម ហើយត្រូវដាក់ទៅតុលាការអនុវត្តភ្លាម ៖

**ក**-សញ្ញាណនៃអចលនវត្ថុ

**ខ**-កាលបរិច្ឆេទនៃការលក់ឡាយឡុង ដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់

**គ**- សញ្ញាណរបស់អ្នកស្នើសុំទិញក្នុងតំលៃអតិបរិមា និង អ្នកតំណាង

**ឃ**- តំលៃរបស់អ្នកស្នើសុំទិញក្នុងតំលៃអតិបរិមា

**ង**-ហេតុការណ៍នោះ និង ស្ថានភាព បើមិនអាចកំណត់អ្នកស្នើសុំទិញក្នុងតំលៃអតិបរិមា

**ច**- មូលហេតុ និង វិធានការដែលបានចាត់ធ្វើ បើបានចាត់វិធានការដែលបានកំណត់នៅមាត្រា ៣៩៦ (ការរក្សាសណ្តាប់ធ្នាប់នៅកន្លែងលក់ ) នៃក្រមនេះ ។

អាជ្ញាសាលា ត្រូវឲ្យអ្នកស្នើសុំទិញក្នុងតំលៃអតិបរិមា ឬអ្នកតំណាង ចុះហត្ថលេខាលើកំណត់ហេតុនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់ ។

**<u>២-៣-ការអនុញ្ញាត ឬ មិនអនុញ្ញាតឲ្យលក់៖( មាត្រា ៤៤២)</u>**

លើកលែងតែក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ២ ខាងក្រោមនេះ *តុលាការអនុវត្ត ត្រូវចេញដីកាសម្រេចអនុញ្ញាតឲ្យលក់ ។*

តុលាការអនុវត្ត ត្រូវចេញដីកាសម្រេចមិនអនុញ្ញាតឲ្យលក់ បើទទួលស្គាល់ថា មានហេតុណាមួយដូចបានកំណត់ក្នុងចំណុចខាងក្រោមនេះ ៖

www.facebook.com/7khmer
fb : Entertainment And Knowledge

**ក**-មិនត្រូវចាប់ផ្ដើម ឬបន្តនូវនីតិវិធីនៃការលក់ដោយបង្ខំ

**ខ**-អ្នកស្នើសុំទិញក្នុងតំលៃអតិបរិមា ពុំមានលក្ខណសម្បត្តិ ឬសមត្ថភាពដើម្បីទិញអចលនវត្ថុ ឬអ្នកតំណាងរបស់អ្នកស្នើសុំទិញក្នុងតំលៃអតិបរិមា ពុំមានសិទ្ធិនោះ ។

**គ**-មានសេចក្ដីស្នើសុំកុំឲ្យអនុញ្ញាតការលក់ ដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា ៤៤៥ (ការស្នើសុំកុំឲ្យអនុញ្ញាតការលក់ ជាអាទិ៍ ក្នុងករណីដែលអចលនវត្ថុ ត្រូវបានខូចខាត )នៃក្រមនេះ ។

**ឃ**- មានកំហុសធ្ងន់ធ្ងរ នៅក្នុងនីតិវិធីនៃដីកាសម្រេចកំណត់តំលៃលក់អប្បបរមា

**ង**-មានកំហុសធ្ងន់ធ្ងរនៅក្នុងនីតិវិធីនៃការលក់ ។

ហេតុនេះ ប្រសិនបើតុលាការអនុវត្តអនុញ្ញាតឲ្យលក់នោះ តុលាការអនុវត្ត នឹងកំណត់កាលបរិច្ឆេទ ដើម្បីចេញដីកាសម្រេចការលក់ ដោយប្រកាសអនុញ្ញាតឲ្យលក់(មាត្រា ៤៤២ កថាខណ្ឌទី១ ) ដែលត្រូវធ្វើការជូនដំណឹងទៅជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ។

ហេតុនេះហើយ កិច្ចការក្រឡាបញ្ជីនៅក្នុងការចេញដីកាសម្រេចអនុញ្ញាតឲ្យលក់មាន៖

១. ព្រាងលិខិតជូនដំណឹង

២. ដាក់ជូនតុលាការអនុវត្ត ចុះហត្ថលេខា

៣. ចាត់ចែងការជូនដំណឹង

***សំគាល:*** ប្រសិនបើជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ប្ដឹងជំទាស់ក្នុងកាលបរិច្ឆេទកំណត់ការប្រកាសអនុញ្ញាតឲ្យលក់ ឬមិនអនុញ្ញាតឲ្យលក់ នោះតុលាការនឹងសម្រេចទទួល ឬលើកចោលបណ្ដឹងជំទាស់ ដោយដីកាសម្រេច ។

**៣-ការបង់ថ្លៃលក់** មាត្រា ៤៤៧

បើដីកាសម្រេចអនុញ្ញាតឲ្យលក់បានចូលជាស្ថាពរ អ្នកទិញ ត្រូវបង់ថ្លៃលក់ទៅតុលាការអនុវត្ត នៅមុនពេលដែលតុលាការអនុវត្តបានកំណត់ ។ ពេលកំណត់នេះ ត្រូវស្ថិតនៅក្នុងអំឡុងពេល ១ (មួយ) ខែ ចាប់ពីថ្ងៃ ដែលដីកាសម្រេចអនុញ្ញាតឲ្យលក់ បានចូលជាស្ថាពរ ។

ចំនួនទឹកប្រាក់ដែលអ្នកទិញបានដាក់ដើម្បីធានាលើសំណើទិញ ត្រូវគិតបញ្ចូលក្នុងថ្លៃលក់

បើអ្នកទិញគឺជាម្ចាស់បំណុល ដែលត្រូវទទួលការចែកចំណែកពីប្រាក់លក់ អ្នកទិញនោះអាចបង់ថ្លៃលក់ ដោយដកនូវចំនួនទឹកប្រាក់ដែលខ្លួនត្រូវទទួលពីការចែកចំណែក នៅកាលបរិច្ឆេទនៃការចែងចំណែកបាន ដោយស្នើសុំទៅតុលាការអនុវត្ត នៅមុនពេលបញ្ចប់កាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់ ។ ក្នុងករណីនេះ បើមានសេចក្ដីថ្លែងតវ៉ាអំពីចំនួនទឹកប្រាក់នៃ

ការចែកចំណែកដែលអ្នកទិញត្រូវទទួល អ្នកទិញ ត្រូវបង់ចំនួនប្រាក់ដែលស្មើនឹងភាគដែលមានការតវ៉ានោះ ជាបន្ទាន់ ។

អ្នកទិញធ្វើលទ្ធកម្មនូវអចលនវត្ថុ នៅពេលដែលខ្លួនបានបង់ថ្លៃលក់ហើយ ។

<u>៣-១-កិច្ចការក្រឡាបញ្ជីក្នុងផ្ទុកផ្ដាក់ឲ្យចុះបញ្ជី ដោយការបង់ថ្លៃលក់(មាត្រា ៥៤៨ )</u>

ប្រសិនបើ អ្នកទិញបានបង់ថ្លៃលក់ហើយ *ក្រឡាបញ្ជីត្រូវ៖*

១. ផ្ទុកផ្ដាក់ឲស្ថាប័នមានសមត្ថកិច្ច ចុះបញ្ជី អំពីការផ្ទេរសិទ្ធិពីម្ចាស់អចលនវត្ថុដែលបានលក់ឡាយឡុង មកអ្នកទិញ ។

២. លុបការចុះបញ្ជី អំពីការផ្ទេរសិទ្ធិដែលអ្នកទិញបានធ្វើលទ្ធកម្ម

៣. លុបការចុះបញ្ជី អំពីលទ្ធកម្មនូវសិទ្ធិដែលបានរលត់ដោយការលក់ ឬសិទ្ធិដែលបានបាត់បង់អានុភាពដោយការលក់ ។

៤. លុបការចុះបញ្ជី អំពីការចាត់ចែងជាបណ្ដោះអាសន្នដែលបានបាត់បង់អានុភាពដោយការលក់

៥. លុបការចុះបញ្ជី អំពីការរឹបអូស ឬការរឹបអូសជាបណ្ដោះអាសន្ន ។

**សំគាល់៖** ដើម្បីផ្ទុកផ្ដាក់ឲ្យស្ថាប័នមានសមត្ថកិច្ចចុះបញ្ជី ក្រឡាបញ្ជី ត្រូវភ្ជាប់ឯកសារចម្លងយថាភូតនៃដីកាសម្រេចអនុញ្ញាតឲ្យលក់ ជាមួយនឹងលិខិតផ្ទុកផ្ដាក់នោះ ។ ចំពោះសោហ៊ុយចាំបាច់ដើម្បីផ្ទុកផ្ដាក់ ខាងលើនេះ ជាបន្ទុករបស់អ្នកទិញ ។

## ផ្នែកទី៥៖ កិច្ចការក្រឡាបញ្ជី នៅពេលអនុវត្តដោយបង្ខំចំពោះនាវា

នាវា សំដៅទៅលើជនយានដែលមានចំណុះសរុបជាតោនស្មើនឹង និង លើសពី ២០ (ម្ភៃ) តោន ទោះបីជាមិនបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជាក៏ដោយ និង ជលយានដែលមានចំណុះសរុបជាតោនក្រោម ២០ (ម្ភៃ) តោន ហើយដែលបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា (មាត្រា ៥៥៥ ) ។

កិច្ចការក្រឡាបញ្ជី នៅពេលអនុវត្តដោយបង្ខំ ចំពោះនាវា វាប្រហាក់ប្រហែលគ្នាទៅនឹងការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុដែរ ដែលមានផ្ទុកផ្ដាក់ឲ្យស្ថាប័នមាសមត្ថកិច្ចចុះបញ្ជីនៅមុនពេលរឹបអូស និង ឲ្យលុបការចុះបញ្ជី ក្រោយការលក់ឡាយឡុង ឬមានការលុបចោលការអនុវត្តដោយបង្ខំដោយដាក់ប្រាក់ធានា ជាដើម ។

www.facebook.com/7khmer
fb : Entertainment And Knowledge

# ជំពូកទី ៥
# នីតិវិធីដាស់តឿន និង ការចាត់ចែងរក្សាការពារ

## ផ្នែកទី ១៖ នីតិវិធីដាស់តឿន

### កថាភាគទី ១៖ សញ្ញាណទូទៅនៃនីតិវិធីដាស់តឿន

នីតិវិធីដាស់តឿន ជានីតិវិធីមួយ ដែលអាចឲ្យម្ចាស់បំណុល បានទទួលដោយឆាប់រហ័ស និង ងាយស្រួល នូវលិខិតអនុវត្តមួយ ដែលអាចយកទៅសុំឲ្យអនុវត្តដោយបង្ខំបាន ដូចសាលក្រម ឬសាលដីកាចំពោះការទាមទារដែលមានគោលបំណងឲ្យសងជាប្រាក់ដោយមិនបាច់ឆ្លងកាត់តាមនីតិវិធីបណ្តឹងធម្មតា ហើយបានតែក្នុងករណីដែលម្ចាស់បំណុលយល់ឃើញថា កូនបំណុលគ្មានហេតុ ផលដើម្បីជំទាស់តាមការទាមទារដែលមានគោលបំណងឲ្យសងជាប្រាក់ ។

តុលាការអាចចេញដីកាសម្រេចដាស់តឿនបាន តាមពាក្យសុំរបស់ម្ចាស់បំណុល ចំពោះការទាមទារដែលមានគោលបំណងឲ្យសងជាប្រាក់ ។ ប៉ុន្តែករណីនេះ អាចធ្វើទៅបាន លុះត្រាតែអាចធ្វើការបញ្ជូនដីកានោះ នៅក្នុងព្រះរាជាណាចក្រកម្ពុជាបាន តាមវិធីក្រៅពីការបញ្ជូនតាមការផ្សាយជាសាធារណៈ (មាត្រា ៣១៩ ) ។

### កថាភាគទី២៖ ពាក្យសុំឲ្យចេញដីកាសម្រេចដាស់តឿន ( មាត្រា ៣២០ )

ពាក្យសុំចេញដីកាសម្រេចដាស់តឿន ចំពោះកូនបំណុលដូចមានកំណត់ក្នុងចំណុចខាងក្រោម *ត្រូវធ្វើទៅសាលាដំបូងដែលមានសមត្ថកិច្ចលើតំបន់ដែលបានកំណត់ក្នុងចំណុចនីមួយៗ ខាងក្រោមនេះ ៖*

**ក-រូបវន្តបុគ្គល៖**

- លំនៅឋាន
- ឬបើពុំមានលំនៅឋាន ឬ
- មានលំនៅឋានមិនពិតប្រាកដនៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ គឺទីសំណាក់

**ខ-នីតិបុគ្គលក្នុងប្រទេស៖**

- ទីស្នាក់ការកណ្តាល ឬ
- ទីកន្លែងអាជីវកម្មចម្បង ឬ
- បើពុំមានទីស្នាក់ការ ឬ
- ទីន្លែងអាជីវកម្មទេ គឺ លំនៅឋានរបស់អ្នកតំណាង ឬ
- របស់អ្នកទទួលខុសត្រូវភារកិច្ចចាត់ចែងការងារជាចម្បង ។

**គ-នីតិបុគ្គលបរទេស៖**

- ទីស្នាក់ការកណ្តាល ឬ
- ទីកន្លែងអាជីវកម្មចម្បងនៅព្រះរាជាណាចក្រកម្ពុជា ឬ
- បើពុំមានទីស្នាក់ការ ឬទីកន្លែងអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ គឺ
- លំនៅឋានរបស់អ្នកតំណាងប្រចាំព្រះរាជាណាចម្រកម្ពុជា ឬ
- របស់អ្នកទទួលខុសត្រូវភារកិច្ចចាត់ចែងការងារជាចម្បងនៅព្រះរាជណាចក្រកម្ពុជា ។

ពាក្យសុំឲ្យចេញដីកាសម្រេចដាស់តឿន អំពីការទាមទារដែលបានកំណត់ក្នុងចំណុចខាងក្រោមនេះ អាចធ្វើទៅសាលាដំបូងដែលមានសមត្ថកិច្ចលើតំបន់ដែលបានកំណត់ក្នុងចំណុចនីមួយៗខាងក្រោមនេះបានដែរ ៖

**ក**-ការទាមទារចំពោះបុគ្គលដែលមានទីស្នាក់ការ ឬកន្លែងអាជីវកម្ម ហើយ ការទាមទារនោះទាក់ទងនឹងការងារនៃទីស្នាក់ការ ឬទីកន្លែងអាជីវកម្មនោះ ៖

- គឺ កន្លែងដែលមានទីស្នាក់ការ ឬ
- ទីកន្លែងអាជីវកម្មនោះ ។

**ខ**- ការទាមទារឲ្យសងជាប្រាក់ដោយរូបិយាណត្តិ ឬមូលប្បទានប័ត្រ និង ការទាមទារបន្ទាប់បន្សំ ដែលទាក់ទងនឹងវត្ថុទាំងនេះ ៖

- កន្លែងដែលត្រូវសងរូបិយាណត្តិ ឬ
- កន្លែងដែលត្រូវសងមូលប្បទានប័ត្រនោះ ។

**សំគាល:** សមត្ថកិច្ច ដែលបានកំណត់ខាងលើនេះ ជាសមត្ថកិច្ចផ្តាច់មុខ ។

**១-ចំណុចដែលត្រូវសរសេរបញ្ជាក់នូវក្នុងដីកាសម្រេចដាស់តឿន** (មាត្រា ៣២៤ )

ដីកាសម្រេចដាស់តឿន ត្រូវសរសេរបញ្ជាក់នូវចំណុចដូចខាងក្រោមនេះ ៖

**ក**-ឈ្មោះ ឬនាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និង អាស័យដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

**ខ**-ដីកាសម្រេចដែលម្ចាស់បំណុលទាមទារឲ្យតុលាការចេញ និង អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារនេះ ។

**គ**-សេចក្តីបង្គាប់ឲ្យសងជាប្រាក់ ដែលមានកំណត់នូវចំនួន ។

ក្នុងដីកាសម្រេចដាស់តឿននៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវសរសេរបន្ថែមថា បើកូនបំណុលមិនបានដាក់ពាក្យប្តឹងតវ៉ាការដាស់តឿន ក្នុងអំឡុងពេល ២(ពីរ ) សប្តាហ៍ បន្ទាប់ពីបានទទួលការបញ្ជូននូវដីកាសម្រេចដាស់តឿននេះទេ នោះតុលាការ ត្រូវប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។

**២-ការលើកចោលនូវពាក្យសុំ** (មាត្រា ៣២២)

ក្នុងករណីដែលពាក្យសុំឲ្យចេញដីកាសម្រេចដាស់តឿន មានភាពផ្ទុយនឹងបញ្ញត្តិនៃមាត្រា ៣១៩ (ល័ក្ខខ័ណ្ឌនៃដីកាសម្រេចដាស់តឿន ) ឬមាត្រា ៣២០ ( ពាក្យសុំឲ្យចេញដីកាសម្រេចដាស់តឿន )ខាងលើនេះ ឬក្នុងករណីដែលមានភាពច្បាស់លាស់ថា គ្មានមូលហេតុក្នុងការទាមទារ ដោយគិតអំពីខ្លឹមសារនៃពាក្យសុំទេ *តុលាការ ត្រូវលើកចោលពាក្យសុំនេះ ដោយដីកាសម្រេច ។* បញ្ញត្តិនេះ ត្រូវយកមកអនុវត្តដែរ ចំពោះការទាមទារមួយភាគ ដែលមិនអាចចេញដីកាសម្រេចដាស់តឿនភាគនោះ ។

**កថាភាគទី៣៖ ការចេញដីកាសម្រេចដាស់តឿន** (មាត្រា ៣២៣)

ដីកាសម្រេចដាស់តឿន ត្រូវចេញដោយមិនបាច់សួរកូនបំណុល ។

កូនបំណុលអាចដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ទៅតុលាការដែលបានចេញដីកាសម្រេចដាស់តឿននោះ ។

**១-ការបញ្ជូនដីកាសម្រេចដាស់តឿន**(មាត្រា ៣២៥ )

តុលាការ ត្រូវជូនដំណឹងអំពីដីកាសម្រេចដាស់តឿន ទៅម្ចាស់បំណុល ហើយត្រូវបញ្ជូនដីកាសម្រេចដាស់តឿននោះ ទៅ កូនបំណុលផងដែរ ។

ដីកាសម្រេចដាស់តឿន ត្រូវមានអានុភាព នៅពេលដែលបានបញ្ជូនទៅដល់ដៃកូនបំណុល

ប្រសិនបើមិនអាចបញ្ជូនដីកាសម្រេចដាស់តឿន ដោយសារគ្មានលំនៅឋាន ទីសំណាក់ ទីស្នាក់ការ ទីកន្លែងអាជីវកម្ម របស់កូនបំណុល ឬលំនៅឋានរបស់អ្នកទទួលបន្ទុកភារកិច្ចចម្បង នៅទីកន្លែងដែលម្ចាស់បំណុលបានរាយការណ៍ទេ តុលាការ ត្រូវជូនដំណឹងអំពីហេតុការណ៍នេះ ទៅម្ចាស់បំណុល ។ ក្នុងករណីនេះ ប្រសិនបើម្ចាស់បំណុលមិនបានរាយការណ៍អំពីកន្លែងដែលត្រូវបញ្ជូន ក្រៅពីទីកន្លែងដែលខ្លួនបានរាយការណ៍ពីមុន *ក្នុងអំឡុងពេល ២(ពីរ) ខែ* ដោយគិតពីថ្ងៃដែលម្ចាស់បំណុលទទួលដំណឹង *ត្រូវចាត់ទុកថា ម្ចាស់បំណុលនោះបានដកពាក្យសុំឲ្យចេញដីកាសម្រេចដាស់តឿនវិញ ។*

ក្នុងអំឡុងពេលដែលបានកំណត់ក្នុងវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ៣ ខាងលើនេះ មិនអាចពន្យារពេលឡើយ ។

**២-ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន** (មាត្រា ៣២៧ )

ប្រសិនបើមានពាក្យសុំតវ៉ា ស្របច្បាប់ចំពោះដីកាសម្រេចដាស់តឿន នៅមុនពេលការប្រកាសឲ្យអនុវត្តជាបណ្ដោះអាសន្ន ដីកាសម្រេចដាស់តឿននោះ ត្រូវបាត់បង់អានុភាពក្នុងទំហំនៃការតវ៉ានោះ ។

ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះការទាមទារដែលទាក់ទងនឹងការតវ៉ាចំពោះដីកាសម្រេចដាស់តឿន ត្រូវចាត់ទុកថា បានដាក់ពាក្យបណ្ដឹងទៅតុលាការដែលបានកំណត់នៅមាត្រា ៣២០ ( ពាក្យសុំឲ្យចេញដីកាសម្រេចដាស់តឿន ) នៃក្រមនេះ នៅពេលដែលមានពាក្យសុំឲ្យចេញដីកាសម្រេចដាស់តឿន ។ ក្នុងករណីនេះ ប្រាក់សោហ៊ុយសម្រាប់នីតិវិធី ដាស់តឿន គឺជាផ្នែកមួយនៃប្រាក់ប្រដាប់ក្ដី ។

ហេតុដូច្នេះហើយ ប្រសិនបើកូនបំណុលមិនបានដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដែលបានធ្វើនៅមុនពេលការប្រកាសឲ្យអនុវត្តជាបណ្ដោះអាសន្ន ក្នុងអំឡុងពេល ២ (ពីរ )សប្ដាហ៍ បន្ទាប់ពីថ្ងៃដែលបានទទួលការបញ្ជូនដីកាសម្រេចដាស់តឿន ឬ បើដីកាសម្រេចដែលលើកចោលនូវពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន មុនការប្រកាសឲ្យអនុវត្តជាបណ្ដោះអាសន្ន បានចូលជាស្ថាពរ តុលាការ ត្រូវប្រកាសឲ្យអនុវត្តជាបណ្ដោះអាសន្ន ដោយកំណត់បញ្ជាក់បន្ថែមនូវប្រាក់សោហ៊ុយសម្រាប់នីតិវិធីដាស់តឿន លើដីកាសម្រេចដាស់តឿនដោយឆន្ទានុសិទ្ធិ ។

ការប្រកាសឲ្យអនុវត្តជាបណ្ដោះអាសន្ន ត្រូវបញ្ជាក់នៅក្នុងដីកាសម្រេចដាស់តឿន ហើយត្រូវបញ្ជូនទៅភាគី (មាត្រា ៣២៨ ) ។

<u>**២-១-ពាក្យសុំតវ៉ា ចំពោះដីកាសម្រេចដាស់តឿន មុនការប្រកាសឲ្យអនុវត្តជាបណ្ដោះអាសន្ន**</u>

ការចេញដីកាសម្រេចដាស់តឿន តុលាការ ធ្វើដោយមិនពិចារណា ដល់អត្ថិភាពនៃសិទ្ធិទាមទាររបស់ម្ចាស់បំណុលទេ ហើយក៏មិនចាំបាច់សួរកូនបំណុលដែរ (មាត្រា ៣២៣ កថាខណ្ឌទី ១ ) ។

ហេតុដូច្នេះហើយ ទើបច្បាប់បើកសិទ្ធិឲ្យកូនបំណុលអាចដាក់ពាក្យសុំតវ៉ានឹងដីកាសម្រេចដាស់តឿនបាន ។

<u>**២-២-ពាក្យសុំតវ៉ា ចំពោះដីកាសម្រេចដាស់តឿន ក្រោយការប្រកាសឲ្យអនុវត្តជាបណ្ដោះអាសន្ន**</u>(មាត្រា ៣២៩ )

ពាក្យសុំតវ៉ាដាស់តឿននៃកថាខណ្ឌទី ២ មាត្រា ៣២៣ (ការចេញដីកាសម្រេចដាស់តឿនជាអាទិ៍)នៃក្រមនេះ ចំពោះដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឲ្យអនុវត្តជាបណ្ដោះអាសន្ន ត្រូវធ្វើនៅក្នុងអំឡុងពេល ២ (ពីរ) សប្ដាហ៍ ក្រោយពីបានទទួលការបញ្ជូនដីកាសម្រេចដាស់តឿននោះ ។

អំឡុងពេលដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចពន្យារពេលបានឡើយ ។

www.facebook.com/7khmer
fb : Entertainment  And Knowledge

នៅពេលដែលកូនបំណុលទទួលដីកាសម្រេចដាស់តឿនភ្ជាប់ជាមួយការសម្រេចឲ្យអនុវត្តជាបណ្តោះអាសន្ន ហើយបានដាក់ពាក្យសុំតវ៉ាទៅតុលាការក្នុងរយៈពេល ២ សប្តាហ៍ ហើយនោះ តុលាការ នឹងត្រូវធ្វើ៖

<u>ក-ករណីដែលតុលាការទទួលពាក្យសុំតវ៉ា៖</u>

ប្រសិនបើមានពាក្យសុំតវ៉ាស្របច្បាប់ចំពោះដីកាសម្រេចដាស់តឿន នៅក្រោយការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន ការទាមទារដែលទាក់ទងនឹងការតវ៉ាចំពោះដីកាសម្រេចដាស់តឿន ត្រូវចាត់ទុកថា បានដាក់ពាក្យបណ្តឹងទៅតុលាការ ដែលបានចេញដីកាសម្រេចដាស់តឿននោះ នៅពេលមានពាក្យសុំឲ្យចេញដីកាសម្រេចដាស់តឿន ។ ករណីនេះ ប្រាក់សោហ៊ុយសំរាប់នីតិវិធីដាស់តឿន គឺជាផ្នែកមួយនៃប្រាក់ប្រដាប់ក្តី (មាត្រា ៣៣១) ។

*ដូច្នេះហើយ បើមានពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដែលស្របច្បាប់ នីតិវិធីដាស់តឿននោះ នឹងផ្ទេរទៅនីតិវិធីនៃបណ្តឹងធម្មតា ក្នុងទំហំនៃការតវ៉ានោះ ។* ***នៅក្នុងករណីនេះនីតិវិធីត្រៀមសំរាប់ការទាញហេតុផល នឹងចាប់ផ្តើមឡើង ។***

<u>ខ-ករណីដែលតុលាការលើកចោលពាក្យសុំតវ៉ា៖</u> (មាត្រា៣៣០)

ប្រសិនបើតុលាការយល់ឃើញថា ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដែលបានធ្វើនៅក្រោយការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ននោះ ***មិនស្របច្បាប់ទេ*** តុលាការត្រូវលើកចោលពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿននោះ ដោយដីកាសម្រេច ។

ចំពោះដីកាសម្រេចដែលបានកំណត់ ដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

ដូច្នេះនេះ ប្រសិនបើតុលាការសម្រេចចេញដីកាសម្រេចលើកចោលនូវពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន បានចូលជាស្ថាពរ ដីកាសម្រេចដាស់តឿននោះ នឹងមានអានុភាពអាចយកទៅអនុវត្តដោយបង្ខំបានដូចសាលក្រមសាលស្ថាពរ ដែរ (មាត្រា ៣៣៣) ។

## កថាភាគទី៤៖ កិច្ចការក្នុងការពិនិត្យពាក្យសុំឲ្យចេញដីកាសម្រេចដាស់តឿន

### ១៖ ការពិនិត្យពាក្យសុំឲ្យចេញដីកាសម្រេចដាស់តឿន

ពាក្យសុំឲ្យចេញដីកាសម្រេចដាស់តឿន ត្រូវធ្វើនៅការិយាល័យក្រឡាបញ្ជីនៃសាលាដំបូងដែលមានសមត្ថកិច្ច ។ ក្រឡាបញ្ជីដែលមានភារកិច្ចទទួលពាក្យសុំ ក្រឡាបញ្ជីត្រូវពិនិត្យពាក្យសុំ ថាតើវាដើរតាមលក្ខខណ្ឌដែលមានចែងនៅមាត្រា ៣១៩ (ល័ក្ខខ័ណ្ឌនៃដីកាសម្រេច

www.facebook.com/7khmer
fb : Entertainment And Knowledge

ដាស់តឿន) ៣២០ (ពាក្យសុំឲ្យចេញដីកាសម្រេចដាស់តឿន ) និង មាត្រា ៣២១(ការអនុវត្ត ដូចគ្នាតាមបញ្ញត្តិស្តីពីបណ្តឹង ) ដែរឬទេ ? បានន័យថាវាត្រូវគោរពតាមដូចតទៅៈ

- ការទាមទារ ត្រូវមានគោលបំណងឲ្យសងជាប្រាក់តែប៉ុណ្ណោះ
- ចំពោះការដីកា គឺធ្វើបានតែនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- មិនអាចធ្វើការបញ្ជូនដីកាតាមការផ្សាយជាសាធារណ:
- ត្រូវដាក់ពាក្យសុំនៅសាលាដំបូងដែលមានសមត្ថកិច្ច
- ត្រូវតែគ្មានភាពផ្ទុយ នឹងលក្ខណ:របស់ពាក្យ (មាត្រា ៣២១) ។

**២៖ ពិនិត្យលើចំណុចចាំបាច់ដែលត្រូវសរសេរក្នុងពាក្យសុំ**

- ត្រូវមានឈ្មោះម្ចាស់បំណុល (ភេទ អាយុ និង អាសយដ្ឋានបច្ចុប្បន្ន )
- កូនបំណុលជារូបវន្តបុគ្គល (ឈ្មោះ អាយុ ភេទ អាសយដ្ឋាន )
- កូនបំណុលជានីតិបុគ្គល (ទីស្នាក់ការកណ្តាល សាខា និង ទីលំនៅឋានរបស់អ្នកទទួលខុសត្រូវភារកិច្ចចម្បង)
- សំណើរបស់ម្ចាស់បំណុល ចំពោះតុលាការ
- អង្គហេតុចាំបាច់សម្រាប់បញ្ជាក់នូវការទាមទារ
- អង្គហេតុផ្សេងៗទៀតសម្រាប់បញ្ជាក់នូវការទាមទារ
- ថ្ងៃ ខែ ឆ្នាំ សរសេរពាក្យសុំ
- ស្នាមមេដៃរបស់អ្នកសុំ ។

**ផ្នែកទី ២៖ ការចាត់ចែងរក្សាការពារ**

**កថាភាគទី១៖ គោលបំណងនៃការចាត់ចែងរក្សាការពារ**(មាត្រា ៥៣០ )

ប្រសិនបើមានការបារម្ភថា ការអនុវត្តដោយបង្ខំមិនអាចធ្វើបាន ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្ត ឬប្រសិនបើមានការបារម្ភថា នឹងមានការខូចខាតធ្ងន់ធ្ងរ ឬគ្រោះថ្នាក់បន្ទាន់ដល់ឋានៈរបស់ភាគីណាមួយ ដោយសារមានវិវាទអំពីទំនាក់ទំនងនៃសិទ្ធិ បុគ្គលដែលមានបំណងចង់ការពារសិទ្ធិរបស់ខ្លួន អាចទាមទារការចាត់ចែងរក្សាការពារ ។

នេះសបញ្ជាក់ថា ការអនុវត្ត ត្រូវធ្វើឡើងដោយផ្អែកលើលិខិតបញ្ជាក់កាតព្វកិច្ច ដូចជាសាលក្រមស្ថាពរ ជាអាទិ៍ ហេតុនេះហើយ ដើម្បីឲ្យបានសាលក្រមនេះ ត្រូវដាក់ពាក្យបណ្តឹងរដ្ឋប្បវេណី ថែមទាំងត្រូវការពេលវេលាច្រើន ។ ក៏ប៉ុន្តែ មុនពេលទទួលសាលក្រមនេះ កូនបំណុលនៃការអនុវត្ត អាចលាក់ ឬផ្ទេរទ្រព្យសម្បត្តិរបស់ខ្លួន ដែលជាហេតុធ្វើឲ្យមិនអាច ឬ

www.facebook.com/7khmer
fb : Entertainment And Knowledge

ធ្វើឲ្យមានការលំបាកនឹងធ្វើការអនុវត្តដោយបង្ខំនៅពេលក្រោយបាន ឬមួយក៏ភាគីណាម្ខាង អាចទទួលនូវការខូចខាតធ្ងន់ធ្ងរ ឬអាចទទួលនូវគ្រោះថ្នាក់ធ្ងន់ធ្ងរដល់ឋានៈរបស់ខ្លួន ដោយសារវិវាទពាក់ព័ន្ធនឹងទំនាក់ទំនងនៃសិទ្ធិ រវាងភាគីទាំងសងខាង ។ ក្នុងករណីនេះ បុគ្គលដែលចង់ការពារសិទ្ធិរបស់ខ្លួននោះ អាចទាមទារឲ្យចាត់ចែងរក្សាការពារសិទ្ធិ ឬទំនាក់ទំនងគតិយុត្តរបស់ខ្លួនបាន ។

**កថាភាគទី ២៖ ប្រភេទនៃការចាត់ចែងរក្សាការពារ**

ការចាត់ចែងរក្សាការពារសំដៅទៅលើការចាត់ចែតនីមួយៗ ដែលមានខ្លឹមសារដូចកំណត់នៅក្នុងចំណុចនីមួយៗ ខាងក្រោមនេះ៖

**-ការរឹបអូសជាបណ្ដោះអាសន្ន**

ការរឹបអូសជាបណ្ដោះអាសន្នអាចធ្វើទៅលើ ចលនវត្ថុ អចលនវត្ថុ ឬ នាវា បានតែចំពោះសិទ្ធិលើបំណុលប៉ុណ្ណោះ ហើយមានគោលបំណងទាមទារជាប្រាក់ ។

ឧ៖ **ខ** ជំពាក់ប្រាក់ **ក** ចំនួន ២០ លានរៀល ។ **ខ** ជាកូនបំណុលមានប្រាក់នៅធនាគារ B ដែលមានតម្លៃប្រហែល ២៥លានរៀល ។ នៅក្នុងនីតិវិធីនៃបណ្ដឹងទាមទារប្រាក់កំចីនេះ ត្រូវចំណាយពេលវេលាច្រើន ករណីនេះ ម្ចាស់បំណុល **ក** អាចនឹងបាត់បង់ផលប្រយោជន៍ ក្នុងករណីដែល **ខ** បានទៅធនាគារ ហើយដកយកប្រាក់បញ្ញើទាំងនោះទៅចំណាចអស់ ។ ដូច្នេះដើម្បីការពារផលប្រយោជន៍របស់ខ្លួន **ក** ត្រូវដាក់ពាក្យសុំឲ្យទៅតុលាការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ននូវគណនីធនាគាររបស់ **ខ** ដើម្បីការអនុវត្តសិទ្ធិរបស់ម្ចាស់បំណុល **ក** នៅពេលគាត់ឈ្នះក្ដី ។ ដូច្នេះ ក្រោយមានដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន នូវគណនីធនាគាររបស់ **ខ** ហើយ **ខ** នឹងមិនអាចទៅធនាគារយកប្រាក់បញ្ញើរបស់ខ្លួនបានទៀតទេ ។

**-ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ**

ការចាត់ចែងដែលរក្សាទុកនូវស្ថានភាពបច្ចុប្បន្ន នៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ ក្នុងករណីដែលមានការប្ដារម្ភ ថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិ ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ ។ នេះចង់បានន័យថា ម្ចាស់បំណុលមិនមានគោលបំណងទាមទារឲ្យកូនបំណុលឲ្យសងជាប្រាក់ទេ តែទាមទារឲ្យកូនបំណុលប្រគល់ការគ្រប់គ្រងវត្ថុ ដែលជាកម្មសិទ្ធិរបស់ខ្លួនមកឲ្យខ្លួនគ្រប់គ្រងវិញ ។

ឧ៖ **ក** បានទិញរថយន្ត ពី **ខ** ក្នុងតំលៃ ១០ លានរៀល ។ **ក** បានប្រគល់ប្រាក់គ្រប់ចំនួនឲ្យ **ខ** រួចរាល់អស់ហើយ រង់ចាំតែការផ្ទេរឈ្មោះ ពី **ខ** មក **ក** នឹងការប្រគល់រថយន្តប៉ុណ្ណោះ ។ ប៉ុន្តែក្រោយមក ដល់កាលកំណត់ដែលត្រូវប្រគល់រថយន្តមកឲ្យខ្លួនតាមកិច្ចសន្យាទិញ-លក់នោះ ។ នៅក្នុងនីតិវិធីនៃបណ្ដឹងនេះ តុលាការ ត្រូវចំណាយពេលច្រើនក្នុងការកំណត់នូវអត្ថិ

www.facebook.com/7khmer
fb : Entertainment And Knowledge

ភាព ឬនត្តិភាពនៃសិទ្ធិរបស់ **ក** ។ ដូច្នេះនៅក្នុងអំឡុងពេលនេះ **ខ**អាចនឹងលក់រថយន្តនោះទៅតតិយជនផ្សេងទៀត បាន ដែលជាហេតុធ្វើឲ្យ **ក** ខូចខាតផលប្រយោជន៍យ៉ាងធ្ងន់ធ្ងរ ដូច្នេះ **ក** ត្រូវដាក់ពាក្យសុំឲ្យតុលាការចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នចំពោះរថយន្តនោះ ដើម្បីកុំឲ្យ **ខ** លក់ ឬផ្ទេររថយន្តទៅតតិយជនបាន ។ តាមរយៈនេះ រថយន្តនោះនឹងមិនបាត់បង់ ឬមិនត្រូវបានផ្ទេរទៅតតិយជននោះទេ ។ ប្រសិនបើ តុលាការរកឃើញនូវអត្ថិភាពនៃសិទ្ធិរបស់ **ក** លើរថយន្តនោះ **ក** នឹងអាចអនុវត្តសិទ្ធិលើរថយន្តនោះបាន ។

**-ការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈបណ្ដោះអាសន្ន ៖**

ជាការចាត់ចែងដែលកំណត់ស្ថានភាពជាបណ្ដោះអាសន្នរហូតដល់សាលក្រម ឬសាលដីកាចូលជាស្ថាពរ ក្នុងករណីដែលមានភាពចាំបាច់ដើម្បីជៀសវាងការខូចខាតធ្ងន់ធ្ងរ ឬគ្រោះថ្នាក់បន្ទាន់ដែលនឹងកើតឡើងដល់ម្ចាស់បំណុល ចំពោះទំនាក់ទំនងគតិយុត្តដែលមានវិវាទ ។

គេតែងប្រើការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន ចំពោះវិវាទការងារ សេវាកម្ម ឬប្រភេទកិច្ចសន្យាមួយចំនួន ។

ឧ៖ **ក** មានដីឡូតិ៍ជាកម្មសិទ្ធិរបស់ខ្លួន ក្រោយមកមានឈ្មោះ **ខ** បានមកសាងសង់សំណង់ជាផ្ទះនៅលើដីឡូតិ៍នោះ ។ ដូច្នេះ **ក** គាត់ក៏ដាក់ពាក្យបណ្ដឹងអង្គសេចក្ដីទៅតុលាការដោយសុំរុះរើសំណង់ទាំងនោះចេញ ។ នៅក្នុងករណីនេះ **ក** ឈ្នះក្ដី **ក** អាចទៅរុះរើសំណង់ទាំងនោះបាន ក៏ប៉ុន្តែវាគ្រាន់តែមានការលំបាកក្នុងការរុះរើ ពីព្រោះសំណង់បានសាងសង់ជាច្រើន ឬក៏សាងសង់ហើយទាំងស្រុង ។ ដូច្នេះ **ក** ត្រូវដាក់ពាក្យសុំតាំងពីដំបូងដើម្បីហាមឃាត់មិនឲ្យ **ខ** បន្តការសាងសង់ទេ គឺត្រូវបញ្ឈប់ការសាងសង់ត្រឹមនេះ ។ ការស្នើសុំបែបនេះ ប្រសិនបើ **ខ** ទើបតែចាប់ផ្ដើមទេ នៅពេលដែល **ក** បានឈ្នះក្ដី **ក** នឹងមានភាពងាយស្រួលក្នុងការរុះរើសំណង់ដ៏តិចតួចទាំងនោះ ចេញ ។ ប្រសិនបើ **ក** មិនបានសុំទេដូច្នេះទេនោះ **ក** នឹងជួបការលំបាកដូចបានលើកពីខាងដើមនៃឧទាហរណ៍នេះ ។

ឧទី២៖ **ក** តែងតែធ្វើដំណើរចេញពីផ្ទះតាមផ្លូវតូចដើម្បីទៅដល់ផ្លូវធំ ស្រាប់មានពេលនោះ **ខ** បានមកសាងសង់សំណង់ដោយបិទផ្លូវតូចនោះ ។ ករណីនេះ **ក** ត្រូវដាក់ពាក្យសុំទៅតុលាការដើម្បីពិចារណាអំពីការសាងសង់នេះ ដោយសុំឲ្យតុលាការចេញដីកាសម្រេចហាមឃាត់កាសាងសង់ជាបណ្ដោះអាសន្ន ។

**១-ស្ថាប័នចាត់ចែងរក្សាការពារ** (មាត្រា ៥៣២)

ដីកាសម្រេចរក្សាកាពារ ត្រូវធ្វើឡើង ដោយតុលាការតាមពាក្យ សុំ ។

www.facebook.com/7khmer
fb : Entertainment And Knowledge

ការអនុវត្តការចាត់ចែងរក្សាការពារ ត្រូវធ្វើឡើងដោយតុលាការ ឬអាជ្ញាសាលាតាមពាក្យសុំ ។

តុលាការ ដែលត្រូវអនុវត្តការចាត់ចែងរក្សាការពារ តាមបញ្ញត្តិនៃគន្ថីនេះ ត្រូវហៅថាតុលាការអនុវត្តការរក្សាការពារ ។

បញ្ញត្តិនៃកថាខណ្ឌទី ៤ នៃមាត្រា ៣៣៦ (ស្ថាប័នអនុវត្ត) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះការអនុវត្តការចាត់ចែងរក្សាការពារ ដែលធ្វើឡើងដោយអាជ្ញាសាលា ។

### ២-ការចាត់ចែងរក្សាការពារ មាន ២ ដំណាក់កាលៈ

#### ២-១-ការសម្រេចរក្សាការពារ

នីតិវិធីចាត់ចែងរក្សាការពារ ត្រូវចាប់ផ្តើមពីម្ចាស់បំណុល ដាក់ពាក្យសុំទៅតុលាការដើម្បីសុំឲ្យចេញដីកាសម្រេចរក្សាការពារសិន ។

**ក-ពាក្យសុំឲ្យចេញដីកាសម្រេចរក្សាការពារ**

ពាក្យសុំឲ្យចេញដីកាសម្រេចរក្សាការពារ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ (មាត្រា ៥៣៤ ចំណុច ក) ។

ដីកាសម្រេចក្នុងការចាត់ចែងរក្សាការពារ ត្រូវធ្វើឡើងដោយតុលាការតាមពាក្យសុំ ។ និយាយម្យ៉ាងទៀត តុលាការអាចចេញដីកាសម្រេចរក្សាការពារបាន លុះត្រាតែមាន ពាក្យសុំរបស់ភាគីម្ខាងទើបជាការត្រឹមត្រូវតាមនីតិវិធី ។ ខ្លឹមសារដែលមាននៅក្នុងពាក្យសុំឲ្យចេញដីការក្សាការពារ ត្រូវសរសេរឲ្យបានច្បាស់លាស់ទៅលើចំណុច សំខាន់ៗដែលរួមមាន ៖

១. ឈ្មោះ និង អាសយដ្ឋាន របស់ភាគី និង អ្នកតំណាងដែលច្បាប់បានកំណត់៖
   a. អ្នកណាជាអ្នកប្តឹងសុំ ? និង មានអាសយដ្ឋាននៅទីណា ?
   b. អ្នកតំណាងដែលច្បាប់កំណត់នោះជានរណា ?
   c. គួរតែមានសរសេរលេខទូរស័ព្ទ(ព្រោះវាមានភាពងាយស្រួល) ។

២. ខ្លឹមសារលំអិតនៃដីកាសម្រេចរក្សាការពារនៃដីការក្សាការពារដែលអ្នកសុំទាមទារ
   a. ដីការក្សាការពារ ដើម្បីធ្វើការរឹបអូសជាបណ្តោះអាសន្ន
   b. ដីការក្សាការពារ ការចាត់ចែងជាបណ្តោះអាសន្ន ចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ
   c. ដីការក្សាការពារ ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន[៤]

៣. សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ

---

[៤] -សំគាល់៖ ខ្លឹមសារនៃការចេញដីការក្សាការពារ គឺជាកម្មវត្ថុនៃការចេញដីកាសម្រេចរក្សាការពារ ។

www.facebook.com/7khmer
fb : Entertainment And Knowledge

a. សរសេរអំពីអង្គហេតុដែលជាមូលហេតុនៃការទាមទារ

b. អង្គហេតុសំខាន់ៗផ្សេងទៀត បើមាន (គោលបំណងដើម្បីបង្កើតសិទ្ធិ) ។

៤. ភាពចាំបាច់នៃដីកាសម្រេចរក្សាការពារ

a. សរសេរឲ្យបានច្បាស់លាស់អំពីតំរូវការចាំបាច់ដើម្បីឲ្យចៅក្រមចេញដីការក្សាការពារ ។

៥. ភស្តុតាងតាមហេតុនីមួយៗ

៦. បញ្ជីសារពើភ័ណ្ឌ (ឯកសារដែលភ្ជាប់ជាមួយពាក្យសុំ )៖

a. បញ្ជី ភាគី

b. បញ្ជីសិទ្ធិលើបំណុល

c. បញ្ជីសារពើភ័ណ្ឌអំពីទ្រព្យដែលត្រូវរឹបអូស

d. បញ្ជីសិទ្ធិលើបំណុលដែលនឹងត្រូវបានរក្សារការពារ ។

**សំគាល់៖**

ពាក្យសុំដែលបានកំណត់ខាងក្រោមនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ៖(មាត្រា ៥៣៨)

- ពាក្យសុំឲ្យចេញដីកាសម្រេចរក្សាការពារ
- ពាក្យបណ្តឹងជំទាស់ ចំពោះដីកាសម្រេចលើកចោលពាក្យសុំឲ្យចេញដីកាសម្រេចរក្សាការពារ
- ពាក្យសុំតវ៉ាចំពោះការរក្សាការពារ
- ពាក្យសុំឲ្យលុបចោលដីកាសម្រេចរក្សាការពារ
- ពាក្យបណ្តឹងជំទាស់ ដែលបានកំណត់នៅមាត្រា ៥៦១ (បណ្តឹងជំទាស់) នៃក្រមនេះ ។
- ពាក្យសុំឲ្យអនុវត្តការរក្សាការពារ ។

ហេតុដូច្នេះហើយ ប្រសិនបើមានពាក្យសុំឲ្យចេញដីកាសម្រេចរក្សារការពារ បានដាក់មកដល់តុលាការដែលមានសមត្ថកិច្ច ពេលនេះ តុលាការត្រូវ៖

**ក-១-ករណីដែលតុលាការសម្រេចចេញដីកាសម្រេចរក្សាការពារ**

តុលាការដែលមានសមត្ថកិច្ចអាចចេញដីកាសម្រេចរក្សាការពារបាន ដោយហេតុថាលក្ខខណ្ឌនៃពាក្យសុំឲ្យចេញដីកាសម្រេចរក្សាការពារ វាមានហេតុផលច្បាស់លាស់ ដែលអាចទទូលយកបាន ។ ក្នុងករណីនេះ តុលាការដែលមានសមត្ថកិច្ច ត្រូវ៖

- ជូនដំណឹងទៅកូនបំណុល ៖

www.facebook.com/7khmer
fb : Entertainment  And Knowledge

    - កូនបំណុលអាចដាក់ពាក្យ***សុំតវ៉ា***បាន (មាត្រា ៥៥០)
  - ជូនដំណឹងទៅម្ចាស់បំណុល ៖
    - បង្គាប់ឲ្យម្ចាស់បំណុលដាក់បណ្ដឹងអង្គសេចក្ដី ហើយឲ្យដាក់ឯកសារដែលបញ្ជាក់អំពីការដាក់ពាក្យបណ្ដឹងនោះ ក្នុងអំឡុងពេលដែលទទួលស្គាល់ថាសមរម្យ ដែលអំឡុងពេលនេះ ត្រូវមានរយៈពេលមិនតិចជាង ២ (ពីរ) សប្ដាហ៍ (មាត្រា ៥៥៧) ។

**<u>ក-២-ករណីដែលតុលាការសម្រេចលើកចោលពាក្យសុំ៖</u>**

តុលាការដែលមានសមត្ថកិច្ច នឹងលើកចោលពាក្យសុំឲ្យចេញដីកាសម្រេចរក្សាការពារបាន ដោយសារតែពាក្យសុំគ្មានហេតុផល ត្រឹមត្រូវ និង មិនស្របតាមច្បាប់កំណត់ ។

ក្នុងករណីនេះ តុលាការដែលមានសមត្ថកិច្ច ត្រូវ៖

- ជូនដំណឹងទៅ កូនបំណុល
- ជូនដំណឹងទៅ ម្ចាស់បំណុល ៖
  - ម្ចាស់បំណុលអាចប្ដឹង***ជំទាស់***បានក្នុងអំឡុងពេល២ (ពីរ) សប្ដាហ៍ ចាប់ពីថ្ងៃដែលខ្លួនបានទទួលការជូនដំណឹង ។ ហើយអំឡុងពេលនេះ មិនអាចពន្យារបានឡើយ (មាត្រា ៥៤៨) ។

**<u>ខ-ការសុំតវ៉ារបស់កូនបំណុលចំពោះការចេញដីកាសម្រេចរក្សាការពារ៖</u>**

នៅក្នុងដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ របស់កូនបំណុលករណីនេះ តុលាការត្រូវ ៖

**<u>ខ-១-ករណីតុលាការទទួលស្គាល់ពាក្យសុំតវ៉ារបស់កូនបំណុល៖</u>**

- តុលាការនឹងបង្គាប់ឲ្យកែតម្រូវ ខ្លឹមសារនៃដីកា
- អាចឲ្យកូនបំណុលដាក់ប្រាតិភោគ ឬមិនឲ្យដាក់៖
- តុលាការអាចលុបចោលដីកាសម្រេចរក្សាការពារ ហើយបើយល់ឃើញថា ចាំបាច់ពិសេស តុលាការអាចប្រកាសថា ដីកាសម្រេចនោះមានអានុភាពអនុវត្តភ្លាមៗ
- តុលាការ ត្រូវបញ្ជូនដីកាសម្រេចរក្សាការពារទៅភាគី(មាត្រា ៥៤៣) និងទុកពេលឲ្យម្ចាស់បំណុលប្ដឹងតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ក្នុងអំឡុង ពេល ២ (ពីរ) សប្ដាហ៍ ចាប់ពីថ្ងៃដែលបានទទួលការបញ្ជូនដីកា (មាត្រា ៥៦១) ។

**<u>ខ-២-ករណីដែលតុលាការលើកចោលពាក្យសុំតវ៉ារបស់កូនបំណុល៖</u>**

- តុលាការ ក៏ត្រូវបញ្ជូនដីកាសម្រេចរក្សាការពារទៅភាគី ផងដែរ ។

www.facebook.com/7khmer
fb : Entertainment  And Knowledge

- ទុកពេលឲ្យកូនបំណុលប្ដឹងតវ៉ាដោយឲ្យដាក់ប្រាតិភោគបាន ។

<u>**គ-បណ្ដឹងតវ៉ារបស់តតិយជនចំពោះពាក្យសុំឲ្យចេញដីកាសម្រេចរក្សាការពារ**</u>(ម ៥៦៣)

បណ្ដឹងតវ៉ារបស់តតីយជន ចំពោះដីកាសម្រេចរក្សាការពារដែលសាលាឧទ្ធរណ៍បានធ្វើក្នុងនាមជាតុលាការអនុវត្តរក្សាការពារ ***ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាដំបូង ដែលមានសមត្ថកិច្ច*** លើទីកន្លែង ដែលវត្ថុ ត្រូវរឹបអូសជាបណ្ដោះអាសន្ន ឬវត្ថុដែលជាកម្មវត្ថុនៃវិវាទស្ថិតនៅ (មាត្រា ៥៦៣ ) ។

**សំគាល់៖** បើបណ្ដឹងតវ៉ារបស់តតីយជនចំពោះពាក្យសុំឲ្យចេញដីកាសម្រេចរក្សាការពារ ដោយដីកាសម្រេចនេះ ចេញដោយសាលាឧទ្ធរណ៍ (*ការចេញដីកាសម្រេចដោយសាលាឧទ្ធរណ៍ មិនអាចទទួលបានទេ ព្រោះតុលាការនេះ មិនមានសមត្ថកិច្ចដោះស្រាយបានទេ)* រីឯការចេញដីកាសម្រេចដោយសាលាដំបូង គឺអាចទទួលដោះស្រាយបណ្ដឹងនោះ ព្រោះ សាលាដំបូងនេះ មានសមត្ថកិច្ចដោះស្រាយ ។

<u>**គ-ការលុបចោលដីកាសម្រេចរក្សាការពារ**</u> (មាត្រា ៥៥៧ )

១. ម្ចាស់បំណុលមិនដាក់បណ្ដឹងអង្គសេចក្ដី ក្រោយពីបានទទួលដីកាសម្រេចរក្សាការពារ ២ (ពីរ) សប្ដាហ៍ កន្លងហួសទៅ បើមានពាក្យសុំរបស់កូនបំណុល តុលាការ លុបចោលដីកាសម្រេចរក្សាការពារ ។

២. បណ្ដឹងអង្គសេចក្ដី ត្រូវបានម្ចាស់បំណុលដកវិញ ឬត្រូវបានតុលាការទទួលធ្វើអង្គសេចក្ដីលើកចោលបណ្ដឹងអង្គសេចក្ដី ។

៣. ទោះបីម្ចាស់បំណុលមិនបានដាក់ពាក្យប្ដឹងអង្គសេចក្ដីក៏ដោយ ៖

   a. បើមាននីតិវិធីមជ្ឈត្តកម្ម ចាប់ផ្ដើមដំណើរការរហូតដល់មានសេចក្ដីសម្រេចមជ្ឈត្តករ ត្រូវចាត់ទុកថាបានដាក់បណ្ដឹងអង្គសេចក្ដីហើយ ។ តុលាការអនុវត្តរក្សារការពារ មិនលុបចោលដីកាសសម្រេចរក្សាការពារ ដោយមូលហេតុថាមិនបានដាក់ពាក្យអង្គសេចក្ដីទេ ។

   b. បើនីតិវិធីមជ្ឈត្តកម្ម ត្រូវបរាជ័យ ហើយបញ្ចប់ដោយគ្មានចេញសេចក្ដីសម្រេចអ្វីទាំងអស់ ម្ចាស់បំណុល ត្រូវដាក់ពាក្យបណ្ដឹងអង្គសេចក្ដីមិនឲ្យហួសពី ២ (ពីរ) សប្ដាហ៍ គិតពីថ្ងៃនីតិវិធីមជ្ឈត្តកម្ម ត្រូវបញ្ចប់ ។ បើហួសរយៈពេលនេះ តុលាការអនុវត្តរក្សាការពារ ត្រូវលុបចោលដីការបស់ខ្លួន ។

៤. ដីកាសម្រេចលុបចោល ដីកាសម្រេចរក្សាការពារតាមពាក្យសុំរបស់កូនក្ដីចូលជាស្ថាពរ

www.facebook.com/7khmer
fb : Entertainment  And Knowledge

៥. ដោយមានការផ្លាស់ប្តូរស្ថានភាព (មាត្រា ៥៥៨ )

៦. ករណីចាំបាច់នៃការរក្សាការពារ ត្រូវបានរលត់ ៖

a. ដោយការសង

b. កូនបំណុលបានដាក់ប្រាតិភោគតាមការតម្រូវរបស់តុលាការ

**២-២-ការអនុវត្តរក្សាការពារ**

ការអនុវត្តរក្សាការពារ ត្រូវធ្វើឡើងដោយផ្អែកលើឯកសារចម្លងយថាភូតនៃដីកាសម្រេចរក្សាការពារ ។ ប៉ុន្តែការអនុវត្តរក្សាការពារចំពោះ ឬសម្រាប់ជនក្រៅពីភាគី ដែលត្រូវបានកំណត់នៅក្នុងដីកាសម្រេចរក្សាការពារ ត្រូវធ្វើឡើង ដោយផ្អែកលើឯកសារចម្លងយថាភូតនៃដីកាសម្រេចរក្សាការពារ ដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្ត ។

ការអនុវត្តរក្សាការពារ មិនត្រូវធ្វើឡើយ បើអំឡុងពេល ២(ពីរ) សប្តាហ៍ បានកន្លងហួសចាប់ពីថ្ងៃដែលដីកាសម្រេចរក្សាការពារ ត្រូវបានបញ្ជូនទៅម្ចាស់បំណុល ។

ទោះបីនៅមុនពេលដែលដីកាសម្រេចរក្សាការពារ ត្រូវបានបញ្ជូន ទៅកូនបំណុលក៏ដោយក៏ការអនុវត្តរក្សាការពារអាចធ្វើបានដែរ (មាត្រា ៥៦២ ) ។

**សំគាល់៖** ការចាប់ផ្តើមអនុវត្តរក្សាការពារ ត្រូវមិនឲ្យហួស ពី ២ (ពីរ) សប្តាហ៍ទេ ក្រោយពីការចាប់ផ្តើម ហើយការអនុវត្តអាចបន្តរហូតដល់ហួសរយៈពេល ២ សប្តាហ៍ក៏បាន ។ ដោយត្រូវការរក្សាការសំងាត់និងភាពបន្ទាន់ ការអនុវត្តរក្សាការពារមិនចាំបាច់រង់ចាំកូនបំណុលទទួលដីកាទេ ព្រោះកូនបំណុលអាចរកលេសផ្សេងៗ កុំឲ្យដីកាបញ្ជូលដល់ដៃរបស់ខ្លួន ។ ចំពោះកូនបំណុលទី ៣ ក្រោយពីបានទទួលដីកាហើយ ការអនុវត្តរក្សាការពារ អាចធ្វើពេលណាក៏បានមិនចាំបាច់កំណត់ពេលវេលាទេ ។

**ក-ការរឹបអូសជាបណ្តោះអាសន្ន សិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ចំពោះចលនវត្ថុ** (មាត្រា ៥៦៥ និង ៥៤៥ )

ការរឹបអូសជាបណ្តោះអាសន្ន ចំពោះចលនវត្ថុ ត្រូវធ្វើតាមរបៀបកាន់កាប់វត្ថុដែលជាកម្មវត្ថុ ដោយអាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលជាកម្មវត្ថុនោះស្ថិតនៅ ។

អាជ្ញាសាលាត្រូវផ្ញើរប្រាក់ដែលបានមកពីការអនុវត្តជាបណ្តោះអាសន្ន នៅតុលាការដែលខ្លួនស្ថិតនៅ ។

បើមានការព្រួយបារម្ភ ថាចលនវត្ថុដែលការរឹបអូសជាបណ្តោះអាសន្ន ត្រូវបានអនុវត្តនឹងចុះតំលៃយ៉ាងខ្លាំង ឬបើត្រូវការសោហ៊ុយច្រើនដើម្បីរក្សាទុកចលនវត្ថុនោះ អាជ្ញាសាលា

www.facebook.com/7khmer
fb : Entertainment And Knowledge

ត្រូវលក់ចលនវត្ថុនោះ តាមនីតិវិធីលក់នៃការអនុវត្តចំពោះចលនវត្ថុដែលបានកំណត់ នៅក្នុងផ្នែកទី ២ ជំពូកទី ២ នៃគន្ថីទី ៦ នៃក្រមនេះ តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការរឹបអូសជាបណ្តោះអាសន្ន ឬកូនបំណុល ហើយផ្ញើរប្រាក់ដែលបានមកពីការលក់នោះទៅតុលាការ ដែលខ្លួនស្ថិតនៅ ។

បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៣៨៤ (ការចាប់ផ្តើមអនុវត្តចំពោះចលនវត្ថុ) ពីមាត្រា ៣៨៥ (ការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត) ដល់មាត្រា ៣៩២(ការហាមឃាត់មិនឲ្យរឹបអូសក្នុងករណីដែលប៉ានប្រមាណឃើញថា គ្មានចំនួនសេសសល់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ ។

ហេតុនេះហើយ ការរឹបអូសជាបណ្តោះអាសន្ន ចំពោះចលនវត្ថុ ត្រូវអនុវត្តដោយអាជ្ញាសាលា ។ ប៉ុន្តែ ក្នុងករណីដែលកម្មវត្ថុនៃការរឹបអូសជាប្រាក់ ពុំត្រូវផ្តល់ផ្ទាល់ទៅម្ចាស់បំណុលនៃការរឹបអូសទេ គឺត្រូវផ្ញើរទៅតុលាការ ហើយក្នុងករណីដែលកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន ច្បាស់ជានឹងចុះថោក ឬជាវត្ថុដែលត្រូវការសោហ៊ុយដើម្បីរក្សាទុក ត្រូវធ្វើការលក់ជាបណ្តោះអាសន្ន និង ត្រូវផ្ញើរប្រាក់លក់នោះទៅតុលាការ ។ ម្យ៉ាងទៀត អំពីការរឹបអូសជាបណ្តោះអាសន្នចំពោះរថយន្ត និង ទោចក្រយានយន្តដែលមានចុះបញ្ជី បញ្ញត្តិនៃមាត្រា ៣៨៧ (បទបញ្ញត្តិពិសេសស្តីពីរថយន្ត ជាអាទិ៍ ដែលបានចុះបញ្ជី ) ត្រូវយកមកអនុវត្ត ហេតុដូច្នេះ អាជ្ញាសាលាដែលបានអនុវត្តរឹបអូសជាបណ្តោះអាសន្ន ត្រូវផ្ទុកផ្តាក់ឲ្យសរសេរនូវហេតុការណ៍នៃការរឹបអូស ចូលទៅក្នុងសៀវភៅចុះបញ្ជី ហើយការរឹបអូស មានអនុភាពនៅពេលដែលបានសរសេរហេតុនេះហើយ ។

**<u>ខ-ការរឹបអូសជាបណ្តោះអាសន្ន ចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិដទៃទៀតដែលមានគោលបំណងសងជាប្រាក់ (មាត្រា ៥៦៦)</u>**

ការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ចំពោះសិទ្ធិលើបំណុលដែលកំណត់នៅក្នុងមាត្រា ៤០២ (អត្ថន័យនៃការអនុវត្តចំពោះសិទ្ធិលើបំណុល និង តុលាការអនុវត្ត) នៃក្រមនេះ ត្រូវធ្វើតាមរបៀបដែលតុលាការអនុវត្តរក្សាការពារចេញដីកាសម្រេចដែលហាមឃាត់មិនឲ្យកូនបំណុលទី ៣ សងទៅកូនបំណុល ។

ចំពោះការអនុវត្តរឹបអូសជាបណ្តោះអាសន្នដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះ តុលាការដែលបានចេញដីកាសម្រេចរឹបអូសបណ្តោះអាសន្ន ត្រូវមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ ។

www.facebook.com/7khmer
fb : Entertainment  And Knowledge

ក្នុងករណីដែលការរឹបអូសជាបណ្តោះអាសន្ន ត្រូវបានអនុវត្តចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឲ្យសងជាប្រាក់ បើកូនបំណុល ទី៣ បានផ្ញើប្រាក់ដែលស្មើនឹងចំនួនប្រាក់នៃសិទ្ធិលើបំណុលនៅតុលាការ ត្រូវចាត់ទុកថា កូនបំណុលបានផ្ញើប្រាក់ដែលស្មើនឹងចំនួនប្រាក់ដែលបានកំណត់តាមបញ្ញត្តិនៃមាត្រា ៥៤៧ (ប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន) នៃក្រមនេះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះភាគីដែលលើសពីចំនួនប្រាក់នោះ ។

បញ្ញត្តិនៃកថាខណ្ឌទី១ និង កថាខណ្ឌទី ២ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ។

បញ្ញត្តិនៃកថាខណ្ឌទី ២ ទី ៣ ទី ៦ ទី ៧ ទី ៨ ទី ១០ និង កថាខណ្ឌទី ១១ នៃមាត្រា ៥០៣ (ដីកាសម្រេចរឹបអូស) បញ្ញត្តិពីមាត្រា៥០៤( ទំហំនៃការរឹបអូស) ដល់មាត្រា ៥០៨ (ការជូនដំណឹងអំពីការដកពាក្យសុំ ជាអាទិ )មាត្រា ៥១១ (ការផ្ញើប្រាក់ទុកដោយកូនបំណុលទី ៣) និង មាត្រា៥១៦ (ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ។

**គ-ការរឹបអូសជាបណ្តោះអាសន្ន ដែលមានគោលបំណងសងជាប្រាក់ចំពោះអចលនវត្ថុ (មាត្រា ៥៦៧ )**

ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៥១៧ (កម្មវត្ថុ និង វិធីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ )នៃក្រមនេះ ត្រូវធ្វើតាមរបៀបចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ។

ចំពោះការអនុវត្តរឹបអូសជាបណ្តោះអាសន្ន តុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ ។

ក្រឡាបញ្ជី ត្រូវផ្ទុកផ្តាក់ឲ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ។

បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៥២០ (ការផ្ទុកផ្តាក់ឲ្យចុះបញ្ជីអំពីការរឹបអូស ជាអាទិ៍ វាក្យខណ្ឌទី ១ កថាខណ្ឌទី ៣នៃមាត្រា ៥២១ (អានុភាពនៃការរឹបអូស ) កថាខណ្ឌទី ១ នៃមាត្រា ៥២៤ (ដីកាសម្រេចចាប់ផ្តើមត្រួតគ្នា ) មាត្រា ៥២៥ (ដីកាសម្រេចចាប់ផ្តើមត្រួតគ្នានៃការអនុវត្តសិទ្ធិប្រាតិភោគ និង ការអនុវត្តចំពោះអចលនវត្ថុ )មាត្រា ៥២៧ (ការលុបចោលនីតិវិធីនៃការលក់ដោយបង្ខំដោយសារការបាត់បង់ ជាអាទិ៍ នៃអចលវត្ថុ ) និងមាត្រា ៥២៨ (ការផ្ទុក

www.facebook.com/7khmer
fb : Entertainment And Knowledge

ផ្ដាក់ឲ្យលុបការចុះបញ្ជីអំពីការរឹបអូស )នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ។

**ឃ-ការរឹបអូសជាបណ្ដោះអាសន្ន ដែលមានគោលបំណងសងជាប្រាក់ចំពោះនាវា (មាត្រា ៥៦៨ )**

ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះនាវា ត្រូវធ្វើតាមរបៀបចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន ឬតាមរបៀបដែលបង្គាប់ឲ្យអាជ្ញាសាលាដកហូតលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ ហើយផ្ដល់លិខិតនោះទៅ តុលាការអនុវត្តរក្សាការពារ ។ របៀបទាំងនេះ អាចអនុវត្តរួមគ្នាបាន ។

ចំពោះការអនុវត្តរឹបអូសជាបណ្ដោះអាសន្នតាមរបៀបចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន តុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ត្រូវមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ រីឯការអនុវត្តរឹបអូសជាបណ្ដោះអាសន្នតាមរបៀបដែលបង្គាប់ឲ្យដកហូតលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលនាវានោះស្ថិតនៅ ត្រូវមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ ។

ក្រឡាបញ្ជី ត្រូវផ្ដុកផ្ដាក់ឲ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន ។

បញ្ញត្តិនៃកថាខណ្ឌទី ២ និង ទី ៣ នៃមាត្រា ៩៥៥(ពាក្យសុំឲ្យអនុវត្តដោយបង្ខំចំពោះនាវា និង របៀបអនុវត្ត ) មាត្រា ៩៦៥ (ការលុបចោលនីតិវិធីលក់ដោយបង្ខំ ដោយការវិនាសបាត់បង់នាវា ជាអាទិ៍ )និង មាត្រា ៩៦៦(ការផ្ដុកផ្ដាក់ឲ្យលុបការចុះបញ្ជីអំពីការរឹបអូស ) ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន តាមរបៀបចុះបញ្ជី ហើយបញ្ញត្តិនៃកថាខណ្ឌ ទី៣ នៃមាត្រា ៩៥៥( ពាក្យសុំឲ្យអនុវត្តដោយបង្ខំចំពោះនាវា និង របៀបអនុវត្ត ) កថាខណ្ឌទី ៧ នៃមាត្រា ៩៥៧ (ដីកាសម្រេចចាប់ផ្ដើម ជាអាទិ៍ មាត្រា ៩៦០ (ការជ្រើសតាំងអ្នកថែរក្សាគ្រប់គ្រង ជាអាទិ៍) និង មាត្រា ៩៦២ (ការអនុញ្ញាតិឲ្យនាវាធ្វើដំណើរ ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន តាមរបៀបដែលបង្គាប់ឲ្យដកហូតលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ ។

**ង- ការចាត់ចែងជាបណ្ដោះអាសន្ន ចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ**

អនុវត្តដូចគ្នាចំពោះនីតិវិធីរឹបអូសជាបណ្ដោះអាសន្ន ឬការអនុវត្តដោយបង្ខំ វិធីចាត់ចែងគឺ អាស្រ័យទៅលើខ្លឹមសារសម្រេចបញ្ជារបស់ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ។

www.facebook.com/7khmer
fb : Entertainment  And Knowledge

**កថាភាគទី ៣៖ សោហ៊ុយនៃការចាត់ចែងរក្សាការពារ** (មាត្រា ៥៣៧ )

**១-ពន្ធដាក់ពាក្យសុំ ៖**

ក្នុងករណីដែលដាក់ពាក្យសុំឲ្យចេញដីកាសម្រេចរក្សាការពារ អ្នកដែលដាក់ពាក្យសុំត្រូវបង់ពន្ធចំនួន ៥.០០០(ប្រាំពាន់) រៀល ទៅតុលាការ (មាត្រា ៥៣៧ កថាខណ្ឌទី ១) ។

បើពន្ធដាក់ពាក្យសុំខាងលើនេះ មិនត្រូវបានបង់ទេ តុលាការ ត្រូវបង្គាប់ឲ្យម្ចាស់បំណុលបង់ពន្ធដាក់ពាក្យសុំក្នុងអំឡុងពេលសមរម្យ (មាត្រា ៥៣៩ និង មាត្រា ៧៨ កថាខណ្ឌទី ១) ។

បើម្ចាស់បំណុលមិនបង់ពន្ធដាក់ពាក្យសុំតាមការបង្គាប់ខាងលើនេះ ទេ តុលាការត្រូវលើកពាក្យសុំចោល ដោយដីកាសម្រេច (មាត្រា ៧៨ កថាខណ្ឌទី ២ ) ។

ចំពោះដីកាសម្រេចលើកចោលនូវពាក្យសុំ អាចប្តឹងជំទាស់បាន ។

ក្នុងករណីដែលដាក់ពាក្យសុំឲ្យអនុវត្តការរក្សារការពារចំពោះអាជ្ញាសាលា អ្នកដែលដាក់ពាក្យសុំត្រូវបង់ពន្ធ តាមបញ្ញត្តិដែលបានកំណត់ផ្សេង ។

__**សំគាល់៖**__ ចំពោះសោហ៊ុយសម្រាប់ការចាត់ចែងការរក្សារការពារ ជាគោលការណ៍បញ្ញត្តិស្តីពីប្រាក់ប្រដាប់ក្តី ក្នុងជំពូកទី ៤ នៃគន្ថីទី១ ត្រូវបានយកមកអនុវត្ត លើកលែងតែបញ្ញត្តិនៃមាត្រា ៦១ (ពន្ធដាក់ពាក្យសុំ ) និង កថាខណ្ឌទី ៣ និង កថាខណ្ឌទី ៤ នៃមាត្រា ៦២ (ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ ) ។ មានន័យថា ក្នុងនីតិវិធីរក្សារការពារ ការចេញដីកាសម្រេចធ្វើការចាត់ចែងរក្សារការពារ និង ការអនុវត្តការរក្សាការពារ គឺជាកិច្ចការភ្ជាប់នឹងគ្នា ហេតុដូច្នេះ ចំពោះសោហ៊ុយសម្រាប់នីតិវិធីចេញដីកាសម្រេចធ្វើការរក្សាការពារ ព្រមទាំងនីតិវិធីអនុវត្តការរក្សាការពារ សោហ៊ុយទាំងឡាយ ដូចជាពន្ធនៃការដាក់ពាក្យសុំទៅតុលាការ និង ទៅអាជ្ញាសាលា ប្រាក់ប្រដាប់ក្តីក្រៅពីពន្ធនៃការដាក់ពាក្យសុំ និងប្រាក់ប្រដាប់ក្តីភាគី ជាបន្ទុករបស់ភាគីម្ខាងទៀត ប្រសិនបើតុលាការទទួលស្គាល់ពាក្យសុំឲ្យចេញដីកាសម្រេចរក្សាការពារ ហើយជាបន្ទុករបស់អ្នកដាក់ពាក្យសុំឲ្យចេញដីកាសម្រេចរក្សាការពារ នោះ ត្រូវបានច្រានចោល ។

**២-ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ៖**

បន្ថែមលើពន្ធដាក់ពាក្យសុំដែលបានកំណត់ខាងលើ ម្ចាស់បំណុល ត្រូវបង់ប្រាកប្រដាប់ក្តីតុលាការផ្សេងទៀត សម្រាប់តុលាការបញ្ជូនឯកសារ ។ ល ។ ដែលស្របតាមមាត្រា ៦២ កថាខណ្ឌទី ១ ឧទាហរណ៍ សោហ៊ុយសម្រាប់ការបញ្ជូនដីកាសម្រេច ទៅកូនបំណុល (មាត្រា ៥៤៣ ) ។

លើកលែងតែមានបញ្ញត្តិពិសេសក្នុងគន្ថីទី ៧ (ការរក្សាការពារ) នៃក្រមនីតិវិធីរដ្ឋប្បវេណី បញ្ញត្តិនៃគន្ថីទី ១ (បទបញ្ញត្តិទូទៅ ) ត្រូវបានយកទៅអនុវត្ត ចំពោះនីតិវិធីនៃការរក្សារការពារ

www.facebook.com/7khmer
fb : Entertainment And Knowledge

ដែរ ដូច្នេះ មាត្រា ៦២ ត្រូវបានអនុវត្ត ចំពោះប្រាក់ប្រដាប់ក្តីតុលាការសម្រាប់ចេញដីកាសម្រេច រក្សាការពារផងដែរ ។

សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ កំណត់ដោយតុលាការអនុវត្តមានសោហ៊ុយៈ

- សោហ៊ុយសម្រាប់ធ្វើដំណើរស្នាក់នៅសំរាប់មន្ត្រីទទួលបន្ទុកអនុវត្ត
- ផ្ញើរឯកសា ទូរស័ព្ទ ទូរសារ
- សំរាប់ជូនដំណឹងជាសាធារណៈ
- សំរាប់អ្នកបច្ចេកទេស
- ការដឹកជញ្ជូនគ្រប់គ្រង
- និងសោហ៊ុយសំរាប់ការលក់ឡាយឡុង ។ ល ។(មាត្រា ៣៧៣ ) ។

**គួរចងចាំ**

| | |
|---|---|
| រៀនច្បាប់ឲ្យបានស្ទាត់ចេះពេញលេញ | គួរខំទន្ទេញកាត់មុសា |
| កុំកោងចិត្តកាចពាលឫស្យា | ដល់ព្រឹទ្ធាចារ្យមេបាខ្លួន ។ |
| រៀនយូរទើបចេះគិតជ្រាលជ្រៅ | ទាញល្ងង់ឬខ្លៅទៅជាប្រាជ្ញ |
| មិនគួររៀនចេះត្រឹមប្រមាថ | ឲ្យគេយល់ប្រាជ្ញថាជាខ្មៅ ។ |

**គួរចងចាំ**

| | |
|---|---|
| ជាអ្នកគ្រប់គ្រងត្រូវពឹងច្បាប់ | កុំពឹងគេប្រាប់នាំអប្រិយ |
| ពឹងច្បាប់នាំខ្លួនឲ្យប្រពៃ | ពឹងច្បាប់ផុតភ័យទុក្ខវឹកវរ ។ |
| យោងច្បាប់នាំខ្លួនជាគំរូ | គំរូល្អអស់ទាំងនគរ |
| ប្រជាបានសុខគ្រប់តំណ | ម្លប់ត្រជាក់ល្អគឺម្លប់ច្បាប់ ។ |